**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# សកម្មភាពការងារសមិទ្ធផលឆ្នាំ២០១៥
# និងទិសដៅការងារឆ្នាំ២០១៦
# របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

**រៀបចំដោយ**

អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

ខែមិនា ឆ្នាំ២០១៦

# មាតិកា


**លិខិតថ្វាយព្រះពរ និងជូនពរ** ........ 2

**អារម្ភកថា** ........ 3

**ពាក្យបំព្រួញនិងអក្សរកាត់** ........ 4

**១. សេចក្តីផ្តើម** ........ 6

**២. វឌ្ឍនភាពនៃការអនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងហូជីមិញ** ........ 10

**៣. សមិទ្ធផលសំខាន់ៗសម្រេចបានកន្លងមកក្នុងក្របខណ្ឌ MRC** ........ 17

**៣.១ សមិទ្ធផលធំៗដែល MRC សម្រេចបានកន្លងមក** ........ 17

**៣.២ សមិទ្ធផលសំខាន់ៗក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គដែលកម្ពុជាទទួលបានកន្លងមក** ........ 19

**៤. សកម្មភាពការងារ និងសមិទ្ធផលផ្នែកអភិបាលកិច្ច និងតាមបណ្តានាយកដ្ឋាន ចំណុះអគ្គលេខាធិការដ្ឋាន និងទិសដៅការងារឆ្នាំ២០១៦** ........ 21

**៤.១ ផ្នែកអភិបាលកិច្ច** ........ 21

៤.១.១ ក្រុមប្រឹក្សា MRC ........ 21

៤.១.២ គណៈកម្មាធិការរួម MRC ........ 24

៤.១.៣ សមិទ្ធផលការងារទូទៅ ........ 29

**៤.២. សកម្មភាពការងារ និងសមិទ្ធផលតាមបណ្តានាយកដ្ឋាន** ........ 32

៤.២.១ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ........ 32

៤.២.២ នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ........ 36

៤.២.៣ នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ ........ 44

៤.២.៤ នាយកដ្ឋានគ្រប់គ្រងព័ត៌មាន និងចំណេះដឹង ........ 57

៤.២.៥ នាយកដ្ឋានបណ្តាគម្រោង និងកម្មវិធី ........ 65

**៥. ទិសដៅការងារសម្រាប់ឆ្នាំ២០១៦** ........ 80

**៦. ការវាយតម្លៃ និងសេចក្តីសន្និដ្ឋាន** ........ 85

**៧. ឧបសម្ព័ន្ធ: តារាងព្រឹត្តិការណ៍ និងសកម្មភាពការងាររបស់ គ.ជ.ទ.ម.ក** ........ 89

# លិខិតថ្វាយព្រះពរ និងជូនពរ
## ទូលបង្គំយើងខ្ញុំ ជាមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
## សូម

ក្រាបបង្គំទូលថ្វាយ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ** ព្រះរាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សូមព្រះអង្គមានព្រះរាជសុខភាពល្អបរិបូរ មានកម្លាំងខ្លាំងក្លា មានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់កូនចៅ ចៅទួតព្រះអង្គ ជានិច្ចជានិរន្តន៍។

ក្រាបបង្គំទូលថ្វាយ **ព្រះករុណាព្រះបាទ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ នូវមនោសញ្ចេតនា ប្រកបដោយកតញ្ញូ កតវេទិតាធម៌យ៉ាងស្មោះស្ម័គ្របំផុត សូមបួងសួងដល់អស់វត្ថុសក្តិសិទ្ធក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងទេវតាថែរក្សាឆ្នាំថ្មី ឆ្នាំវក អដ្ឋស័ក ព.ស២៥៦០ សូមជួយប្រោះព្រំសព្វសាធុពរជ័យ គាំពារថែរក្សាព្រះករុណាថ្លៃវិសេស សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរ ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ក្នុងសិរីរាជសម្បត្តិនៃព្រះរាជាណាចក្រកម្ពុជា និងជាម្លប់ដ៏ត្រជាក់សម្រាប់ប្រជារាស្ត្រខ្មែរ។

## សូមថ្វាយព្រះពរ និងជូនពរ

សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី ក្នុងឱកាសឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំវក អដ្ឋស័ក ព.ស២៥៦០ គ.ស២០១៦ សូមមានសុខភាពល្អបរិបូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាវាងវៃ និងជួបតែវិបុលសុខ សុភមង្គល និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

**ឯកឧត្តម លឹម គានហោ**<br>
រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម<br>
និងជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា<br>
ព្រមទាំងមន្ត្រីរាជការទាំងអស់ក្រោមឱវាទក្រសួង<br>
និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

# អារម្ភកថា



ឆ្នាំ២០១៥ គឺជាខួបលើកទី២០នៃការបង្កើតឡើងនូវគណៈកម្មការទន្លេមេគង្គ (MEKONG RIVER COMMISSION – MRC)។ ក្នុងរយៈពេល២ទសវត្សរ៍កន្លងទៅនេះ គណៈកម្មការទន្លេមេគង្គដែលមានសមាជិកបួនប្រទេស កម្ពុជា ឡាវ ថៃ និងវៀតណាម បានធ្វើការរួមគ្នា និងសម្រេចបាននូវសមិទ្ធផលគួរអោយកត់សម្គាល់មួយចំនួនលើផ្នែកៈ ការព្យាករណ៍ទឹកជំនន់ ការត្រួតពិនិត្យនិងគ្រប់គ្រងជលផល ការជម្រុញនាវាចរ ការត្រួតពិនិត្យនិងវាយតម្លៃគុណភាពទឹក ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងវារីអគ្គិសនីប្រកបដោយនិរន្តរភាព។ ក្រៅពីសមិទ្ធផលទាំងនេះ ជោគជ័យដែលសំខាន់ហើយមានលក្ខណៈជាប្រវត្តិសាស្ត្រនោះគឺ ការបង្កើតឡើងនូវបណ្តានីតិវិធីប្រើប្រាស់ទឹកផ្សេងៗគ្នាចំនួន៥ ដើម្បីប្រើជាឧបករណ៍អភិបាលកិច្ចសម្រាប់គ្រប់គ្រងការប្រើប្រាស់និងការបែងចែកទឹកក្នុងគោលដៅធានាអោយបានកាអភិវឌ្ឍន៍និងការគ្រប់គ្រងទឹកនិងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គប្រកបដោយនិរន្តរភាព។

ជោគជ័យនៃកិច្ចសហប្រតិបត្តិការតំបន់ខាងលើបានឆ្លុះបញ្ចាំងនូវផលជាវិជ្ជមានលើការអនុវត្តន៍កិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ និងការអនុវត្តផែនការយុទ្ធសាស្ត្ររបស់គណៈកម្មការទន្លេមេគង្គឆ្នាំ២០១១-២០១៥ ដែលជាការរួមចំណែកដល់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាតំណាក់កាលទី៣។ បណ្តាសមិទ្ធផលសំខាន់ៗ ដែលសម្រេចបានខាងលើនេះគឺបានមកពីកិច្ចខិតខំប្រឹងប្រែងនិងការប្តេជ្ញាចិត្តរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងមន្ត្រីអគ្គលេខាធិការដ្ឋានក្នុងការងារសម្របសម្រួលអនុវត្តការងារក្រោមកិច្ចសហការជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នជាសមាជិកដែលទាំងនេះគឺជាសក្ខីកម្មបង្ហាញពីការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែក្នុងការចូលរួមអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជាដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ។

ខ្ញុំមានមោទនភាពក្នុងការបង្ហាញជូននូវរបាយការណ៍សមិទ្ធផលការងារឆ្នាំ២០១៥ និងទិសដៅការងារឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដែលជាស្ថាប័នជាតិមួយបាននិងកំពុងចូលរួមលើកកំពស់និងជម្រុញការអនុវត្តគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា (២០០៧) ហើយក៏ជាគោលការណ៍ចម្បងប្រកាន់យកដោយគណៈកម្មការទន្លេមេគង្គក្នុងការអភិវឌ្ឍន៍ ការគ្រប់គ្រង និងការអភិរក្សធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គប្រកបដោយនិរន្តរភាព។

ខ្ញុំសូមអបអរសាទរ និងកោតសរសើរដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាទាំងអស់ព្រមទាំងបណ្តាដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដែលបានចូលរួមនិងគាំទ្រដល់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ហើយខ្ញុំសូមជូនពរ ឯកឧត្តមលោកជំទាវ អស់លោក លោកស្រីទាំងអស់ទទួលបាននូវពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៦

**ឯកឧត្តម លឹម គានហោ**

រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម

និងជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

# ពាក្យបំព្រួញនិងអក្សរកាត់

| | | |
|---|---|---|
| **AIP** | Agriculture and Irrigation Programme | កម្មវិធីកសិកម្ម និងធារាសាស្ត្រ |
| **BDP** | Basin Development Plan Programme | កម្មវិធីផែនការអភិវឌ្ឍន៍អាងទន្លេ |
| **CCAI** | Climate Change and Adaptation Initiative | គំនិតផ្តួចផ្តើមបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| **CF** | Core Function | មុខងារស្នូល |
| **CNMC** | Cambodia National Mekong Committee | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| **DMP** | Drought Management Programme | កម្មវិធីគ្រប់គ្រងគ្រោះរាំងស្ងួត |
| **EIA** | Environmental Impact Assessment | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| **EP** | Environment Programme | កម្មវិធីបរិស្ថាន |
| **FMMP** | Flood Management and Mitigation Programme | កម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ |
| **FP** | Fisheries Programme | កម្មវិធីជលផល |
| **GMS** | Greater Mekong Sub-region | មហាអនុតំបន់មេគង្គ |
| **ICBP** | Integrated Capacity Building Programme | កម្មវិធីកសាងសមត្ថភាពចម្រុះ |
| **IKMP** | Information and Knowledge Management Programme | កម្មវិធីគ្រប់គ្រងព័ត៌មាន និងចំណេះដឹង |
| **ISH** | Initiative on Sustainable Hydropower | គំនិតផ្តួចផ្តើមស្តីអំពីនិរន្តរភាពវារីអគ្គិសនី |
| **IWRM** | Integrated Water Resource Management | ការគ្រប់គ្រងធនធានទឹកចម្រុះ |
| **JC** | Joint Committee | គណៈកម្មាធិការរួម |
| **LMB** | LMB Lower Mekong Basin | អាងទន្លេមេគង្គក្រោម |
| **M-IWRMP** | Mekong Integrated Water Resource Management Project | គម្រោងគ្រប់គ្រងធនធានទឹកចម្រុះមេគង្គ |

| | | |
|---|---|---|
| **MRC** | Mekong River Commission | គណៈកម្មការទន្លេមេគង្គ |
| **MRCS** | Mekong River Commission Secretariat | លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ |
| **NAP** | Navigation Programme | កម្មវិធីនាវាចរ |
| **NMC** | National Mekong Committee | គណៈកម្មាធិការជាតិទន្លេមេគង្គ |
| **OSP** | Office of the MRC Secretariat in Phnom Penh, Cambodia | ការិយាល័យនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គនៅ ភ្នំពេញ ប្រទេសកម្ពុជា |
| **OSV** | Office of the MRC Secretariat in Vientiane, Lao PDR | ការិយាល័យនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គនៅវៀងច័ន្ទ ប្រទេសឡាវ |
| **PDIES** | Procedures for Data and Information Exchange and Sharing | និតិវិធីនៃការដោះដូរ និង ចែករំលែកទិន្នន័យ និង ព័ត៌មាន |
| **PMFM** | Procedures for the Maintenance of Flows on the Mainstream | និតិវិធីនៃការរក្សាលំហូរនៅលើទន្លេមេ |
| **PNPCA** | Procedures for Notification, Prior Consultation and Agreement | នីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ ជាមុននិងការព្រមព្រៀង |
| **PWQ** | Procedures for Water Quality | នីតិវិធីសម្រាប់គុណភាពទឹក |
| **PWUM** | Procedures for Water Use Monitoring | នីតិវិធីសម្រាប់ការតាមដានលើការប្រើប្រាស់ទឹក |

# ១. សេចក្តីផ្តើម

## ១.១ អំពីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គ.ជ.ទ.ម.ក) ហៅជាភាសាអង់គ្លេសថា Cambodia National Mekong Committee (CNMC) ត្រូវបានបង្កើតឡើងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា លេខ៣១៩/៨០ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៨០។ សេចក្តីសម្រេចនេះត្រូវបានជំនួសដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩០៩/៩៤៣ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការកែសម្រួល និងការធ្វើនិយតភាព ការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។ គ.ជ.ទ.ម.ក ជាស្ថាប័នជាតិមួយស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាល ដើម្បីសម្របសម្រួល ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គក្នុងក្របខណ្ឌជាតិ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពនៃសេដ្ឋកិច្ច សង្គម និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជាផលប្រយោជន៍ជាតិ និងប្រជាជន។

គ.ជ.ទ.ម.ក មានមុខងារ និងភារកិច្ចដូចតទៅៈ

- ជាសេនាធិការឲ្យរាជរដ្ឋាភិបាល លើរាល់ការគ្រប់គ្រង ការពិនិត្យពិចារណា ការសិក្សា និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ ក្នុងក្របខណ្ឌទូទាំងប្រទេស ដើម្បីបុព្វហេតុសេដ្ឋកិច្ចជាតិនិងផលប្រយោជន៍របស់ប្រជាជននិងបុព្វហេតុសន្តិភាព មិត្តភាព និងសហប្រតិបត្តិការអន្តរជាតិ
- ធ្វើការសិក្សា ពិនិត្យពិចារណា ហើយលើកសំណើជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ សម្រេចលើរាល់បញ្ហាទាំងឡាយណាដែលទាក់ទងនឹងការធ្វើផែនការ ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រង ការថែរក្សាការពារ និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គប្រកបដោយចីរភាព
- សម្របសម្រួល និងសហការជាមួយក្រសួង-ស្ថាប័នជាតិ ក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គប្រកបដោយចីរភាព
- រួមសហការជាមួយក្រសួង-ស្ថាប័ន រាជធានី-ខេត្តពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់រាជរដ្ឋាភិបាលស្តីពីអាងទន្លេមេគង្គ
- ពង្រឹងសហប្រតិបត្តិការជាមួយនិងគណៈកម្មាធិការជាតិទន្លេមេគង្គនៃប្រទេសជាសមាជិក MRC ជាមួយបណ្តាដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិផ្សេងៗក្នុងការពិនិត្យពិចារណា ការសិក្សា ការអភិវឌ្ឍន៍ ការគ្រប់គ្រង និងការថែរក្សាធនធានទឹក និងធនធានពាក់ព័ន្ធដទៃ

ទៀតក្នុងអាងទន្លេមេគង្គឲ្យបានសមស្របទៅនឹងផលប្រយោជន៍ដ៏សមរម្យរបស់បណ្តាប្រទេសជាសមាជិក និងដោយត្រឹមត្រូវតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីអាងទន្លេមេគង្គ

- ធ្វើទំនាក់ទំនង សម្របសម្រួលជាមួយ MRC និងដៃគូរអភិវឌ្ឍន៍ដើម្បីស្វែងរកថវិកាជំរុញការសិក្សា និងការអភិវឌ្ឍន៍គម្រោងឲ្យបានឆាប់រហ័ស ទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់
- គៀងគរ រកមធ្យោបាយ និងធនធានដើម្បីរួមចំណែកក្នុងការអនុវត្តកម្មវិធី គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងវិស័យធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
- អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដល់បណ្តាអ្នកពាក់ព័ន្ធ
- បំពេញភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន
- ក្នុងក្របខណ្ឌMRC គ.ជ.ទ.ម.ក មានតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល លើការរៀបចំ និងការអនុវត្តន៍គម្រោង និងកម្មវិធីនានារបស់ MRC ។

គ.ជ.ទ.ម.ក មានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | | អនុប្រធាន |
| ៤- ឥស្សរជនជាន់ខ្ពស់មួយរូប | | អនុប្រធាន |
| ៥- រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | | អនុប្រធានអចិន្ត្រៃយ៍ |
| ៦- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ០១ រូប | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១ រូប | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១ រូប | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១ រូប | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ០១ រូប | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | ០១ រូប | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងផែនការ | ០១ រូប | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ០១ រូប | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១ រូប | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១ រូប | សមាជិក |
| ១៧- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូប | សមាជិក |

១៨- រដ្ឋលេខាធិការក្រសួងកិច្ចការនារី ០១ រូប សមាជិក

១៩- អគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ០១ រូប សមាជិក

២០- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ០១ រូប សមាជិក

២១- អគ្គលេខាធិការអាជ្ញាធរទន្លេសាប ០១ រូប សមាជិក

**អគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក**

អគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក គឺជាសេនាធិការក្នុងការចាត់ចែង ដឹកនាំការងារប្រចាំថ្ងៃរបស់ គ.ជ.ទ.ម.ក ដឹកនាំដោយអគ្គលេខាធិការ ០១រូប និងមានអគ្គលេខាធិការរងចំនួន ៥រូប ជាជំនួយការ។ អគ្គលេខាធិការដ្ឋាន មាននាយកដ្ឋានចំនួន០៥ និងលេខាធិការដ្ឋានឋបនីយជីវមណ្ឌលបឹងទន្លេសាប ចំនួន០១ ដឹកនាំដោយប្រធាននាយកដ្ឋាន និងមានអនុប្រធាននាយកដ្ឋានមួយចំនួន។ ក្នុងនាយកដ្ឋាននីមួយៗ មានការិយាល័យមួយចំនួនដែលដឹកនាំដោយប្រធាន និងអនុប្រធានការិយាល័យជាជំនួយការ។ ក្នុងឆ្នាំ ២០១៥ មន្ត្រីរាជការ និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋានសរុបមានចំនួន ៤៤រូប ស្រ្តី ០៧ រូប ក្នុងនោះ មានមន្ត្រីបុគ្គលិកជាប់កិច្ចសន្យាដែលចូលរួមអនុវត្តគម្រោងកម្មវិធីចំនួន១១រូប ស្រ្តី ០៤រូប។



## ១.២ អំពីគណៈកម្មការទន្លេមេគង្គ

គណៈកម្មការទន្លេមេគង្គ ហៅជាភាសាអង់គ្លេសថា **Mekong River Commissio** (MRC) គឺជាស្ថាប័នអន្តររដ្ឋាភិបាល ត្រូវបានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ ស្តីពីកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ។ MRC មានតួនាទី ធ្វើសហប្រតិបត្តិការលើគ្រប់វិស័យនៃ ការអភិវឌ្ឍ ការប្រើប្រាស់ ការគ្រប់គ្រង និងការអភិរក្សប្រកបដោយនិរន្តរភាពនូវធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត ក្នុងអាងទន្លេមេគង្គ រួមជាអាទិ៍មាន ការស្រោចស្រព វារីអគ្គិសនី នាវាចរណ៍ ការត្រួតពិនិត្យទឹកជំនន់ ជលផល ការបណ្តែតក្បូនឈើ ការកំសាន្ត និងទេសចរណ៍ ក្នុងលក្ខណៈមួយ ដើម្បីធ្វើឲ្យការប្រើប្រាស់ពហុបំណងកាន់តែប្រសើរបំផុត និងក្នុងផលប្រយោជន៍រួមទៅវិញទៅមករបស់ប្រទេសតាមដងទន្លេ និងដើម្បីកាត់បន្ថយផលប៉ះពាល់អាក្រក់ដែលអាចកើតឡើងពីបាតុភូតធម្មជាតិ និងសកម្មភាពរបស់មនុស្ស។ MRC មានអង្គការចាត់តាំងគ្រប់គ្រង ៣ គឺ ក្រុមប្រឹក្សា គណៈកម្មាធិការរួម និងលេខាធិការដ្ឋាន។

**ក្រុមប្រឹក្សា** ( **Council** )

ក្រុមប្រឹក្សា មានសមាជិក ០១រូប មកពីប្រទេសជាសមាជិកនីមួយៗ (ថ្នាក់រដ្ឋមន្រ្តី និងជាសមាជិករដ្ឋាភិបាល)។ ប្រធានក្រុមប្រឹក្សា មានអាណត្តិ ០១ឆ្នាំ (ពីថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែ ធ្នូ)។ ប្រធាន Council ត្រូវប្តូរវេនគ្នាតាមលំដាប់លេខរៀងអក្សរពីលើចុះក្រោមយកតាមអក្សរឡាតាំងនៃឈ្មោះប្រទេសជាសមាជិក (C-L-T-V) ឧទាហរណ៍៖ ប្រធាន Council សម្រាប់ឆ្នាំ២០១៦ គឺសមាជិក Council តំណាងប្រទេសឡាវ។ Council ត្រូវកោះប្រជុំជាទៀងទាត់យ៉ាងហោចណាស់ មួយដងក្នុងមួយឆ្នាំ គឺនៅត្រីមាសទី៤ និងអាចកោះប្រជុំពិសេសនៅពេលដែលយល់ឃើញថាចាំបាច់ តាមសំណើរបស់សមាជិកក្រុមប្រឹក្សាណាមួយឬរបស់ប្រធានគណៈកម្មាធិការរួម។ Council ជាអ្នកធ្វើសេចក្តីសម្រេចខាងនយោបាយ ជំនួសមុខរដ្ឋាភិបាល។

**គណៈកម្មាធិការរួម (Joint Committee "JC")**

គណៈកម្មាធិការរួមមានសមាជិក ០១រូប មកពីប្រទេសជាសមាជិកនីមួយៗ មានឋានៈចាប់ពីប្រធាននាយកដ្ឋានឡើងទៅ។ ប្រធាន **JC** មានអាណត្តិ ១ឆ្នាំ (ពីថ្ងៃទី ០១ ខែមករា ដល់ ថ្ងៃទី៣១ ខែ ធ្នូ)។ ប្រធាន **JC** ត្រូវប្តូរវេនគ្នាតាមលំដាប់លេខរៀងអក្សរបញ្រ្ច្រាសពីក្រោមឡើងលើនៃបញ្ជីឈ្មោះប្រទេសជាសមាជិកតាមអក្សរឡាតាំង **(V-T-L-C)** ឧទាហរណ៍ៈ ប្រធាន **JC** សម្រាប់ឆ្នាំ២០១៦ គឺ សមាជិក **JC** តំណាងប្រទេសថៃ។ **JC** ក្នុងមួយឆ្នាំ ត្រូវប្រជុំសាមញ្ញ ២ដង គឺនៅត្រីមាសទី១ និងត្រីមាសទី៣ និងប្រជុំវិសាមញ្ញមួយចន្ទួនតាមការចាំបាច់ទៅតាមសំណើរបស់សមាជិកគណៈកម្មាធិការរួមណាមួយ។ **JC** ជាអ្នកអនុវត្តគោលនយោបាយ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានិងជាអ្នកគ្រប់គ្រងសកម្មភាពការងាររបស់លេខាធិការដ្ឋាន **MRC** ។

**លេខាធិការដ្ឋាន MRC (MRC Secretariat)**

លេខាធិការដ្ឋាន MRC ជាសេនាធិការផ្តល់សេវាផ្នែករដ្ឋបាល និងបច្ចេកទេសដល់ក្រុមប្រឹក្សា និងគណៈកម្មាធិការរួម ដែលស្ថិតនៅក្រោមការគ្រប់គ្រងទូទៅដោយផ្ទាល់របស់គណៈកម្មាធិការរួម។ លេខាធិការដ្ឋាន MRC ដឹកនាំដោយនាយកប្រតិបត្តិ (CEO) ០១រូប ដែលត្រូវបានជ្រើសរើសដោយគណៈកម្មាធិការរួម តាមរយៈការប្រកួតប្រជែង និងសម្រេចដោយក្រុមប្រឹក្សា។ អាណត្តិរបស់ CEO មានរយៈពេល០៣ឆ្នាំ ដែលអាចបន្តបាន ១អាណត្តិ ០៣ឆ្នាំទៀត តាមការសម្រេចរបស់JC។ បច្ចុប្បន្ននេះ CEO ជាជនជាតិវៀតណាម ដែលត្រូវបានជ្រើសរើសសំរាប់អាណត្តិរយៈពេល០៣ឆ្នាំ ហើយដែលអណត្តិបន្ទាប់គឺដល់វេនកម្ពុជា។

# ២. វឌ្ឍនភាពនៃការអនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងហូជីមិញ

សេចក្តីថ្លែងការណ៍ទីក្រុងហូជីមិញ នៃកិច្ចប្រជុំកំពូលលើកទី២ របស់ MRC (**2nd MRC Summit's Ho Chi Minh Declaration**) នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៤ ថ្នាក់ដឹកនាំកំពូលបានបញ្ជាក់អះអាងជាថ្មីនូវឆន្ទៈនយោបាយក្នុងកម្រិតខ្ពស់ ដែលផ្តោតទៅលើ៖ ***ទី១. កិច្ចសហប្រតិបត្តិការណ៍ និង ជម្រុញការអភិវឌ្ឍប្រកបដោយនិរន្តរភាពនូវការប្រើប្រាស់ ការអភិរក្ស និងការគ្រប់គ្រងធនធានទឹក និងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ ទី២. ការពង្រឹងកិច្ចសហប្រតិបត្តិការណ៍ជាមួយដៃគូសន្ទនា (MRC Dialogue Partners) និងដៃគូអភិវឌ្ឍន៍ (MRC Development Partners) និងជាមួយបណ្តាអ្នកពាក់ព័ន្ធនានា សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងអាងទន្លេមេគង្គ ទី៣. ភាពជាម្ចាស់ការនៃប្រទេសជាសមាជិក ដើម្បីឈានដល់គោលដៅស្វ័យភាពហិរញ្ញវត្ថុ នៅឆ្នាំ ២០៣០***។ វឌ្ឍនភាពនៃការងារនេះ មានដូចខាងក្រោម៖

- ✓ *ការអនុវត្ត ការសិក្សារបស់ក្រុមប្រឹក្សា MRC ស្តីពីការគ្រប់គ្រងនិងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃទន្លេមេគង្គ ដោយរាប់បញ្ចូលទាំងផលប៉ះពាល់ពីគម្រោងទំនប់វារីអគ្គិសនីនៅលើទន្លេមេនៃទន្លេមេគង្គ និងទំនាក់ទំនងជាមួយការសិក្សាដីសណ្តទន្លេមេគង្គ ដែលផ្តួចផ្តើមដោយប្រទេសវៀតណាម ដើម្បីផ្តល់នូវដំបូន្មាន និងអនុសាសន៍ ក្នុងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ។*

គោលបំណងនៃការសិកស្សានេះ គឺដើម្បីបង្កើតឡើងនូវភស្តុតាងវិទ្យាសាស្ត្រដែលជឿទុកចិត្តបានចំពោះផល់ប៉ះពាល់ទាំងវិជ្ជមាននិងអវិជ្ជមានលើផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម ដែលបណ្តាលមកពីការអភិវឌ្ឍន៍នៅក្នុងអាងទន្លេមេគង្គ។ បើតាមផែនការ ការសិក្សានេះនឹងត្រូវបញ្ចប់នៅខែធ្នូ ឆ្នាំ ២០១៥ ប៉ុន្តែការសិក្សានេះមានការយឺតយ៉ាវ ហើយនឹងត្រូវពន្យាពេលដោយសារពុំមានថវិកាគ្រប់

គ្រាន់ ដូច្នេះការងារនេះនឹងធ្វើឡើងជាពីរដំណាក់កាល។ របាយការណ៍បណ្តោះអាសន្ន (**Interim Reports**) ត្រូវបានចងក្រងឡើងដោយបណ្តាក្រុមអ្នកសិក្សាទៅតាមផ្នែកនីមួយៗ រួមមាន៖ អភិក្រមម៉ូដែល ការរៀបចំម៉ូដែល ការកំណត់ស្ថានភាពគោល និងការតាក់តែងសេណារីយ៉ូអភិវឌ្ឍន៍ ហើយបានដាក់ជូនប្រទេសជាសមាជិកកាលពីខែធ្នូ ឆ្នាំ២០១៥ ដើម្បីយកទៅប្រើប្រាស់ទៅតាមលទ្ធភាពដែលអាចប្រើបាន ដោយហេតុថារបាយការណ៍នេះពុំទាន់បានធ្វើការវាយតម្លៃទូលំទូលាយពីផលប៉ះពាល់នៃការអភិវឌ្ឍន៍ទៅតាមសេណារីយ៉ូផ្សេងៗគ្នានៅឡើយ។ ការរៀបចំរបាយការណ៍បណ្តោះអាសន្ននេះធ្វើឡើងទៅតាមការស្នើសុំរបស់ប្រទេសជាសមាជិកមុននឹងបញ្ចប់ដំណាក់កាលទី១ និងឈានទៅអនុវត្តដំណាក់កាលទី២ដែលជាដំណាក់កាលនៃការវាយតម្លៃពីផលប៉ះពាល់នៃការអភិវឌ្ឍន៍។

ការសិក្សានេះ បានធ្វើស្របគ្នាជាមួយនឹងការសិក្សាដីសណ្តទន្លេមេគង្គ ដែលផ្តួចផ្តើមដោយប្រទេសវៀតណាម ដែលជាការសិក្សាមួយដ៏ធំនៅក្នុងផែនការចង្អុលថ្នាក់ជាតិ **(National Indicative Plan)** ដោយមានការសម្របសម្រួលជាមួយកម្មវិធីអភិវឌ្ឍអាងទន្លេ (**Basin Development Plan**)។ ការសិក្សាដីសណ្តទន្លេមេគង្គបានបញ្ចប់កាលពីខែធ្នូឆ្នាំ២០១៥ ហើយប្រទេសវៀតណាមក៏បានផ្សព្វផ្សាយពីលទ្ធផលនៃការសិក្សានេះផងដែរ ដោយមានការបញ្ជូនបេសកជនពិសេសថ្នាក់រដ្ឋមន្ត្រីមកកាន់ប្រទេសកម្ពុជា និងបណ្តាប្រទេសជាសមាជិកដទៃទៀតដើម្បីរាយការណ៍ពីលទ្ធផលនៃការសិក្សានេះ។

- ✓ *ពិនិត្យសារឡើងវិញ ធ្វើបច្ចុប្បន្នភាព និងបន្តអនុវត្ត យុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេ (***Basin Development Strategy)** *និងផែនការយុទ្ធសាស្ត្ររបស់* **MRC** *ឆ្នាំ២០១១-២០១៥ (***MRC Strategic Plan***) រៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រ ឆ្នាំ២០១៦-២០២០ ដើម្បីជួយតម្រែតម្រង់ការអភិវឌ្ឍបច្ចុប្បន្ន និងអនាគតនៅក្នុងអាងទន្លេមេគង្គ។*

យុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេ ឆ្នាំ២០១១-២០១៥ ត្រូវបានអនុវត្តតាមរយៈផែនការសកម្មភាពអាង (Basin Action Plan) ផែនការសកម្មភាពថ្នាក់តំបន់ (Regional Action Plan) និងផែនការចង្អុលថ្នាក់ជាតិទាំង៤ប្រទេស។ នៅដំណាច់ឆ្នាំចុងក្រោយនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្ររបស់ MRC ឆ្នាំ២០១១-២០១៥ ប្រហែល៩០% នៃសកម្មភាពដែលមាននៅក្នុងផែនការសកម្មភាពថ្នាក់តំបន់ត្រូវបានអនុវត្ត និង៧០% នៃផែនការចង្អុលថ្នាក់ជាតិត្រូវបានអនុវត្ត។ នៅដំណាច់ឆ្នាំ២០១៥នេះ លើសពី៧៥% នៃសកម្មភាពជាយុទ្ធសាស្ត្រដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេត្រូវបានអនុវត្ត។ សកម្មភាពយុទ្ធសាស្ត្រទាំងឡាយណា ដែលមិនទាន់អនុវត្តចប់នៅចុងឆ្នាំ២០១៥ នឹងត្រូវដាក់បញ្ចូលទៅក្នុងឯកសារយុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេមេគង្គសម្រាប់ឆ្នាំ២០១៦-២០២០។

ការធ្វើបច្ចុប្បន្នភាព យុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេសម្រាប់ឆ្នាំ២០១៦-២០២០ ត្រូវបានបញ្ចប់តាមរយៈការអនុម័តរបស់គណៈកម្មាធិការរួម (MRC Joint Committee) និងការឯកភាពរបស់ក្រុមប្រឹក្សា (MRC Council) នៅដើមឆ្នាំ២០១៦។

ការរៀបចំផែនការយុទ្ធសាស្ត្រ MRC ឆ្នាំ២០១៦-២០២០ ដោយផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេសម្រាប់ឆ្នាំ២០១៦-២០២០ និងផែនការប្រចាំឆ្នាំ២០១៦ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រ MRC ឆ្នាំ២០១៦-២០២០ ត្រូវបានបញ្ចប់ដោយ។ សេចក្តីព្រាងឯកសារផែនការយុទ្ធសាស្ត្ររបស់ MRC ឆ្នាំ២០១៦-២០២០ និងផែនការប្រចាំឆ្នាំ២០១៦ ត្រូវបានអនុម័តដោយគណៈកម្មាធិការរួម (MRC Joint Committee) និងឯកភាពដោយក្រុមប្រឹក្សា (MRC Council) នៅដើមឆ្នាំ២០១៦។ ដៃគូអភិវឌ្ឍន៍របស់MRC បានគាំទ្រ និងសន្យាផ្តល់ជំនួយហិរញ្ញវត្ថុជាបន្តសម្រាប់រយៈពេល៥ឆ្នាំបន្ទាប់ (ឆ្នាំ២០១៦-២០២០) ដែលមានប្រមាណ ៥៣លាន ដុល្លា។

✓ *ចៀសវាង កាត់បន្ថយហានិភ័យដល់អេកូឡូស៊ីទន្លេ សន្តិសុខស្បៀង ជីវភាពរស់នៅ និងគុណភាពទឹក ដោយសារប្រពលវប្បកម្មកសិកម្ម (Intensive Agriculture) វារីវប្បកម្ម និងធារាសាស្ត្រ ក៏ដូចជាទំនប់វារីអគ្គិសនី នាវាចរណ៍ និងសកម្មភាពអភិវឌ្ឍដទៃទៀត នៅក្នុងអាងទន្លេមេគង្គ ដោយទទួលស្គាល់ថា ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ អាចបន្ថែមបន្ទុកទៅលើហានិភ័យខាងលើ។*

កម្មវិធីកសិកម្មនិងធារាសាស្ត្រ បានធ្វើការវាយតម្លៃនិងកំណត់ហានិភ័យដល់សន្តិសុខស្បៀងដោយសារការប្រែប្រួលអាកាសធាតុ។ កម្មវិធីនេះជាមួយនឹងកម្មវិធីប្រែប្រួលអាកាសធាតុ និងកម្មវិធីជលផល មានគម្រោងរួមគ្នាមួយធ្វើការវាយតម្លៃផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុនៅក្នុងអាងទន្លេមេគង្គក្រោមលើសន្តិសុខស្បៀង និងជម្រើសនៃការបន្សាំ។ បានបញ្ចប់និងធ្វើការបោះពុម្ពផ្សព្វផ្សាយដល់អ្នកធ្វើគោលនយោបាយ ពីលទ្ធផលនៃការសិក្សាលើផលិតកម្មដំណាំដើម្បីសន្តិសុខស្បៀង និងស្ថានភាពគោលនៃភាពក្រីក្រនៅតាមជនបទ និងគម្រោងសាកល្បង ក៏ដូចជាការត្រួតតពិនិត្យមើលឡើងវិញពីប្រព័ន្ធស្រោចស្រពសម្រាប់សន្តិសុខស្បៀង ការកត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ជនបទ។ ការសិក្សាពីការប្រើប្រាស់ទឹកក្រោមដីសម្រាប់ផលិតកម្មកសិកម្មកំពង់តែមានវឌ្ឍន៍ភាពផងដែរ។

ដើម្បីចៀសវាងនិងកាត់បន្ថយបណ្តាហានិភ័យលើសន្តិសុខស្បៀង ផ្នែកជលផលបានយកចិត្តទុកដាក់ពិសេសលើការធ្វើផែនការគ្រប់គ្រងជលផលសម្រាប់អាងទន្លេទាំមូល ជាមួយនឹងការអនុវត្តការអភិវឌ្ឍធនធានទឹកនៅតាមបណ្តាវិស័យដទៃទៀត។ គម្រោងគ្រប់គ្រងជលផលឆ្លងដែនចំនួន០២ រវាងបណ្តាខេត្តជាប់ព្រំដែននៃប្រទេសកម្ពុជា-វៀតណាម និងឡាវ-ថៃ កំពុងតែដំណើរការ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍និងគ្រប់គ្រងធនធានជលផលសម្រាប់អាងទន្លេទាំមូលត្រូវបានពិគ្រោះយោបល់ជាមួយបណ្តាអ្នកជាប់ពាក់ព័ន្ធ។ ក្រៅពីនេះ តាមរយៈការសហការជាមួយកម្មវិធីប្រែប្រួលអាកាសធាតុ កម្មវិធីជលផលកំពុងតែរៀបចំម៉ូដែលដើម្បីព្យាករណ៍ពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុទៅលើធនធានជលផល។

ដោយទទួលស្គាល់ពីសារៈសំខាន់ដែលវារីអគ្គិសនីផ្តល់ដល់ការរីកលូតលាស់សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ កម្មវិធីនិរន្តរភាពវារីអគ្គិសនីកំពុងអនុវត្តការសិក្សាមួយចំនួនដើម្បីជួយដល់បណ្តាប្រទេសជាសមាជិកធ្វើផែនការ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពចំពោះការកើនឡើងនៃចំនួនគម្រោងវារីអគ្គិសនីនៅទន្លេមេគង្គក្រោម។ បន្ទាប់ពីបានបញ្ចប់ការសិក្សាស្តីពី “ *ការកែលម្អព័ត៌មានគោលលើផ្នែកបរិស្ថាននិងសេដ្ឋកិច្ចសង្គមសម្រាប់ការធ្វើផែនការវារីអគ្គិសនី*” ។ លទ្ធផលនៃការសិក្សាទាំងនេះដែលបានធ្វើឡើងរវាងឆ្នាំ ២០១១-២០១៥ នឹងជួយដល់ការវាយតម្លៃនាពេលអនាគតលើផលប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច សង្គម បង្កឡើងដោយគម្រោងវារីអគ្គិសនីដែលមានលក្ខណៈសំខាន់សម្រាប់អាងទន្លេទាំមូល។

ដើម្បីការពារអេកូឡូស៊ីទន្លេ និងធ្វើឲ្យប្រសើរឡើងនូវគុណភាពទឹក គណៈកម្មការទន្លេមេគង្គបានរៀបចំផែនការសកម្មភាពថ្នាក់តំបន់សម្រាប់ការដឹកជញ្ជូនប្រកបដោយនិរន្តរភាព នូវរាល់បណ្តាទំនិញដែលមានគ្រោះថ្នាក់ និងបានរៀបចំគោលការណ៍ណែនាំសម្រាប់អធិការកិច្ចនាវា ការគ្រប់គ្រងទំនិញដែលមានគ្រោះថ្នាក់នៅតាមកំពង់ផែ និងផែនការគ្រប់គ្រងកាកសំណល់សម្រាប់ប្រើប្រាស់នៅតាមបណ្តាផៃលើកដាក់ប្រេងនិងសារធាតុគីមី។ ការអនុវត្តផែនការនេះ នឹងជួយបន្ថយបានច្រើននូវហានិភ័យនៃការផ្ទុះ ការកំពប់ប្រេង និងការបំពុល និងធ្វើឲ្យប្រសើរនូវការឆ្លើយតបបន្ទាន់ និងយន្តការទំនាក់ទំនងថ្នាក់តំបន់។ កម្មវិធីនាវាចរណ៍ និងក្រុមការងារជំនាញថ្នាក់ជាតិ បានបញ្ចប់គោលការណ៍ណែនាំស្តីពី អធិការកិច្ចនាវា ការគ្រប់គ្រងទំនិញគ្រោះថ្នាក់នៅកំពង់ផែ និងផែនការគ្រប់គ្រងសំណល់។ សកម្មភាពដទៃទៀត ការធ្វើឲ្យប្រសើឡើងនូវសុវត្ថិភាពនាវាចរណ៍ នៅតាមព្រែកជីក រាប់បញ្ចូលការតម្លើងពោងសញ្ញានៅកណ្តាលទន្លេ និងបង្គោលសញ្ញានៅតាមច្រាំងទន្លេនៅកម្ពុជា (ពីភ្នំពេញ ដល់ទល់ដែន) និងនៅវៀតណាម (ក្នុងខេត្តដុងថាប់)។

លេខាធិការដ្ឋាន MRC តាមរយៈកម្មវិធីការប្រែប្រួលអាកាសធាតុ កំពុងធ្វើការវាយតម្លៃអាងទន្លេទាំមូលពីផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុលើស្ថានភាពរបបជលសាស្ត្រទឹកជំនន់ គ្រោះរាំងស្ងួត ប្រព័ន្ធអេកូរ សន្តិសុខស្បៀង ការផលិតវារីអគ្គសនី និងសង្គម-សេដ្ឋកិច្ចនៅទន្លេមេគង្គក្រោម។ ដើម្បីសម្រេចបានការងារខាងលើនេះ កម្មវិធីការប្រែប្រួលអាកាសធាតុ បាននិងកំពុងប្រមូលទិន្នន័យរយៈពេល៣០ឆ្នាំ និងយូរជាងនេះ លើផ្នែកឧតុនិយម ខ្យល់ព្យុះ និងការព្យាករណ៍អាកាសធាតុនៅពេលអនាគតតាមតំបន់នីមួយៗនៃអាងទន្លេមេគង្គ។ ដោយប្រើប្រាស់ទិន្នន័យដែលប្រមូលបានខាងលើ លេខាធិការដ្ឋាន MRC បានរៀបចំជារបាយការណ៍បច្ចេកទេសតាមរយៈការវិភាគការប្រែប្រួលអាកាសធាតុ និងកំណត់ពីសេណារីយ៉ូការប្រែប្រួលអាកាសធាតុនាពេលអនាគតសម្រាប់តបន់ទាំងមូល។ មកដល់ពេលនេះ កម្មវិធីការប្រែប្រួលអាកាសធាតុ ដោយសហការជាមួយកម្មវិធីគ្រប់គ្រងព័ត៌មាននិងចំណេះដឹង កំពុងតែធ្វើការវាយតម្លៃពីការប្រែប្រួលនាពេលអនាគតចំពោះលំហូរធារទឹក ការកើនជាតិប្រៃ កំណកកករ និងជីជាតិ នៃទន្លេមេគង្គ។ លទ្ធផលនៃការវាយតម្លៃនេះ និងការវិភាគផ្សេងៗទៀត នឹងផ្តល់ជាធាតុចូលសម្រាប់ការធ្វើរបាយការណ៍ថ្នាក់តំបន់លើកទី១ស្តីពីស្ថានភាព

បម្រែបម្រួលអាកាសធាតុនិងការបន្សាំនៅក្នុងអាងទន្លេមេគង្គភាគខាងក្រោម និងសម្រាប់ការរៀបចំយុទ្ធសាស្រ្តបន្សាំថ្នាក់តំបន់ និងផែនការសកម្មភាពនៅក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោមដែលនឹងបញ្ចប់នៅឆ្នាំ២០១៦។

- ✓ *បន្តធ្វើឲ្យប្រសើរឡើងនូវការអនុវត្តន៍នីតិវិធីប្រើប្រាស់ទឹករបស់ MRC ដើម្បីគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ និងមានឆន្ទៈក្នុងការអនុវត្តនីតិវិធីនេះឲ្យមានប្រសិទ្ធភាព ដើម្បីសម្រេចបានដល់គោលដៅនៃកិច្ចព្រមព្រៀងមេគង្គ។*

នីតិវិធីប្រើប្រាស់ទឹកទាំង៥ ដែលបានអនុម័តដោយក្រុមប្រឹក្សានៃMRC និងការរៀបចំគោលការណ៍បច្ចេកទេសដើម្បីគាំទ្រដល់ការអនុវត្តនីតិវិធីទាំងនេះ។ ការអនុវត្តនីតិវិធី ស្តីពីការផ្លាស់ប្តូរ និងចែកចាយទិន្នន័យ បានផ្តោតលើការបង្កើតប្រព័ន្ធទិន្នន័យ (Information System) ដើម្បីធ្វើឲ្យប្រសើរនូវយន្តការចែកចាយទិន្នន័យ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន និងមានការជួយជ្រោមជ្រែងផ្នែកថវិកាពីMRC គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាបានបង្កើតប្រព័ន្ធទិន្នន័យមួយដើម្បីចែកចាយទិន្នន័យដែល MRCS មាន។

ឡាវ បានដាក់គម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ទៅក្នុងដំណើរការពិគ្រោះយោបល់ជាមុនដើម្បីអោយស្របតាមនីតិវិធីស្តីពី *ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និង ការព្រមព្រៀង* (PNPCA) កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ ហើយដំណើរការពិគ្រោះយោបល់ជាមុនរយៈពេល ០៦ខែ បានចាប់ផ្តើមពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤។ ក្នុងរយៈពេល ០៦ខែ នៃដំណើរការពិគ្រោះយោបល់ជាមុននេះ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានរៀបចំអោយមានការប្រជុំពិគ្រោះយោបល់ទាំងថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីប្រមូលមតិយោបល់ ក្តីបារម្ភ និងអនុសាសន៍ទាក់ទងនឹងផលប៉ះពាល់អវិជ្ជមាននានា ដែលអាចកើតមានឡើងដោយសារការសាងសង់ទំនប់វារីអគ្គិសនី **ដន សាហុង**។ ក៏ដូចជាភាគីថៃនិងវៀតណាមដែរ កម្ពុជាបានបំពេញកាតព្វកិច្ចរបស់ខ្លួនតាមរយៈការបំពេញនូវទម្រង់ឆ្លើយតប ដែលបានបញ្ជាក់ជំហរយ៉ាងច្បាស់ដោយសុំអោយមាន *ការសិក្សាគ្រប់ជ្រុងជ្រោយស្តីពីផលប៉ះពាល់ឆ្លងដែនលើផ្នែក បរិស្ថាន សង្គម និងសេដ្ឋកិច្ច* នៃរាល់បណ្តាប្រទេសដែលនៅក្រោមខ្សែទឹក។ កិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការរួម កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ បានលើកឡើងនូវក្តីបារម្ភជាច្រើន ហើយស្នើអោយមានការពន្យាពេលដំណើរការពិគ្រោះយោបល់ជាមុន ដើម្បីប្រមូលទិន្នន័យនិងសិក្សាបន្ថែម ប៉ុន្តែភាគីឡាវយល់ឃើញថាដំណើរការពិគ្រោះយោបល់ជាមុនរយៈពេល ០៦ ខែត្រូវបានបញ្ចប់ ។ ដោយសារគណៈកម្មាធិការរួម ក៏ដូចជាក្រុមប្រឹក្សាមិនអាចរកការឯកភាពបានបញ្ហានេះត្រូវបានបញ្ជូនទៅកាន់ថ្នាក់រដ្ឋាភិបាលដើម្បីដោះស្រាយ។ ឯកសារស្តីពីមេរៀននិងបទពិសោធន៍ដែលបានរៀនសូត្រតាមរយៈការអនុវត្តន៍នីតិវិធីស្តីពី *ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និង ការព្រមព្រៀង* (PNPCA) ត្រូវបានចងក្រងឡើយដើម្បីឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការអនុវត្តន៍នីតិវិធី

ស្តីពី *ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និង ការព្រមព្រៀង* (PNPCA) ដើម្បីជាការរៀនសូត្ររបស់វេទិការួម (Joint Platform)។

ដើម្បីដោះស្រាយបាននូវភាពប្រឈម ដែលបានជួបប្រទះទាក់ទងនឹងការអនុវត្តបណ្តានីតិវិធី គណៈកម្មាធិការរួមបានបង្កើតជាវេទិការួម (Joint Platform) ដើម្បីពិភាក្សានិងរកដំណោះស្រាយក្នុងពេលដែលកំពុងបញ្ចប់គោលការណ៍បច្ចេកទេសមួយចំនួនក្នុងការអនុវត្តនីតិវិធីប្រើប្រាស់ទឹក។ ជាជំហានបន្តពីកិច្ចប្រជុំ Joint Platform លើកទី១ កិច្ចប្រជុំ Joint Platform លើកទី២ បានរៀបចំឡើងដើម្បីបូកសរុបអំពីបទពិសោធន៍ បញ្ហាជាប់គាំង និងការប្រឈមនានានៃការអនុវត្តន៍នីតិវិធីនីមួយៗ និងការព្រាងឯកសារការងារ (Working Paper) ដើម្បីស្នើឲ្យមានការពិនិត្យឡើងវិញនូវនីតិវិធី និងគោលការណ៍បច្ចេកទេសទាំងនេះ។ ជាមួយគ្នានេះ កិច្ចសន្ទនាលើកទី២ ត្រូវបានរៀបចំដើម្បីបង្កើនការស្វែងយល់គ្នាលើគោលបំណងនៃកិច្ចព្រមព្រៀងមេគង្គ និងនីតិវិធីប្រើប្រាស់ទឹក។

- ✓ *បង្កើនកិច្ចខំប្រឹងប្រែងក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទឹកជំនន់និងរាំងស្ងួតក្នុងអាងទន្លេមេគង្គ និងផលប៉ះពាល់នៃការកើនកំពស់ទឹកសមុទ្រ ការត្រួតពិនិត្យ និងចាត់វិធានការ ថែរក្សាគុណភាពទឹក នៅក្នុងអាងទន្លេមេគង្គ។*

កម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់និងមជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ថ្នាក់តំបន់ (Regional Flood Management and Mitigation Center) បានផ្តល់នូវសេវាកម្មជាមូលដ្ឋានចំនួនពីរគឺ ការព្យាករណ៍ទឹកជំនន់ (MRC Flood Forecasting System) និងការណែនាំអំពីជំនន់ទឹកភ្លៀង (MRC Flash Flood Guidance System) ដល់ប្រទេសជាសមាជិកដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងហានិភ័យនៃគ្រោះទឹកជំនន់នៅក្នុងអាងទន្លេមេគង្គភាគខាងក្រោម។ បន្ថែមពីនេះទៀតបានជួយគាំទ្រទាំងថវិកា និងបច្ចេកទេសដល់ប្រទេសជាសមាជិកពង្រីកបណ្តាញស្ថានីយទឹកភ្លៀងដែលចាំបាច់សម្រាប់ការព្យាករណ៍ទឹកជំនន់ សម្រាប់រយៈពេល ៥ ទៅ១០ថ្ងៃ ទៅមុខ។ ប្រព័ន្ធព្យាករណ៍ទឹកជំនន់ទឹកទន្លេមេគង្គផ្តល់សេវាកម្មជូនដំណឹង (Flood Warning Service) រយៈពេលពី ១ថ្ងៃ ទៅ ៥ថ្ងៃ នូវកំពស់ទឹកប្រចាំថ្ងៃក្នុងរដូវវស្សា គិតចាប់ពីថ្ងៃទី១ ខែមិថុនា ដល់ ថ្ងៃទី៣០ ខែតុលា និងការព្យាករណ៍ប្រចាំសប្តាហ៍នូវកំពស់ទឹក ពីថ្ងៃទី១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែឧសភា សម្រាប់ស្ថានីយ៍ចំនួន២២កន្លែង នៅតាមដងទន្លេមេ។ សេវាកម្ម ជូនដំណឹងអំពីជំនន់ទឹកភ្លៀង រៀងរាល់៣ម៉ោងម្តង និង២៤ម៉ោង ក្នុងមួយសប្តាហ៍ ក្នុងអំឡុងពេលមានអាកាសធាតុស្រួចស្រាវ ជាពិសេសនៅរដូវទឹកជំនន់ និងការធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវហានិភ័យនៃជំនន់ទឹកភ្លៀង សម្រាប់បណ្តាភូមិ ស្រុក នៅក្នុងអាងទន្លេមេគង្គភាគខាងក្រោម។

នៅក្នុងកិច្ចខិតខំប្រឹងប្រែងវាយតម្លៃ និងគ្រប់គ្រងហានិភ័យនៃគ្រោះរាំងស្ងួត កម្មវិធីគ្រប់គ្រងគ្រោះរាំងស្ងួត (Drought Management Programme) បាន ទី១)ធ្វើការវាយតម្លៃ ផលប៉ះពាល់ថ្នាក់

តំបន់នៃភាពរាំងស្ងួត ដោយផ្អែកលើសុចនាករ បានមកពីទិន្នន័យស្ថិតិ និងម៉ូឌែល ដោយការវិភាគ GIS ជាមួយនិងទិន្នន័យ អិមពិរិច បានមកពីតំបន់ប្រឈមនឹងភាពរាំងស្ងួត ទី២) វាយតម្លៃផលប៉ះពាល់ និងវិភាគភាពងាយរងគ្រោះ នៃភាពរាំងស្ងួត និងបម្រែបម្រួលអាកាសធាតុសម្រាប់តំបន់ដីសណ្តទន្លេមេគង្គ និងខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាម ទី៣)បានកំណត់តំបន់ងាយរងគ្រោះដោយសារភាពរាំងស្ងួត និងការវិភាគភាពការវាយតម្លៃផលប៉ះពាល់ និងភាពងាយរងគ្រោះនៃភាពរាំងស្ងួត និងបម្រែបម្រួលអាកាសធាតុសម្រាប់ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ នៃប្រទេសកម្ពុជា។

ទាក់ទងនឹងវិធានការថែរក្សាគុណភាពទឹកអោយបានល្អ គណៈកម្មាការទន្លេមេគង្គបាននិងកំពុងអនុវត្តការងារត្រួតពិនិត្យគុណភាពទឹកនិងសុខភាពអេកូឡូស៊ីសម្រាប់ទន្លេមេ និងដៃទន្លេ។ របាយការណ៍បច្ចេកទេសចំនួន០៣ បានផលិតរួមមាន៖ ការត្រួតពិនិត្យសុខភាពអេកូឡូស៊ីទន្លេ (Ecological health monitoring report) និងប័ណ្ណរបាយការណ៍ស្ថានភាពសុខភាពអេកូឡូស៊ី (Ecological health Report card) បានត្រូវបោះពុម្ព។ របាយការណ៍ថ្នាក់តំបន់ស្តីពីការត្រួតពិនិត្យគុណភាពទឹកឆ្នាំ២០១៤ ត្រូវបានរៀបចំនិងបោះពុម្ពក្នុងចុងឆ្នាំ២០១៥។

- ✓ *ស្រាវជ្រាវ និងកំណត់ឱកាស ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូសន្ទនារបស់គណៈកម្មការទន្លេមេគង្គ ជាមួយដៃគូអភិវឌ្ឍន៍បច្ចុប្បន្ន និងដៃគូនាពេលអនាគត និងជាមួយគំនិតផ្តួចផ្តើមតំបន់ និងអន្តរជាតិដទៃទៀត។*

លេខាធិការដ្ឋាន MRC បានធ្វើការជាបន្តក្នុងការថែរក្សា និងធ្វើឲ្យប្រសើរឡើងនូវភាពជាដៃគូបច្ចេកទេសជាមួយស្ថាប័នតំបន់ និងអន្តរជាតិ និងអង្គការគ្រប់គ្រងអាងទន្លេ តាមរយៈយន្តការផ្សេងៗ រាប់បញ្ចូលទាំងការរៀបចំ និងការចូលរួមក្នុងសិក្ខាសាលា វេទិកាបច្ចេកទេស កម្មវិធីផ្លាស់ប្តូរមន្ត្រីជំនាញ ការផ្លាស់ប្តូរទស្សនៈកិច្ចបច្ចេកទេស ទស្សនៈកិច្ចសិក្សា និងការផ្លាស់ប្តូរបទពិសោធន៍។

MRC បន្តស្វែងរកឱកាស ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការ ជាមួយដៃគូសន្ទនា កិច្ចសហប្រតិបត្តិការជាមួយចិន ត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈការផ្លាស់ប្តូរទស្សនៈកិច្ច និងកិច្ចប្រជុំបច្ចេកទេសនានា។ ក្រៅពីនេះកិច្ចសហការណ៍ជាមួយចិន ត្រូវបានពង្រឹងលើការអភិវឌ្ឍសមត្ថភាព ក្រោមគម្រោងមន្ត្រីជំនាញវ័យក្មេង (MRC Junior Riparian Professional) ដែលក្នុងឆ្នាំ២០១៥ មន្ត្រីចិនវ័យក្មេងចំនួន២នាក់ បានទទួលការស្វែងយល់ និងបន្តការបណ្តុះបណ្តាល ជាមួយកម្មវិធីគ្រប់គ្រង និងកាត់បន្ថយទឹកជំនន់ និងកម្មវិធីគ្រប់គ្រងព័ត៌មាននិងចំណេះដឹងនៃMRC លើប្រធានបទ សិក្សាអំពីកករល្បប់ដីទន្លេ រហូតដល់ការសង្កេតជលសាស្ត្រ។

លេខាធិការដ្ឋាន MRC បានអនុវត្តខ្ជាប់ខ្ជួននូវចក្ខុវិស័យ និងឆន្ទៈប្តេជ្ញាចិត្តខ្ពស់បំផុតរបស់ថ្នាក់ដឹកនាំនៃប្រទេសជាសមាជិក ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការគ្រប់គ្រងទឹក និងធនធានពាក់ព័ន្ធ នៃទន្លេមេគង្គ និងការអនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងហូជីមិញ និងគំនិតផ្តួចផ្តើមដទៃទៀត និងគោលនយោបាយចូលរួមកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងអាងទន្លេមេគង្គ។ ការអនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងហូជីមិញ នឹងមិនអាចសម្រេចទៅបាន បើគ្មានការបន្តគាំទ្រពីប្រទេសជាសមាជិក។

## ៣. សមិទ្ធផលសំខាន់ៗសម្រេចបានកន្លងមកក្នុងក្របខណ្ឌ MRC

គ.ជ.ទ.ម.ក ជាស្ថាប័នជាតិមួយដែលបានចូលរួមយ៉ាងសកម្មក្នុងដំណើរការសម្របសម្រួលកិច្ចសហប្រតិបត្តិការក្របខណ្ឌទន្លេមេគង្គ។ ក្នុងរយៈពេលជាង៣៤ឆ្នាំ គ.ជ.ទ.ម.ក បានផ្សារភ្ជាប់ទំនាក់ទំនងនិងធ្វើការងារយ៉ាងជិតស្និទប្រកបដោយផលិតភាពជាមួយបណ្តាសមាជិកដទៃទៀតដែលបាន ចូលរួមបង្កើតឡើងនូវគណៈកម្មការទន្លេមេគង្គ MRC តាមរយៈកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥។ តាមរយៈសហប្រតិបត្តិការក្របខណ្ឌគណៈកម្មការទន្លេមេគង្គ MRC បាននាំមកនូវជោគជ័យ និងសមិទ្ធផលគួរអោយកត់សម្គាល់មួយចំនួនដូចខាងក្រោម៖

### ៣.១ សមិទ្ធផលធំៗដែល MRC សម្រេចបានកន្លងមក:

- ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌតំបន់
- កសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស
- ចងក្រងបាននូវព័ត៌មាន ទិន្នន័យទាក់ទងនឹងធនធានទឹក និងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ
- កសាងបាននូវនីតិវិធីនៃការប្រើប្រាស់ទឹកទន្លេមេគង្គចំនួន៥៖
  - នីតិវិធីស្តីពីការដោះដូរ និងចែករំលែកទិន្នន័យ និងព័ត៌មាន និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់អនុវត្ត (Proceduer on Data and Information Exchange and Sharing – PDIES)
  - នីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់អនុវត្ត (Procedure on Notification, Prior Consultaion and Agreement – PNPCA)
  - នីតិវិធីស្តីពីការតាមដានពិនិត្យលើការប្រើប្រាស់ទឹកនិងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់អនុវត្ត (Procedure on Water Use Monitoring – PWUM)
  - នីតិវិធីស្តីពីការថែរក្សាជារទឹកលើទន្លេមេនិងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់អនុវត្ត (Procedure on Maintenance of Flow on the Mainstream – PMFM)
  - នីតិវិធីស្តីពីគុណភាពទឹកនិងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់អនុវត្ត (Procedure on Water Quality – PWQ)

- បង្កើតនិងអនុវត្តនូវកម្មវិធី និងគម្រោងសម្រាប់គ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានទឹកចំនួន ១៥ ដែលមានការគាំទ្រពីដៃគូអភិវឌ្ឍន៍រួមមាន:
  *១. កម្មវិធីប្រើប្រាស់ទឹក*
  *២. កម្មវិធីកសិកម្ម និងធារាសាស្ត្រ*
  *៣. កម្មវិធីកសាងផែនការអភិវឌ្ឍន៍អាងទន្លេ*

*៤. កម្មវិធីគ្រប់គ្រងគ្រោះរាំងស្ងួត*
*៥. កម្មវិធីបរិស្ថាន*
*៦. កម្មវិធីជលផល*
*៧. កម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់*
*៨. កម្មវិធីគ្រប់គ្រងព័ត៌មាននិងចំណេះដឹង*
*៩. កម្មវិធីកសាងសមត្ថភាពចម្រុះ*
*១០. កម្មវិធីនាវាចរណ៍*
*១១. កម្មវិធីការបន្សាំបម្រែបម្រួលអាកាសធាតុ*
*១២. កម្មវិធីនិរន្តរភាពវារីអគ្គីសនី*
*១៣. កម្មវិធីគ្រប់គ្រងធនធានទឹកចម្រុះមេគង្គ*
*១៤. កម្មវិធីវិមជ្ឈការ-មុខងារស្នូល*

- ជម្រុញការលើកកំពស់ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានទឹកនិងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ៖
  - តាមវិធីសាស្ត្រការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM)
  - តាមគោលការណ៍សមភាពយេនឌ័រ
  - តាមគោលការណ៍ចូលរួមពីអ្នកពាក់ព័ន្ធនានា
- បង្កើតសៀវភៅផែនទីផែនការអាងទន្លេផ្តល់នូវព័ត៌មានយ៉ាងទូលំទូលាយអំពីលទ្ធផលនៃការវាយតម្លៃសេណារីយ៉ូអភិវឌ្ឍន៍អាងទន្លេមេគង្គទាំងមូលដែលគាំទ្រដល់ការបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេរបស់ MRC។ សៀវភៅនេះផ្តល់ដល់អ្នកធ្វើផែនការយល់កាន់តែច្បាស់នូវកាលានុវត្តភាពដ៏ធំសម្បើម ការប្រឈម ហានិភ័យ ក្នុងការអភិវឌ្ឍន៍ធនធានទឹក និងធនធានពាក់ព័ន្ធនៅក្នុងអាងទន្លេមេគង្គ ដើម្បីផលប្រយោជន៍សេដ្ឋកិច្ច និងសង្គម ព្រមទាំងមើលឃើញផងដែរអំពីផលប៉ះពាល់នានាចំពោះបរិស្ថាន និងសង្គមដែលអាចកើតចេញពីការអភិវឌ្ឍន៍។

## ៣.២ សមិទ្ធផលសំខាន់ៗក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គដែលកម្ពុជាទទួលបានកន្លងមក

***សមិទ្ធផលរូបវ័ន្ត:***

- ធ្វើជាម្ចាស់ផ្ទះទីស្នាក់ការលេខាធិការដ្ឋាន MRC ឆ្នាំ១៩៩៨-២០០៤ (ការផ្លាស់ប្តូរវេនគ្នារៀងរាល់៥ឆ្នាំម្តង រវាងទីក្រុងភ្នំពេញ និងទីក្រុងវៀងច័ន្ទ)
- ធ្វើជាសហម្ចាស់ផ្ទះទីស្នាក់ការអចិន្ត្រៃយ៍នៃលេខាធិការដ្ឋាន MRC នៅរាជធានីភ្នំពេញ
- ធ្វើជាម្ចាស់ផ្ទះនៃមជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់នៅរាជធានីភ្នំពេញ
- តម្លើង និងដំណើរការស្ថានីយ៍ជលសាស្ត្រនៅលើទន្លេមេគង្គ ចំនួន៥ស្ថានីយ៍ និងនៅលើដៃទន្លេចំនួន ៨ស្ថានីយ៍
- កសាង និងពង្រឹងមន្ទីរពិសោធន៍គុណភាពទឹក
- ទទួលបាននូវវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប
- ទទួលបាននូវសាឡាងសម្រាប់ចំលងអ្នកដំណើរនៅអ្នកលឿងៈសាឡាងថ្មី២គ្រឿង
- សាឡាងចាស់ជួសជុល៣គ្រឿងព្រមទាំងរោងជាងសំរាប់ជួសជុលនិងតម្លើងសាឡាង០១កន្លែង
- បោះពោងសញ្ញាសុវត្ថិភាពនាវាចរណ៍តាមដងទន្លេមេគង្គ ពីកំពង់ផែស្វយ័តភ្នំពេញដល់ព្រំដែនកម្ពុជា-វៀតណាម ពីកំពង់ផែភ្នំពេញទៅទន្លេបិទខេត្តកំពង់ចាម និងពីភ្នំពេញទៅផ្លូកទ្រូ

***សមិទ្ធផលមិនរូបវ័ន្ត:***

- បង្កើតប្រព័ន្ធព័ត៌មាននៅលេខាធិការដ្ឋាន គ.ជ.ទ.ម.ក ដើម្បីចែកចាយព័ត៌មាន និងទិន្នន័យនានាដែលទាក់ទាងនឹងការគ្រប់គ្រង និងការអភិវឌ្ឍន៍អាងទន្លេមេគង្គ
- កសាង និងពង្រឹងសមត្ថភាពមន្ត្រីជំនាញតាមក្រសួង ស្ថាប័នពាក់ព័ន្ធ ទាក់ទងនឹងការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានទឹក និងជាពិសេសជំនាញផ្នែកម៉ូដែល គូរផែនទី និងប្រព័ន្ធពត៌មានភូមិសាស្ត្រ
- តាមរយៈកម្មវិធីអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញវ័យក្មេងរបស់ MRC (Junior Riparian Professional) កម្ពុជាបានពង្រឹង និងអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញវ័យក្មេងបានចំនួន ២៤រូប។ មន្ត្រីលេខាធិការដ្ឋាន គ.ជ.ទ.ម.ក ០៦រូប និងមន្ត្រី១៤រូប មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ បានទទួលសញ្ញាប័ត្រអនុបណ្ឌិត
- កសាងផែនការមេដឹកជញ្ជូនតាមផ្លូវទឹកក្នុងប្រព័ន្ធទន្លេមេគង្គកម្ពុជា

- ពង្រឹងសមត្ថភាពគ្រប់គ្រងគ្រោះទឹកជំនន់នៅក្នុងប្រទេស និងនៅតាមមូលដ្ឋាន
- បង្កើត និងធ្វើបច្ចុប្បន្នភាពផែនទីផ្លូវទឹកក្នុងដងទន្លេមេគង្គកម្ពុជា
- ធ្វើការសិក្សាបុរេសមិទ្ធលទ្ធភាពក្នុងការស្តារផ្លូវនាវាចរណ៍ពីផ្នែកទ្រូទៅសៀមរាប
- កសាងប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់កំពង់ផែស្វយ័តភ្នំពេញ
- ធ្វើការសិក្សាអំពីសណ្ឋានដី និងបរិស្ថានតំបន់ចតុមុខ
- ធ្វើការសិក្សាពីយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ធនធានធម្មជាតិរបស់អាងទន្លេសាប
- ធ្វើការសិក្សាពីគម្រោងគ្រប់គ្រងបរិស្ថានរបស់បឹងទន្លេសាប
- ធ្វើការសិក្សាគម្រោងអភិរក្សបឹងទន្លេសាប
- ធ្វើការសិក្សាពីកំណកដីល្បាប់ក្នុងបឹងទន្លេសាប
- កសាងបានឯកសារព័ត៌មានស្តីពីការសិក្សាវាយតម្លៃ និងវិភាគលើលទ្ធភាពដែលមាន និងសក្តានុពលនៃធានធានទឹក និងធនធានពាក់ព័ន្ធនៅក្នុងអនុតំបន់ និងបានលើកសំណើយុទ្ធសាស្ត្រអភិវឌ្ឍន៍នាពេលអនាគតដោយផ្អែកតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ។
- កសាងបាននូវឯកសារវាយតម្លៃសេណារីយ៉ូអភិវឌ្ឍន៍អាងទន្លេមេគង្គបានបោះពុម្ពក្នុងខែមេសា ឆ្នាំ២០១១ សេណារីយ៉ូអភិវឌ្ឍន៍បានដាក់បញ្ចូលនូវផែនការអភិវឌ្ឍន៍តាមវិស័យរបស់ប្រទេសដោយផ្តោតលើ ហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់ទឹក ការស្រោចស្រព ទំនប់វារីអគ្គិសនី និងការពារទឹកជំនន់ ដែលការអភិវឌ្ឍផ្នែកទាំងនេះមានហានីយភ័យខ្ពស់ចំពោះផលប៉ះពាល់ឆ្លងដែនសង្គមនិងបរិស្ថាន។
- កសាងផែនការចង្អុលថ្នាក់ជាតិសម្រាប់អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ទន្លេមេគង្គ។

***<u>ផលប្រយោជន៍សេដ្ឋកិច្ចៈ</u>***

- រយៈពេល៥ឆ្នាំ កន្លងមកនេះ តាមរយៈកិច្ចសហប្រតិបត្តិការក្របខ័ណ្ឌ MRC ជាមធ្យមក្នុង ០១ឆ្នាំ កម្ពុជាទទួលបានប្រយោជន៍គិតជាទឹកប្រាក់មានចំនួនប្រមាណ ២.២ លានដុល្លា នៅពេលដែលកម្ពុជាត្រូវបង់វិភាគទានប្រចាំឆ្នាំដល់ MRC ដែលមានចំនួន ៤៧៦.៧៣៤ លានដុល្លា បើគិតជាភាគរយវិញ គឺក្នុង ០១ឆ្នាំ កម្ពុជាទទួលបានប្រមាណ ១២ ភាគរយពីការចំណាយសរុបរបស់ MRC។

# ៤. សកម្មភាពការងារ និងសមិទ្ធផលផ្នែកអភិបាលកិច្ច និងតាមបណ្តា នាយកដ្ឋាន ចំណុះអគ្គលេខាធិការដ្ឋាន និងទិសដៅការងារឆ្នាំ២០១៦

## ៤.១ ផ្នែកអភិបាលកិច្ច

នៅក្នុងផ្នែកអភិបាលកិច្ចនេះមានសកម្មភាពការងារជាច្រើនបានអនុវត្ត និងសម្រេចបាននូវសមិទ្ធផលដែលឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ខ្ពស់របស់ថ្នាក់ដឹកនាំគណៈកម្មការទន្លេមេគង្គ រួមទាំងគណៈកម្មាធិការជាតិទន្លេមេគង្គនៃប្រទេសជាសមាជិក ដែលបានបង្ហាញពីវឌ្ឍនភាពលើការអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ ២០១១-២០១៥ ដើម្បីធានាឲ្យកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ត្រូវបានអនុវត្តខ្ជាប់ខ្ជួន និងផ្តល់ផ្លែផ្កាសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ឈរលើមូលដ្ឋានផលប្រយោជន៍រួម និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពរបស់អាងទន្លេមេគង្គទាំងមូល។

### ៤.១.១ ក្រុមប្រឹក្សា MRC

ក្នុងឆ្នាំ២០១៥នេះ និងតាមរយៈកិច្ចប្រជុំកិច្ចប្រជុំពេញអង្គលើកទី២២ របស់ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ (MRC Council) ដែលប្រារព្ធឡើងកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គបានពិនិត្យ និងពិភាក្សាបញ្ហាសំខាន់ៗមួយចំនួន ហើយបានឯកភាព និងអនុម័ត លើឯកសារសំខាន់ៗមួយចំនួនដូចជា៖

- ✓ ឯកភាព និងអនុម័ត លើគម្រោងថវិកាចំណាយសម្រាប់គាំទ្រដល់កិច្ចដំណើរការ MRCS ប្រចាំឆ្នាំ២០១៦។
- ✓ ឯកភាព និងអនុម័ត រូបមន្តបង់ប្រាក់វិភាគទានសម្រាប់កិច្ចដំណើរការរបស់គណៈកម្មការទន្លេមេគង្គ សម្រាប់រយៈពេល ០៣ឆ្នាំ (២០១៦-២០១៨) ដោយភាគីកម្ពុជា និង ភាគីឡាវ ត្រូវបង់ ២០% ស្មើគ្នា ហើយភាគីថៃ និងវៀតណាមត្រូវបង់ ៣០% ស្មើគ្នា។ ជារៀងរាល់ឆ្នាំបណ្តាប្រទេសជាសមាជិកត្រូវបង្កើនការបង់ ១០% នៃចំណែកបដិភាគរបស់ខ្លួន។
- ✓ ឯកភាព និងអនុម័ត លើឯកសារបទ ***បញ្ជាផ្ទៃក្នុង*** សម្រាប់ក្រុមប្រឹក្សា និងគណៈកម្មាធិការរួម ដែលបានស្នើឡើង កាលពីកិច្ចប្រជុំលើកទី១៩ របស់ក្រុមប្រឹក្សានៅឆ្នាំ២០១៣ ដើម្បីបង្កើនប្រសិទ្ធភាពអភិបាលកិច្ចរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការរួម។
- ✓ ឯកភាព និងអនុម័ត លើរចនាសម្ព័ន្ធថ្មីរបស់លេខាធិការរដ្ឋានគណៈកម្មការទន្លេមេគង្គ ដែលមានអង្គភាពចំនួន4ជាចំណុះ។
- ✓ ឯកភាព និងអនុម័ត លើឯកសារស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេទន្លេមេគង្គសម្រាប់ឆ្នាំ ២០១៦-២០២០ ។

✓ ឯកភាព និងអនុម័ត លើឯកសារស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់ឆ្នាំ ២០១៦-២០២០ និង ផែនការប្រចាំឆ្នាំ២០១៦ របស់គណៈកម្មការទន្លេមេគង្គ។




*កិច្ចប្រជុំលើកទី២២ របស់ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ (MRC Council ) និងកិច្ចប្រជុំរួមលើកទី១៩ ជាមួយដៃគូអភិវឌ្ឍន៍ប្រារព្ធឡើងកាលពី ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ នៅទីក្រុងហាណូយ វៀតណាម*




*ពិធីចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំពេញអង្គលើកទី២២របស់ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ (MRC Council ) ប្រារព្ធឡើងកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា*

បន្ទាប់ពីកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការរួម ស្តីពីគម្រោងវារីអគ្គីសនី **ដន សាហុង** នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ ដោយពុំអាចរកការឯកភាពគ្នាបាន បញ្ហាទំនប់វារីអគ្គីសនី **ដន សាហុង** ត្រូវបានបញ្ជូនទៅថ្នាក់ក្រុមប្រឹក្សាដើម្បីពិនិត្យនិងពិចារណា។ ក្រោយពីការពិគ្រោះយោបល់ក្នុងចំណោមសមាជិកក្រុមប្រឹក្សារួចមក សមាជិកក្រុមប្រឹក្សានៅរក្សាជំហរដូចដែលបានប្រកាន់យកដោយសមាជិកគណៈកម្មាធិការរួម ដោយហេតុដូចនេះនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ប្រធានក្រុមប្រឹក្សាបានផ្ញើលិខិតដល់បណ្តាសមាជិកក្រុមប្រឹក្សាដោយស្នើដាក់បញ្ហានេះជូនរដ្ឋាភិបាលរៀងៗខ្លួន ដើម្បីពិនិត្យនិងពិចារណាទៅតាមនីតិវិធីដូចដែលមានចែងក្នុងកិច្ចព្រមព្រៀមេគង្គ ឆ្នាំ១៩៩៥។ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ នៅភ្នំពេញ មានកិច្ចប្រជុំពិភាក្សាគ្នាមួយរវាងប្រតិភូកម្ពុជា និងប្រតិភូឡាវ ដើម្បីពិភាក្សាដោះស្រាយគម្រោងទំនប់វារីអគ្គិសនី **ដនសាហុង** តបតាមស្មារតីនៃជំនួបសវនាការ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា ជាមួយ **ឯកឧត្តម ស៊ុមសាវ៉ាតឡេងសាវ៉ាត ឧបនាយករដ្ឋមន្រ្តី** នៃរដ្ឋាភិបាលឡាវទទួលបន្ទុកផ្នែកសេដ្ឋកិច្ច។ តាមរយៈកិច្ចប្រជុំ ភាគីកម្ពុជាបានដាក់សំណើបង្កើតយន្តការទ្វេភាគីដែលមានសហប្រធានដោយរដ្ឋមន្រ្តីក្រសួងធនធាន និងឧតុនិយមកម្ពុជា និងរដ្ឋមន្រ្តីធនធានធម្មជាតិនិងបរិស្ថានឡាវ ដើម្បីធ្វើការសិក្សាលម្អិតមួយឲ្យបានច្បាស់លាស់អំពីផលប៉ះពាល់ឆ្លងដែនមកលើបរិស្ថាន សេដ្ឋកិច្ច និងសង្គម។ ការឆ្លើយតប ភាគីឡាវជាយល់ឃើញថា វាពុំមានការចាំបាច់ក្នុងការបង្កើតឲ្យមានជាយន្តការទ្វេភាគីទេ ដោយហេតុថាវារីអគ្គិសនី **ដនសាហុង** នឹងមិនមានផលប៉ះពាល់អ្វីទេ។ រហូតមកដល់បច្ចុប្បន្ននេះ បញ្ហាទំនប់វារីអគ្គីសនី **ដន សាហុង** ពុំទាន់ត្រូវបានដោះស្រាយនិងរកការឯកភាពរួមនៅឡើយក្នុងចំណោមបណ្តាប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ។

ក្រោយពីការជ្រើសរើសដោយគណៈកម្មាធិការរួម គឺមានតែបេក្ខជនមកពីកម្ពុជានិង វៀតណាមទេដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីកាន់តំណែងជាយកប្រតិបត្តិទីមួយ ជ្រើសចេញពីបណ្តាប្រទេសជាសមាជិក (First Riparian CEO)។ ដោយហេតុថាបណ្តាប្រទេសជាសមាជិកមិនមានការឯកភាពគ្នារវាងបេក្ខជនមកពីកម្ពុជា និងវៀតណាម ថាតើបេក្ខជនណាមួយត្រូវកាន់តំណែងជានាយកប្រតិបត្តិទីមួយ ហើយក៏ដូចជាលំដាប់តួអក្សរប្រទេសដែលត្រូវឆ្លាស់វេនក្រោយរយៈពេល ០៣ឆ្នាំ ដែលជាហេតុធ្វើអោយការការជ្រើសរើសនាយកប្រតិបត្តិទីមួយចេញពីបណ្តាប្រទេសជាសមាជិក មានការយឺតយ៉ាវ។ ប៉ុន្តែក្រោយពីមានការពិភាក្សាបន្តដោយគណៈកម្មាធិការរួម ក៏ដូចជាមានការឯកភាពពីសមាជិកក្រុមប្រឹក្សា ជាពិសេសសមាជិកក្រុមប្រឹក្សាមកពីប្រទេសថៃ ក្រុមប្រឹក្សាបានឯកភាពអោយបេក្ខជនមកពីវៀតណាមធ្វើជានាយកប្រតិបត្តិទីមួយ ហើយក្រោយរយៈពេល ០៣ឆ្នាំ គឺដល់វេនកម្ពុជាបន្ទាប់មកប្រទេសឡាវ និងចុងក្រោយគឺប្រទេសថៃ។ មកដល់បច្ចុប្បន្ននេះ នាយកប្រតិបត្តិលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គទី១ ដែលជ្រើសចេញពីបណ្តាប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ

ជាជនជាតិវៀតណាមបានចូលកាន់ដំណែងដែលមានរយៈពេល០៣ឆ្នាំ កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦។

*សម្រាប់ឆ្នាំ ២០១៦ ក្រុមប្រឹក្សា MRC មានផែនការការងាររបស់ខ្លួនរួមមាន៖*

- ពិនិត្យ និងឯកភាព លើផែនការប្រចាំឆ្នាំ២០១៧ និងគម្រោងថវិកាចំណាយសម្រាប់គាំទ្រដល់ប្រតិបត្តិការ និងកិច្ចដំណើរការ MRCS ប្រចាំឆ្នាំ២០១៧ ។
- ក្រើនរំលឹក MRCS ឲ្យប្រឹងប្រែងប្រមូលគ្រប់ធនធានពីដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញការសិក្សាស្តីពីការគ្រប់គ្រងនិងការអភិវឌ្ឍប្រកបដោយចីរភាពនៃទន្លេមេគង្គដោយរាប់បញ្ចូលទាំងផលប៉ះពាល់បង្កឡើងដោយគម្រោងវារីអគ្គីសនីនៅលើដងទន្លេមេគង្គ។
- ពិនិត្យលើវឌ្ឍនភាព នៃការអនុវត្តន៍សេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំកំពូល គណៈកម្មការទន្លេមេគង្គលើកទី១ និងលើកទី២ នៅឆ្នាំ២០១០ និងឆ្នាំ២០១៤ ដែលប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិកបានប្តេជ្ញាចិត្ត អំពីស្វ័យភាពផ្នែកហិរញ្ញវត្ថុដោយប្រទេសជាសមាជិក ត្រឹមឆ្នាំ២០៣០។ ពាក់ព័ន្ធនឹងកិច្ចការនេះ គណៈកម្មការទន្លេមេគង្គ បាននិងកំពុងពិនិត្យឡើងវិញនូវរូបមន្តនៃការបង់ភាគទាន ដើម្បីឈានដល់ការឯកភាពគ្នាមួយដែលប្រទេសជាសមាជិក ត្រូវបង់ប្រាក់ភាគទានរបស់ខ្លួន សម្រាប់កិច្ចដំណើរការរបស់គណៈកម្មការទន្លេមេគង្គ។
- ពិនិត្យលើវឌ្ឍនភាព នៃការអនុវត្តន៍រចនាសម្ព័ន្ធថ្មីរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គដែលមានអង្គភាពចំនួន៤ជាចំណុះ។
- ពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តន៍យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេទន្លេមេគង្គសម្រាប់ឆ្នាំ ២០១៦-២០២០ ។
- ពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់ឆ្នាំ២០១៦-២០២០ និង ផែនការប្រចាំឆ្នាំ២០១៦ របស់គណៈកម្មការទន្លេមេគង្គ។

## ៤.១.២ គណៈកម្មាធិការរួម MRC

ក្នុងឆ្នាំ២០១៥ កន្លងទៅនេះ គណៈកម្មាធិការរួម (Joint Committee MRC) បានដំណើរការងាររបស់ខ្លួនក្នុងការពិភាក្សាបញ្ហាសំខាន់ៗ ជាគន្លឹះទាក់ទងនឹងប្រតិបត្តិការរបស់លេខាធិការដ្ឋាន MRC ក៏ដូចជាពិនិត្យ និងអនុម័ត លើសំណើរនានារបស់លេខាធិការដ្ឋានMRC ក្នុងការងារបច្ចេកទេសលើការគ្រប់គ្រង និងអភិវឌ្ឍន៍អាងទន្លេមេគង្គ តាមរយៈសម័យប្រជុំពេញអង្គ និងវិសមញ្ញរបស់ខ្លួន។

ក្នុងឆ្នាំ២០១៥នេះ គណៈកម្មាធិការរួមបានបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ដោយមានការកោះប្រជុំវិសាមញ្ញចំនួន ០២លើក និងកិច្ចប្រជុំពេញអង្គប្រចាំឆ្នាំចំនួន ០២លើក ដើម្បីពិភាក្សានិង

ដោះស្រាយបញ្ហាសំខាន់ៗជាយុទ្ធសាស្ត្រទាក់ទងនឹងស្ថាប័ន យុទ្ធសាស្ត្រអភិវឌ្ឍ ក៏ដូចជាដំណើរការរបស់លេខាធិការដ្ឋាន MRC មុននឹងដាក់ជូនក្រុមប្រឹក្សា ពិនិត្យ និងសម្រេចឯកភាព។ តាមរយៈកិច្ចប្រជុំទាំងអស់ខាងលើនេះគណៈកម្មាធិការរួមបានពិភាក្សានិងដោះស្រាយបញ្ហាជាគន្លឹះមួយចំនួនដូចជា៖

- តាមរយៈកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការរួម ស្តីពីគម្រោងសាងសង់ទំនប់វារីអគ្គិសនី **ដន សាហុង** ដែលបានធ្វើឡើងនាថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ នៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គប្រចាំនៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ដើម្បីបូកសរុបលទ្ធផលនៃការពិគ្រោះយោបល់ជាមុន ដែលមានរយៈពេល ០៦ខែ និងការឆ្លើយតបជាផ្លូវការពីបណ្តាប្រទេសជាសមាជិកពាក់ព័ន្ធនឹងទំនប់វារីអគ្គិសនី **ដន សាហុង**។ ជាលទ្ធផលគឺភាគី កម្ពុជា ថៃ និងវៀតណាម មានជំហរប្រហាក់ប្រហែលគ្នាទាក់ទងនឹងមតិឆ្លើយតបលើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ដោយបានស្នើសុំឲ្យមានការពន្យាពេលសាងសង់ទំនប់វារីអគ្គិសនី **ដន សាហុង** ដើម្បីអនុញ្ញាតិអោយមានការសិក្សា ប្រមូលទិន្នន័យ និងព័ត៌មាន ក៏ដូចជាការវាយតម្លៃបន្ថែមទៀត។ ស្របតាមនីតិវិធីនៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ អង្គប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការរួមបានឯកភាពថា នឹងធ្វើរបាយការណ៍ដាក់ជូនក្រុមប្រឹក្សាដើម្បីពិនិត្យនិងសម្រេច មុននឹងរាយការណ៍ជូនរដ្ឋាភិបាលនៃប្រទេសជាសមាជិករៀងៗខ្លួនដើម្បីពិនិត្យនិងសម្រេច។

- ក្នុងឆ្នាំ២០១៥កន្លងទៅនេះ គណៈកម្មាធិការរួមបានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំលើកទី៤១ និងកិច្ចប្រជុំលើកទី១៩ ជាមួយដៃគូសន្ទនាដែលបានធ្វើឡើងកាលពី ថ្ងៃទី៥-៨ ខែឧសភា ឆ្នាំ២០១៥ នៅទីក្រុងសៀមរាប ប្រទេសកម្ពុជា និងកិច្ចប្រជុំប្រចាំឆ្នាំលើកទី៤២ ដែលបានធ្វើឡើងកាលពីថ្ងៃទី៩-១១ ខែកញ្ញា ឆ្នាំ២០១៥ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ តាមរយៈកិច្ចប្រជុំទាំង ០២ លើកនេះ គណៈកម្មាធិការរួមបានពិភាក្សា និងឯកភាពលើបញ្ហាមួយចំនួនដូចខាងក្រោម៖

    - ដោយអនុវត្តតាមសេចក្តីសម្រេចរបស់ MRC Council ក្នុងកិច្ចប្រជុំលើកទី២១ នៅខែមករា ឆ្នាំ២០១៥ នាទីក្រុងហាណូយ ប្រទេសវៀតណាម អង្គប្រជុំលើកទី៤២នេះបានបញ្ជាក់អះអាងជាឯកច្ឆ័ន្ទ អំពីវេនរបស់ប្រទេសជាសមាជិក ដែលត្រូវធ្វើជានាយកប្រតិបត្តិ (Chief Executive Officer) យកវេនតាមលំដាប់តួអក្សរគឺ *ទី១- វៀតណាម,ទី២-កម្ពុជា , ទី៣ - ឡាវ និង ទី៤ - ថៃ*។ ដូច្នេះគោលការណ៍នេះបានត្រូវដោះស្រាយចប់សព្វគ្រប់ មានន័យថា CEO វៀតណាមនឹងត្រូវធ្វើការចាត់តាំង ហើយនៅ០៣ឆ្នាំបន្ទាប់គឺដល់វេនប្រទេសកម្ពុជាដែលត្រូវទទួលយកប៉ុស្តិ៍ CEO ។
    - ពិនិត្យ និងជ្រាបអំពីស្ថានភាពថវិកា និងវឌ្ឍភាពនៃការអនុវត្តកម្មវិធីនានារបស់គណៈកម្មការទន្លេមេគង្គ គិតពី ខែមករា ដល់ខែកក្កដា ឆ្នាំ២០១៥ ដែលបាននិងកំពុងដំណើរការល្អជាធម្មតា។

- ពិនិត្យ និងជ្រាបអំពីរបាយការណ៍ស្តីពីថវិកាចំណូល-ចំណាយ សម្រាប់ដំណើរការលេខាធិការដ្ឋាន (Operating Expenses Budget) គិតពី ខែមករា ដល់ខែកក្កដា ឆ្នាំ២០១៥ និងបានឯកភាពលើសំណើកែសម្រួលថវិកាថ្មី សម្រាប់រយៈពេលនៅសល់ដល់ចុង ឆ្នាំ២០១៥។
- ពិនិត្យ និងជ្រាបអំពីវឌ្ឍភាពនៃការសិក្សារបស់ក្រុមប្រឹក្សា (Council Study) ហើយបានស្នើឲ្យលេខាធិការដ្ឋានរៀបចំរបាយការណ៍បណ្តោះអាសន្នមួយ ដើម្បីផ្សព្វផ្សាយលទ្ធផលសិក្សាឲ្យបានទូលំទូលាយដល់បណ្តាភាគីពាក់ព័ន្ធដទៃទៀត ក៏ដូចជាប្រឹងប្រែងរកថវិកាបង្គ្រប់សម្រាប់ការសិក្សានេះ។
- ពិភាក្សា និងឯកភាពលើចំណុចមួយចំនួនដែលនៅសេសសល់ស្តីពីការកែសម្រួល ***បទបញ្ជាផ្ទៃក្នុង***របស់គណៈកម្មាធិការរួមនិងក្រុមប្រឹក្សា ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។
- ពិភាក្សា និងឯកភាពលើរចនាសម្ពន្ធ័ថ្មីរបស់លេខាធិការដ្ឋាន MRC ដែលមានត្រឹមតែ ៤អង្គភាព (4 Units) ដោយពុំចាំបាច់មានជាក្រុមប្រឹក្សាភិបាល (Advisory Board) ទេ។ ប្រទេសនីមួយៗ នឹងមានឱកាសទទួលបានតួនាទីជាប្រធានអង្គភាពមួយ ដែលតួនាទីនេះ នឹងត្រូវធ្វើការជ្រើសរើសដោយឈរលើលក្ខណៈសម្បត្តិ និងសមត្ថភាពជំនាញ។
- ពិភាក្សា និងឯកភាពឲ្យមានរយៈពេលអន្តរកាលចំនួន ០៦ខែ មុននឹងឈានទៅអនុវត្តរចនាសម្ព័ន្ធថ្មីរបស់លេខាធិការដ្ឋាន MRC ដោយរក្សាទុកតែបុគ្គលិកសំខាន់ៗ ប្រមាណជា១០០នាក់ ឲ្យនៅធ្វើការបន្តក្រោមកិច្ចសន្យាសេវាកម្មបណ្តោះអាសន្ន (Service Contract) ចាប់ពីដើមខែមករា រហូតដល់ចុងខែមិថុនា ឆ្នាំ២០១៦ ទន្ទឹមនឹងការជ្រើសរើសបុគ្គលិកថ្មីស្របតាមរចនាសម្ព័ន្ធថ្មី ដើម្បីធ្វើការងារបន្តចាប់ពី ដើមខែកក្កដា ឆ្នាំ២០១៦។
- ពិភាក្សា និងឯកភាពលើការបង្កើតកញ្ចប់ថវិការួម (MRC Basket Fund) ដែលត្រូវអនុវត្តចាប់ពី ដើមឆ្នាំ ២០១៦ បានន័យថា ថវិកាជំនួយដែលប្រមូលបានពីដៃគូអភិវឌ្ឍន៍នានា និងថវិការបស់ប្រទេសជាសមាជិកនឹងដាក់ចូលរួមគ្នា និងប្រើសម្រាប់រាល់ការចំណាយទូទៅ ដោយមិនប្រកាន់ និងសម្រាប់ការងារណាដែលជាអាទិភាព។
- ប្រទេស កម្ពុជា ឡាវ និងវៀតណាម បានឯកភាពលើសំណើសុំប្រើប្រាស់រូបមន្តបង់វិភាគទានបច្ចុប្បន្ន សម្រាប់ឆ្នាំ២០១៦ទៀត ហើយស្នើឲ្យភាគីថៃ ផ្តល់ការឯកភាពរបស់ខ្លួនឲ្យបានឆាប់។ រូបមន្តសម្រាប់ការបង់ថវិកាវិភាគទានពីប្រទេសជាសមាជិកចូល MRC មិនទាន់បានឯកភាពគ្នានៅឡើយ។
- ពិនិត្យ ពិភាក្សា និងឯកភាព លើឯកសារយុទ្ធសាស្រ្តអភិវឌ្ឍន៍អាងទន្លេមេគង្គ ឆ្នាំ២០១៦-២០២០ (Basin Development Strategy) និងផែនការយុទ្ធសាស្រ្តគណៈកម្មការទន្លេមេគង្គឆ្នាំ២០១៦-២០២០ (MRC Strategic Plan) ដាក់ជូនក្រុមប្រឹក្សាអនុម័ត។

- ពិនិត្យ ពិភាក្សា និងជ្រាបនូវរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីនានារបស់គណៈកម្មការទន្លេមេគង្គនិងបានណែនាំឲ្យមានការពន្លឿនការងារនេះបានទាន់ពេលវេលាមុនដំណាច់ឆ្នាំ២០១៥។




*កិច្ចប្រជុំប្រចាំឆ្នាំលើកទី៤១ របស់គណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ (MRC Joint Committee) ប្រារព្ធឡើងកាលពី ថ្ងៃទី៥-៨ ខែឧសភា ឆ្នាំ២០១៥ នៅទីក្រុងសៀមរាប ប្រទេសកម្ពុជា*

ក្នុងឆ្នាំ២០១៥ នេះ ក្រុមការងារគណៈកម្មាធិការរួម (Joint Committee Task Force) បានបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ដោយមានការជួបប្រជុំគ្នាចំនួន ០៣លើក (ទី២៦ ទី២៧ និងទី២៨) ដើម្បីពិភាក្សា និងដោះស្រាយបញ្ហាសំខាន់ៗជាយុទ្ធសាស្ត្រទាក់ទាងនឹងស្ថាប័ន យុទ្ធសាស្ត្រអភិវឌ្ឍ ក៏ដូចជាដំណើរការរបស់លេខាធិការដ្ឋាន MRC មុននឹងដាក់ជូនគណៈកម្មាធិការរួម ពិនិត្យ និងសម្រេច។ តាមរយៈកិច្ចប្រជុំខាងលើនេះក្រុមការងារគណៈកម្មាធិការរួម បានពិភាក្សា និងដោះស្រាយបញ្ហាសំខាន់ៗដូចខាងក្រោម៖

- សម្រាំងជ្រើសរើសបេក្ខជននាយកប្រតិបត្តិទីមួយ (First MRC Riparian CEO) ដើម្បីឈានទៅដល់ដំណាក់កាលធ្វើសម្ភាសន៏។ ជាលទ្ធផល ក្រុមការងារគណៈកម្មាធិការរួមបានឯកភាពសម្រេចជ្រើសរើសបេក្ខជនដែលមានសក្តានុពលចំនួន ០៦ រូប ដើម្បីឆ្លងកាត់ដំណាក់កាលចុងក្រោយគឺ ការសម្ភាសន៏ដោយសមាសជិកគណៈកម្មាធិការរួមនៅ ថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១៥ នៅលេខាធិការដ្ឋាន MRC ប្រចាំទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ ដោយហេតុថាពុំអាចរកការ

ឯកភាពគ្នាបានលើបញ្ជីចំណាត់ថ្នាក់រួម សមាជិកក្រុមគណៈកម្មការធ្វើសម្ភាសន៍មកពីវៀតណាម បានយកមាត្រាទី៣៣ នៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ មកនិយាយហើយស្នើសុំលើកយកបញ្ហានេះទៅពិភាក្សាក្នុងអំឡុងកិច្ចប្រជុំពិសេសរបស់គណៈកម្មាធិការរួម។

- *កញ្ចប់ថវិការួម* *(MRC Basket Fund)* *និង* *លក្ខខណ្ឌការងាររបស់គណៈកម្មាធិការថវិកា* *(TOR of Budget Committee)* - ពិនិត្យ និងពិភាក្សាលើ សមាសភាព តួនាទីនិងការទទួលខុសត្រូវ ការរៀបចំកិច្ចប្រជុំ ការពិនិត្យមើលផែនការប្រចាំឆ្នាំនិងការអនុម័តថវិការបស់ គណៈកម្មាធិការថវិកា។ សមាសភាពគណៈកម្មាធិការថវិការដែលសមាជិករួមមាន៖ ០១រូប មកពីបណ្តាប្រទេសជាសមាជិក (ថ្នាក់សមាជិកបំរុងគណៈកម្មាធិការរួម ឬអគ្គនាយករង) ប្រធានប្រតិបត្តិ MRCS តំណាងដៃគូរអភិវឌ្ឍន៍ចំនួន ០២រូប និងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុជាលេខាធិការ។ មន្ត្រីសង្កេតការណ៍រួមមាន៖ ប្រធានអង្គភាពទាំង៤ តំណាងដៃគូរអភិវឌ្ឍន៍ចំនួន ០១រូប និង ជំនួយការបច្ចេកទេស ០១រូប មកពីបណ្តាប្រទេសជាសមាជិក។
- *ការកែទំរង់រចនាសម្ព័ន្ធរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ* *(MRCS Restructure)* ពិភាក្សា និងឯកភាពអោយមានអង្គភាព ចំនួន០៤ រួមមាន៖ ១- អង្គភាពសេវាកម្ម (Corporate Services Unit) ដែលត្រូវបំពេញមុខងារផ្នែក រដ្ឋបាល-ហិរញ្ញវត្ថុ-បុគ្គលិក ២- អង្គភាពផែនការ (Planning Unit) ៣-អង្គភាពគ្រប់គ្រងបរិស្ថាន (Environmental Management Unit) និង ៤-អង្គភាពគាំទ្របច្ចេកទេស (Technical Support Unit)។ ចំណែមុខងារទាក់ទងនឹងអភិបាលកិច្ច និងសហប្រតិបត្តការ អង្គប្រជុំបានស្នើរអោយ MRCS សិក្សាបន្ថែមដើម្បីបែងចែកមុខងារទាំងពីរទាក់ទងនឹងអភិបាលកិច្ច និងសហប្រតិបត្តការអោយនៅក្រោមអង្គភាពផែនការខ្លះ និងក្រោមការិយាល័យរបស់ CEO ខ្លះ (Office of CEO) ដើម្បីដាក់ឆ្លង JC ពិនិត្យ និងសម្រេចនាកិច្ចប្រជុំត្រៀមរបស់ខ្លួនមុនកិច្ចប្រជុំលើកទី២២ របស់ MRC Council។ ចំពោះការបែងចែកអង្គភាពទាំង៤អោយទៅប្រទេសនិមួយៗ គឺស្នើរអោយប្រើប្រាស់គោលការណ៍ប្តូរវេនបច្ចុប្បន្ន តែភាគីថៃស្នើរផ្តល់អាទិភាពដល់ប្រទេសដែលត្រូវធ្វើ CEO ក្រោយគេធ្វើការជ្រើសរើសមុន។
- *កំរិតប្រាក់បៀវត្សរ៍ថ្មីរបស់មន្ត្រី* *MRCS ( New Salary Scale)* - កត់ត្រានូវពត៌មានដែលបានបង្ហាញដោយ MRCS ហើយបានស្នើរអោយ MRCS សិក្សាបន្ថែមទៅលើការកាត់បន្ថយថែមទៀតនូវរាល់ការចំណាយផ្សេងៗដែល *MRCS* ត្រូវបង់អោយបណ្តាបុគ្គលិក ក្រៅពីប្រាក់ខែស្នូល ដើម្បីដាក់ជូន JC ពិនិត្យ និងសម្រេចនាកិច្ចប្រជុំត្រៀមរបស់ខ្លួនមុនកិច្ចប្រជុំលើកទី២២ របស់ MRC Council។
- *ការធ្វើជាម្ចាស់ផ្ទះរបស់លេខាធិការដ្ឋាន* *MRC* *និង* *ការសិក្សាពីទីតាំងមួយ និងពីរ របស់លេខាធិការដ្ឋាន* *MRC* - MRCS បានបង្ហាញថា បើលេខាធិការដ្ឋាន MRC មានតែមួយនោះ MRC អាចសន្សំថវិកាបានប្រហែល ១៩៥.០០០ ដុល្លារ/ឆ្នាំ លើការចំណាយសម្រាប់បុគ្គលិក និងប្រហែល ៤២៤.០០០ដុល្លារ/ឆ្នាំ លើការចំណាយសម្រាប់ប្រតិបត្តិការលេខាធិការដ្ឋាន។ ជា

រួមមិនមានការខុសគ្នាធំដុំលើការចំណាយទេ រវាងការតាំងទីលេខាធិការដ្ឋាន MRC នៅភ្នំពេញ ឬ វៀងច័ន្ទ (កម្ពុជាលើសឡាវប្រហែល ៤.០០០ដុល្លារ)។ ក្រុមការងារគណៈកម្មាធិការរួមបាន ស្នើរអោយ MRCS សិក្សាបន្ថែម ដោយឡើងជាផែនទីបង្ហាញផ្លូវដើម្បីដាក់ជូន JC ពិនិត្យនិង សម្រេចនាកិច្ចប្រជុំត្រៀមរបស់ខ្លួនមុនកិច្ចប្រជុំលើកទី២២ របស់ MRC Council។

*សម្រាប់ឆ្នាំ ២០១៦ គណៈកម្មាធិការរួម MRC នឹងបន្តអនុវត្តផែនការការងាររបស់ខ្លួនរួមមានៈ*

- ពិនិត្យនិងអនុម័តលើផែនការប្រចាំឆ្នាំ២០១៧និងគម្រោងថវិកាចំណាយសម្រាប់គាំទ្រដល់ប្រតិបត្តិការ និងកិច្ចដំណើរការ MRCS ប្រចាំឆ្នាំ២០១៧ ។
- ក្រើនរំលឹក MRCS ឲ្យប្រឹងប្រែងប្រមូលគ្រប់ធនធានពីដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញការសិក្សាស្តីពីការគ្រប់គ្រងនិងការអភិវឌ្ឍប្រកបដោយចីរភាពនៃទន្លេមេគង្គដោយរាប់បញ្ចូលទាំងផលប៉ះពាល់បង្កឡើងដោយគម្រោងវារីអគ្គីសនីនៅលើដងទន្លេមេគង្គ។
- ពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តសេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី១ និងលើកទី២ នៅឆ្នាំ២០១០ និងឆ្នាំ២០១៤ ដែលប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិកបានប្តេជ្ញាចិត្តអំពីស្វ័យភាពផ្នែកហិរញ្ញវត្ថុដោយប្រទេសជាសមាជិកត្រឹមឆ្នាំ២០៣០។ ពាក់ព័ន្ធនឹងកិច្ចការនេះ គណៈកម្មការទន្លេមេគង្គបាននិងកំពុងពិនិត្យឡើងវិញនូវរូបមន្តនៃការបង់ភាគទាន ដើម្បីឈានដល់ការឯកភាពគ្នាមួយដែលប្រទេសជាសមាជិកត្រូវបង់ប្រាក់ភាគទានរបស់ខ្លួនសម្រាប់កិច្ចដំណើរការរបស់គណៈកម្មការទន្លេមេគង្គ។
- ពិនិត្យ ពិចារណា ដើម្បីឈានដល់ការឯកភាព និងអនុម័តលើចំនួននិងសមាសភាព កំរិតកាំប្រាក់បៀវត្សរ៍ និងកញ្ចប់អត្ថប្រយោជន៍នានាសម្រាប់បុគ្គលិកបំរើការរចនាសម្ព័ន្ធថ្មីរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។
- ពិនិត្យនិងតាមដានការអនុវត្តន៍រចនាសម្ព័ន្ធថ្មីរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គដែលមានអង្គភាពចំនួន៤ជាចំណុះ។
- ពិនិត្យនិងតាមដានការអនុវត្តយុទ្ធសាស្រ្តអភិវឌ្ឍន៍អាងទន្លេទន្លេមេគង្គសម្រាប់ឆ្នាំ ២០១៦-២០២០ ។
- ពិនិត្យនិងតាមដានការអនុវត្តន៍ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សម្រាប់ឆ្នាំ ២០១៦-២០២០ និង ផែនការប្រចាំឆ្នាំ២០១៦ របស់គណៈកម្មការទន្លេមេគង្គ។

## ៤.១.៣ សមិទ្ធផលការងារទូទៅ

ក្នុងឆ្នាំ២០១៥ កន្លងទៅនេះក្រៅពីការងារអភិបាលកិច្ចក្របខណ្ឌគណៈកម្មការទន្លេមេគង្គ អគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក បានចូលរួមកិច្ចប្រជុំក៏ដូចជាផ្លាស់ប្តូរមតិយោបល់ជាមួយដៃគូសហប្រតិបត្តិការដទៃទៀត ដើម្បីពង្រឹងសមត្ថភាព និងកិច្ចសហប្រតិបត្តិការ រួមមានៈ

- ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពី កិច្ចការទូតផ្នែកទឹកៈ ច្បាប់ទឹកអន្តរជាតិ និងកិច្ចសហប្រតិបត្តិការតំបន់ កាលពីថ្ងៃទី២៧-២៨ ខែមេសា ឆ្នាំ២០១៥ នៅទីក្រុងសៀមរាប និង ថ្ងៃទី២១-២២ ខែកញ្ញា ឆ្នាំ២០១៥ នៅទីក្រុងភ្នំពេញ ដែលបានរៀបចំដោយ IUCN ក្រោមគម្រោង BRIDGE ដើម្បីបង្កើនការយល់ដឹងអំពីខ្លឹមសារនៃ UN Water Convention 1997, ការបំពេញបន្ថែមទៅលើកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការតំបន់មេគង្គ និងទន្លេអន្តរជាតិ និងដើម្បីត្រៀមខ្លួនចូលជាសមាជិក UNWC។
- ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ ស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មក្នុងតំបន់ដែលបានរៀបចំដោយក្រសួងសាធារណការនិងដឹកជញ្ជូនកាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ និងថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០១៥។ ក្រុមការងារមានភារកិច្ច ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ធ្វើការសម្របសម្រួល និងពិភាក្សាជាមួយប្រទេសដៃគូផ្តល់ជំនួយនានា លើកិច្ចការគម្រោងហេដ្ឋារចនាសម្ពន្ធ័ក្នុងប្រទេស។គោលបំណងនៃកិច្ចប្រជុំរៀងរាល់៣ខែម្តងគឺដើម្បីរាយការណ៍អំពីការគាំទ្ររបស់ម្ចាស់ជំនួយលើគម្រោងដែលបានដាក់ស្នើសុំថវិការបស់ក្រសួងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ, រាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តគម្រោង និងចំណុចប្រឈមមួយចំនួន និងមានវិធានការដោះស្រាយស្រប។ ក្រុមការងារមានភារកិច្ចក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ធ្វើការសម្របសម្រួល និងពិភាក្សាជាមួយប្រទេសដៃគូផ្តល់ជំនួយនានា លើកិច្ចការគម្រោងហេដ្ឋារចនាសម្ពន្ធ័ក្នុងប្រទេស។
- ចូលរួមពិធីសម្ពោធ អាគារស្រាវជ្រាវ របស់ជប៉ុននៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥។ អគារស្រាវជ្រាវ ដែលជាជំនួយរបស់ប្រទេសជប៉ុនត្រូវបានសម្ពោធដាក់អោយប្រើប្រាស់ ក្រោមអធិបតីភាពរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា។
- ចូលរួមកិច្ចប្រជុំលើកទី១៤ នៃគណៈកម្មការចម្រុះ កម្ពុជា វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា កាលពីថ្ងៃទី១៧-១៩ ខែតុលា ឆ្នាំ២០១៥ នៅទីក្រុងហូជីមិញ។ ជាកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំប្រចាំឆ្នាំ ថ្នាក់រដ្ឋមន្ត្រីការបរទេស នៃប្រទេសទាំងពីរ ដើម្បីពិនិត្យមើលវឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការលើគ្រប់វិសយ័ ផ្អែកតាមកំណត់ហេតុនៃកិច្ចប្រជុំ។

- ចូលរួមវេទិកាមហាតំបន់មេគង្គស្តីពីទឹក ស្បៀង និងថាមពល កាលពីថ្ងៃទី ២១-២៣ ខែតុលា ឆ្នាំ២០១៥ នៅភ្នំពេញ ដែលបានរៀបចំដោយ CGIAR ដើម្បីពិភាក្សា ផ្សព្វផ្សាយលទ្ធផលសិក្សាស្រាវជ្រាវ និងបង្កើនកិច្ចសហការណ៍ក្នុងតំបន់មេគង្គលើ វិសយ័ទឹក ស្បៀង និងថាមពល នៃបណ្តាប្រទេសនៅក្នុងតំបន់មេគង្គ និងមានការចូលរួមដោយអង្គការសង្គមស៊ីវិលស្ថាប័នរដ្ឋ ស្ថាប័នសិក្សាស្រាវជ្រាវនានា។
- ចូលរួមកិច្ចប្រជុំត្រៀមស្តីពីកិច្ចសហប្រតិបត្តិការមេគង្គ-ឡានសាងកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីពិភាក្សាអំពី Concept Note ស្តីពីការបង្កើតយន្តការ មេគង្គ-ឡានសាង ការលើកគម្រោងសហប្រតិបត្តិការជាមួយភាគីចិន ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេស មេគង្គ-ឡានសាង

- MRC។ អង្គសិក្ខាសាលាក៏បានជ្រាបពីសារៈសំខាន់នៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ នីតិវិធីទាំង ៥ ព្រមទាំងចំណុចខ្វះខាតនិងការលំបាកមួយចំនួនក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ និងការកំណែទម្រង់រចនាសម្ព័ន្ធនិងហិរញ្ញវត្ថុរបស់ *MRC*។

# ៤.២ សកម្មភាពការងារ និងសមិទ្ធផលតាមបណ្តានាយកដ្ឋាន

## ៤.២.១ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

សមិទ្ធផលសកម្មភាពការងារដែលនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនិងកម្មវិធីការងារវិមជ្ឈការមុខងារស្នូលក្នុងការគ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គសម្រាប់កម្ពុជាអនុវត្តបានក្នុងឆ្នាំ២០១៥ មានដូចខាងក្រោម៖

### ក.ការងារស្នូលរបស់នាយកដ្ឋាន

**ក.១ ការងាររដ្ឋបាលទូទៅ**

- បានទទួល និងកត់ត្រាចូលលិខិត ចំនួន ៧០២
- បានបញ្ជូនលិខិត និងទូរសារចេញ ចំនួន ១១៦៤
- សម្របសម្រួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានចំនួន ២៣លើក
- សម្របសម្រួលនិងរៀបចំទទួលជួបពិភាក្សាការងារជាមួយភ្ញៀវជាតិចំនួន១២លើក និងជាមួយភ្ញៀវអន្តរជាតិចំនួន ៨លើក
- សម្របសម្រួលរៀបចំបោះពុម្ពផ្សព្វផ្សាយទស្សនាវដ្តីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ចំនួន០២លេខ៖ លេខ១ ត្រីមាសទី2 ឆ្នាំ២០១៤ និងលេខ២ ឆមាសទី២ ឆ្នាំ២០១៤ សរុបចំនួន ៤៥០ក្បាល ហើយបានចែកជូន ២៣ ក្រសួង-ស្ថាប័នជាតិពាក់ព័ន្ធ អស់ចំនួន ៣២០ក្បាល។
- សម្របសម្រួលការចូលរួមរបស់គណៈប្រតិភូក្រុមប្រឹក្សាកម្ពុជាក្នុងកិច្ចប្រជុំលើកទី២១ របស់ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ និងកិច្ចប្រជុំរួមលើកទី១៩ ជាមួយដៃគូអភិវឌ្ឍន៍នាថ្ងៃទី១៥-១៦ ខែមករា ឆ្នាំ២០១៥ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។
- សម្របសម្រួលការរៀបចំ និងចូលរួមរបស់គណៈប្រតិភូគណៈកម្មាធិការរួមកម្ពុជាក្នុងកិច្ចប្រជុំលើកទី ៤១ របស់គណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ និងកិច្ចប្រជុំលើកទី១៩ ជាមួយប្រទេសដៃគូសន្ទនា (ចិន-មីយ៉ាន់ម៉ា) នាថ្ងៃទី៥-៨ ខែឧសភា ឆ្នាំ២០១៥ នៅទីក្រុងសៀមរាប។
- សម្របសម្រួលការចូលរួមរបស់គណៈប្រតិភូគណៈកម្មាធិការរួមកម្ពុជាក្នុងកិច្ចប្រជុំលើកទី៤២ របស់គណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គនាថ្ងៃទី៩-១១ ខែកញ្ញា ឆ្នាំ២០១៥ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។
- សម្របសម្រួលការចូលរួមរបស់គណៈប្រតិភូតំណាងគណៈកម្មាធិការរួមកម្ពុជាក្នុងកិច្ចប្រជុំលើកទី ២៦ លើកទី២៧ និងលើកទី២៨ របស់ក្រុមការងារបច្ចេកទេសគណៈកម្មាធិការរួម (MRC Joint

Committee Task Force) និងកិច្ចប្រជុំគណៈកម្មាធិការថវិកា (Budget Committee) ដែលបានរៀបចំឡើងដោយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។

### គ.២. ការងារហិរញ្ញវត្ថុ

នៅក្នុងឆ្នាំ២០១៥ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានទទួលថវិកាជាតិដែលបានអនុម័តសរុបចំនួន ***២,៧៥០,០០០,០០០ រៀល*** ហើយដែលត្រូវចំណាយសម្រាប់ទ្រទ្រង់ដំណើរការអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ចំនួន ៧៥០,០០០,០០០ រៀល និងសម្រាប់បង់ភាគទានជូនគណៈកម្មការទន្លេមេគង្គសម្រាប់ឆ្នាំ២០១៥ ចំនួន ២,០០០,០០០,០០០ រៀល។

## ខ. កម្មវិធីការងារវិមជ្ឈការមុខងារស្នូលគ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គសម្រាប់កម្ពុជា

កម្មវិធីវិមជ្ឈការមុខងារស្នូលនៃគ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គសម្រាប់កម្ពុជា (Core River Basin Management Functions-CRBMF) ជាកម្មវិធីមួយក្នុងចំណោមកម្មវិធីទាំង១២ របស់គណៈកម្មការទន្លេមេគង្គដែលបានចាប់ផ្ដើមអនុវត្តជំហានដំបូងចាប់តាំងពីចុងឆ្នាំ២០១១ ដល់ឆ្នាំ២០១៥ ក្រោមការគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ GIZ ប្រទេសអាល្លឺម៉ង់។ កម្មវិធីវិមជ្ឈការមុខងារស្នូលនេះគឺរៀបចំដំណើរការវិមជ្ឈការមុខងារស្នូល នៃការគ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គ ដោយក្នុងនោះសម្រាប់កម្ពុជាបានរៀបចំនូវផែនទីបង្ហាញផ្លូវថ្នាក់ជាតិ សម្រាប់ការអនុវត្តសកម្មភាពដែលត្រូវធ្វើវិមជ្ឈការក្នុងឆ្នាំ២០១១-២០១៥ឆ្នាំ២០១៦-២០២០ និងឆ្នាំ២០២១-២០២៥។
សកម្មភាពការងារអនុវត្តបានរួមមាន៖

### ខ.១ ការចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាថ្នាក់តំបន់នានាពាក់ព័ន្ធនឹងកម្មវិធី

- ចូលរួមកិច្ចប្រជុំសម្របសម្រួលថ្នាក់តំបន់នាថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ ដែលបានរៀបចំដោយគណៈកម្មការទន្លេមេគង្គលើការងារវិមជ្ឈការមុខងារស្នូល ក្នុងការគ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គនៅទីក្រុងហូជីមិញ ប្រទេសវៀតណាម។ កិច្ចប្រជុំនេះផ្ដោតលើ៖ (១) ការពិភាក្សាអំពីបញ្ហាសម្របសម្រួលក្នុងគម្រោង (២) ផែនការការងារនិងសកម្មភាពពីខែមិថុនាដល់ខែធ្នូ ឆ្នាំ២០១៥ និង (៣) ធ្វើបច្ចុប្បន្នភាពអំពីការរីកចម្រើនបញ្ហាសេសសល់ និងបញ្ហាប្រឈមនៃសកម្មភាពក្នុងកញ្ចប់ទី១ និងបញ្ហាសកម្មភាពដែលបានស្នើសុំសម្រាប់កញ្ចប់ទី២។ បញ្ហាទាក់ទងនឹងថវិកា អង្គប្រជុំជ្រាបថាចាប់ពីឆ្នាំ២០១៦ទៅរាល់សកម្មភាពវិមជ្ឈការក្នុងកញ្ចប់ទី២នឹងត្រូវរ៉ាប់រងចំណាយដោយប្រទេសជាសមាជិក (ឬតាមរយៈជំនួយទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍)លើសកម្មភាពប្រតិបត្តិនិងកិច្ចការទាក់ទងនឹងការសម្របសម្រួល។ អង្គប្រជុំបានឯកភាពថា រាល់សកម្មភាពការងារវិមជ្ឈការ ដែលទាក់ទងនឹងកម្មវិធីណាមួយគប្បី

ឲ្យមន្ត្រីសម្របសម្រួលថ្នាក់ជាតិនៃកម្មវិធីនោះទទួលខុសត្រូវ ចំពោះការរៀបចំដោយពិភាក្សាជាមួយមន្ត្រីសម្របសម្រួលថ្នាក់ជាតិនៃការងារវិមជ្ឈការមុខងារស្នូល។

- ចូលរួមកិច្ចប្រជុំថ្នាក់តំបន់ដែលមានមន្ត្រីកម្ពុជា១០រូបដឹកនាំដោយ ឯកឧត្តម អាន ពេជ្រហត្ថដា អគ្គលេខាធិការរង គ.ជ.ទ.ម.ក នាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ នៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ នាទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ដែលរៀបចំដោយគណៈកម្មការទន្លេមេគង្គ។ កិច្ចប្រជុំនេះផ្តោតលើការយល់ដឹងនិងឯកភាពរួមគ្នារវាងប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ និងលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គលើៈ (១) វឌ្ឍនភាពនៃដំណើការវិមជ្ឈការនៃសកម្មភាពកញ្ចប់ទី១ និង (២) សំណើសកម្មភាពសម្រាប់ធ្វើវិមជ្ឈការកញ្ចប់សកម្មភាពទី២ក្នុងឆ្នាំ២០១៦-២០២០។ អង្គប្រជុំបានទទួលយកសំណើរបស់កម្ពុជា និងឡាវ ដែលបានស្នើសកម្មភាព *__១.១.២ ការត្រួតពិនិត្យកម្ពស់ទឹក និងកម្ពស់ទឹកភ្លៀងទាន់ពេលវេលា__* ដើម្បីដាក់បញ្ចូលទៅក្នុងកញ្ចប់សកម្មភាពទី២ ដោយសារប្រទេសទាំង២ពុំទានមានលទ្ធភាពពេញលេញក្នុងការអនុវត្តកម្មភាពនេះក្នុងដំណាក់កាលឆ្នាំ២០១១-២០១៥ នៃកញ្ចប់សកម្មភាពទី១ និងអង្គប្រជុំបានឯកភាពជាគោលការណ៍លើសំណើរបស់ MRCS នូវសកម្មភាពមួយចំនួននៅក្នុងកញ្ចប់សកម្មភាពទី១ ដែលត្រូវបន្តធ្វើវិមជ្ឈការក្នុងកញ្ចប់សកម្មភាពទី២ ឆ្នាំ២០១៦-២០២០។
- ចូលរួមកិច្ចប្រជុំថ្នាក់តំបន់ដែលមានមន្ត្រីកម្ពុជាចំនួន០៧រូបដឹកនាំដោយ ឯកឧត្តម អាន ពេជ្រហត្ថដា អគ្គលេខាធិការរង នាថ្ងៃទី០៧ និងទី០៨ ខែកក្កដា ឆ្នាំ២០១៥ នៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គនាទីក្រុងភ្នំពេញ។ កិច្ចប្រជុំនេះផ្តោតលើការពិភាក្សា ការពិនិត្យមើលឡើងវិញនូវសកម្មភាពនៃមុខងារស្នូលដែលនឹងត្រូវធ្វើមជ្ឈការ និងទិដ្ឋភាពបច្ចេកទេសនៃសកម្មភាពទាំងនេះ។

## ខ.២ ការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានា

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីរៀបចំកញ្ចប់សកម្មភាពវិមជ្ឈការទី២ក្នុងឆ្នាំ ២០១៦-២០២០ នាថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥នៅសណ្ឋាគារភ្នំប្រុស ក្រុងកំពង់ចាម។ មានសមាជិកក្រុមការងារបច្ចេកទេសនៃវិមជ្ឈការមុខងារស្នូលក្នុងក្របខណ្ឌគណៈកម្មការទន្លេមេគង្គសម្រាប់កម្ពុជាមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ មន្ត្រីមកពីលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ និងមន្ត្រីអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាសរុបចំនួន ៣៥រូប។ សិក្ខាសាលានេះ បាននិត្យ និងពិភាក្សាឡើងវិញលើមុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គសម្រាប់រៀបចំកញ្ចប់សកម្មភាពវិមជ្ឈការទី២ក្នុងឆ្នាំ០១៦-២០២០។



*សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិដើម្បីរៀបចំកញ្ចប់សកម្មភាពវិមជ្ឈការទី២ ឆ្នាំ២០១៦-២០២០ នាថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ សណ្ឋាគារភ្នំប្រុស ក្រុងកំពង់ចាម*

- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិដើម្បីរៀបចំផែនការវិមជ្ឈការកញ្ចប់សកម្មភាពទី២ សម្រាប់ឆ្នាំ២០១៦-២០២០នៅក្រុងព្រះសីហនុដោយមានការចូលរួមពីមន្ត្រីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធការអនុវត្តន៍វិមជ្ឈការមុខងារស្នូលក្នុងការគ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេ មេគង្គ និងមន្ត្រីមកពីលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គសរុបចំនួន ២៧រូប។





*កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិដើម្បីរៀបចំផែនការវិមជ្ឈការកញ្ចប់សកម្មភាពទី២សម្រាប់ ឆ្នាំ ២០១៦-២០២០ ក្រុងព្រះសីហនុ នាថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥*

ឯកសារសំខាន់ៗ ដែលសម្របសម្រួលរៀបចំផលិតឡើងដោយកម្មវិធីវិមជ្ឈការមុខងារស្នូលមាន៖

- ផែនទីបង្ហាញផ្លូវថ្នាក់ជាតិសម្រាប់មុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេដើម្បីអនុវត្តវិមជ្ឈការគណៈកម្មការទន្លេមេគង្គខែមិថុនា ឆ្នាំ២០១៣ ( Khmer and English )។
- បច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវថ្នាក់ជាតិសម្រាប់មុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេដើម្បីអនុវត្តវិមជ្ឈការគណៈកម្មការទន្លេមេគង្គ។

ការអនុវត្តការងាររដ្ឋបាលទូទៅដំណើការជាធម្មតា។ ចំណែកការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់បានដំណើរការតាមប្រតិទិនការងារ និងដោះស្រាយតម្រូវការរបស់អង្គភាពក្រោមឱវាទជាធម្មតា។ ចំពោះសកម្មភាពអនុវត្តការងារវិមជ្ឈការមុខងារស្នូលក្នុងការគ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គសម្រាប់កម្ពុជា គឺដំណើរការតាមផែនការសកម្មភាពរបស់ខ្លួន។

## ៤.២.២ នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

សកម្មភាព និងលទ្ធផលការងារដែលបានអនុវត្តក្នុងឆ្នាំ២០១៥ របស់នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស មានដូចខាងក្រោម ៖

- បានរៀបចំសំណុំឯកសារផ្ទេរក្របខណ្ឌជូនលោក ឈុន តារា ពីមន្ត្រីក្រសួងបរិស្ថាន មកបំរើការងារនៅអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ក្នុងក្របខណ្ឌក្រសួងធនធានទឹក និងឧតុនិយម ដោយចាត់ឲ្យទៅបម្រើការងារនៅក្នុងនាយកដ្ឋានគ្រប់គ្រងព័ត៌មាន និងចំណេះដឹង។
- បានបំពេញតារាងពិពណ៌នាមុខតំណែងនិងរចនាសម្ព័ន្ធមុខតំណែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បញ្ជូនទៅក្រសួងធនធានទឹកនិងឧតុនិយម។
- ស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការចំនួន០៩រូបនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាសម្រាប់ឆ្នាំ២០១៥។
- រៀបចំឯកសារបច្ចុប្បន្នភាពកាំប្រាក់បៀវត្ស, គ្រឿងឥស្សរិយយសរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគណៈកម្មាធិការជាតិទន្លេមេគង្គម្ពុជាសម្រាប់ឆ្នាំ២០១៥ ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច។
- បានសម្របសម្រួលរៀបចំលិខិតឆ្លើយតបទៅនឹងសំណើររបស់គណៈកម្មការទន្លេមេគង្គ ស្តីពីការពន្យាកិច្ចសន្យា និងការបញ្ចប់ការងាររបស់បុគ្គលិកកម្ពុជាដែលបម្រើការងារនៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ចំនួន១២រូប។
- រៀបចំរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ២០១៥ ស្តីពីវត្តមាននិងអវត្តមានរបស់មន្ត្រីរាជការនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងមានវិធានការ។

ក្រៅពីសកម្មភាពទូទៅ នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៏ធនធានមនុស្សក៏បានទទួលខុសត្រូវក្នុងការអនុវត្តន៍កម្មវិធីកសាងសមត្ថភាពចម្រុះ (Integrated Capacity Building Programme – ICBP) របស់គណៈកម្មការទន្លេមេគង្គ ហើយទទួលបានលទ្ធផល ដូចខាងក្រោម ៖

- បានចូលរួមកិច្ចប្រជុំលើកទី១០ របស់គណៈកម្មាធិការដឹកនាំកម្មវិធីកសាងសមត្ថភាពចម្រុះ នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៥ នៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ កិច្ចប្រជុំនេះផ្តោតការពិភាក្សាលើរបាយការណ៏វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកសាងសមត្ថភាពចម្រុះចាប់តាំងពីបានឯកភាពលើឯកសារកម្មវិធីរយៈពេល២ឆ្នាំ បន្តរហូតដល់ខែតុលាឆ្នាំ២០១៥(២០១៤-២០១៥)និងបានឯកភាពឲ្យអនុវត្តផែនការសកម្មភាពសំខាន់ៗក្នុងឆ្នាំ២០១៥។




*កិច្ចប្រជុំថ្នាក់តំបន់លើកទៅ១០ របស់គណៈកម្មាធិការដឹកនាំកម្មវិធីកសាងសមត្ថភាពចម្រុះ នៅលេខាធិការដ្ឋាន MRC ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ នាថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៥*

- បានចូលរួមកិច្ចប្រជុំលើកទី១១ របស់គណៈកម្មាធិការដឹកនាំកម្មវិធីកសាងសមត្ថភាពចម្រុះ នាថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៥ នៅទៅក្រុងបាងកក ប្រទេសថៃ។ កិច្ចប្រជុំបានពិភាក្សា និងផ្តល់ជាអនុសាសន៏បន្ថែមលើឯកសារព្រាងសំខាន់ចំនួន០២ គឺ(១)របាយការណ៏វាយតម្លៃបញ្ចប់គម្រោងកម្មសិក្សាសម្រាប់មន្ត្រីវ័យក្មេង (Junior Riparian Professionals - JRPs) និង (២)របាយការណ៏វាយតម្លៃបញ្ចប់កម្មវិធីកសាងសមត្ថភាពចម្រុះ (ICBP) ។ របាយការណ៏ទាំងពីររៀបចំឡើងដោយក្រុមទីប្រឹក្សាអន្តរជាតិឯករាជ្យ។ កិច្ចប្រជុំនេះក៏បានឯកភាពផងដែរលើការអនុវត្តន៍ផែនការសកម្មភាពកសាងសមត្ថភាពជាអាទិភាពក្នុងឆ្នាំ២០១៦។

*កិច្ចប្រជុំថ្នាក់តំបន់លើកទៅ១១ របស់គណៈកម្មាធិការដឹកនាំកម្មវិធីកសាងសមត្ថភាពចម្រុះ នៅទីក្រុងបាងកក ប្រទេសថៃ នាថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៥*



- បានរៀបចំសិក្ខាសាលាអបអរសាទរ និងចូលរួមសំដែងមតិចំពោះខួបអនុស្សាវរីយ៍លើកទី ១០៤ ទិវានារីអន្តរជាតិ៨ មីនា ឆ្នាំ២០១៥ នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៥ នៅសណ្ឋាគារភ្នំប្រុស ក្រុងកំពង់ចាម ដែលមានមន្ត្រីទទួលបន្ទុកការងារយេនឌ័រមកពីបណ្តាក្រសួង-ស្ថាប័នជាសមាជិកនិង មន្ត្រីអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាសរុបចំនួន៣៥នាក់។ ព្រឹត្តិការណ៍នេះ គឺជារំលឹកអំពីកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នជាសមាជិករយៈពេល១៨ឆ្នាំដែលក្រសួង-ស្ថាប័នជាសមាជិកបានចូលរួមនិងបន្តជួយលើកកំពស់ទស្សនៈយេនឌ័រនិងការបញ្ជ្រាបយេនឌ័រទៅក្នុងការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានទឹកនៅអាងទន្លេមេគង្គ



*សិក្ខាសាលាអបអរទិវានារីអន្តរជាតិ ៥មីនា ឆ្នាំ២០១៥ សណ្ឋាគារភ្នំប្រុស ខេត្តកំពង់-ចាម នាថ្ងៃទី៦ ខែមិនា ឆ្នាំ២០១៥*

- បានរៀបចំសិក្ខាសាលាវាយតម្លៃគម្រោងបណ្តុះបណ្តាលមន្ត្រីជំនាញវ័យក្មេងរបស់គណៈកម្មការទន្លេមេគង្គ នាថ្ងៃទី៣០-៣១ ខែមីនា ឆ្នាំ២០១៥ នៅសណ្ឋាគារភ្នំប្រុស ក្រុងកំពង់ចាម។ មានការចូលរួមពីមន្ត្រីទទួលបន្ទុក HRDមកពីក្រសូង-ស្ថាប័នជាសមាជិកអតីតមន្ត្រីជំនាញវ័យក្មេងដែលធ្លាប់បំពេញកម្មសិក្សានៅលេខាធិការដ្ឋាន MRC សរុបចំនួន៣៥រូប។ សិក្ខាសាលានេះបានពិភាក្សាផ្លាស់ប្តូរយោបល់ ដើម្បីឱ្យក្រុមការងារវាយតម្លៃគម្រោង JRP ប្រមូលអនុសាសន៍ពីអង្គសិក្ខាសាលាសម្រាប់ជាសូចនាករអនុវត្តសកម្មភាពគម្រោង JRP នាថ្ងៃអនាគត។



***សិក្ខាសាលាស្តីពីការវាយតម្លៃវឌ្ឍនភាពគម្រោងបណ្តុះបណ្តាលមន្ត្រីជំនាញវ័យក្មេងរបស់ MRC នា ថ្ងៃទី៣០-៣១ ខែមីនា ឆ្នាំ២០១៥ សណ្ឋាគារភ្នំប្រុស ទីក្រុងកំពង់ចាម***

- បានរៀបចំសិក្ខាសាលាស្តីពីការចែករំលែកចំណេះដឹងលើការបញ្ជ្រាបយេនឌ័ក្នុងការគ្រប់គ្រងធនធានទឹកចម្រុះ IWRM នាថ្ងៃទី២៧-២៨ ខែមេសា ឆ្នាំ២០១៥ នៅសណ្ឋាគារភ្នំប្រុសក្រុងកំពង់ចាមដោយមានការចូលរួមពីមន្ត្រីទទួលបន្ទុកការងារយេនឌ័រមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងមន្ត្រី គ.ជ.ទ.ម. សរុបចំនួន៣០រូប។ សិក្ខាសាលាបានជម្រាបជូនពីលទ្ធផលនៃការអនុវត្តន៍សកម្មភាពបញ្ជ្រាបយេនឌ័ររបស់កម្មវិធីកសាងសមត្ថភាពចម្រុះរបស់ គ.ជ.ទ.ម.ក ក្នុងឆ្នាំ ២០១១-២០១៥ និងផ្តល់វេទិការចែករំលែកចំណេះដឹង មេរៀនបទពិសោធន៍ ដែលទទួលបានពីការអនុវតន៍ការងារបញ្ជ្រាបយេនឌ័រក្នុង IWRM នៅតាមវិស័យពីអ្នកពាក់ព័ន្ធ និងទទួលយកអនុសាសន៍ពីអ្នកចូលរួម។



*សិក្ខាសាលាស្តីពីការចែករំលែកចំណេះដឹងលើការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងធនធានទឹករបស់ MRC នាថ្ងៃទី២៧-២៨ ខែមេសា ឆ្នាំ២០១៥ សណ្ឋាគារភ្នំប្រុស ទីក្រុងកំពង់ចាម*

- បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិស្តីពីការប្រើប្រាស់ម៉ូដែល e-Water Source របស់ប្រទេសអូស្ត្រាលី នាថ្ងៃទី២០-២៣ ខែកក្កដា ឆ្នាំ២០១៥ នៅសណ្ឋាគារភ្នំប្រុស ទីក្រុងកំពង់ចាម។ សិក្ខាសាលាបណ្តុះបណ្តាលនេះរៀបចំដោយសហការជាមួយកម្មវិធីគ្រប់គ្រងព័ត៌-មាននិងចំណេះដឹងដោយមានការចូលរួមពីមន្ត្រីជំនាញម៉ូដែលមកពីក្រសួងស្ថាប័នពាក់ព័ន្ធសរុបចំនួន៣០នាក់។ សិក្ខាសាលានេះក៏បានផ្តល់ចំណេះដឹងបន្ថែមក្នុងការប្រើប្រាស់ម៉ូដែលថ្មី e-Water Source របស់ប្រទេសអូស្ត្រាលីដែលជាឧបករណ៍បច្ចេកទេសវាយតម្លៃបម្រែបម្រួលជលសាស្ត្រក្នុងអាងទន្លេមេគង្គប្រកបដោយបច្ចេកទេសវិទ្យាសាស្ត្រកំរិតខ្ពស់និងអាចជួយបំពេញបន្ថែមជាមួយម៉ូដែលដែលមានស្រាប់ដូចជា SWAT, IQQM, ISIS, របស់ MRC។



*សិក្ខាសាលាស្តីពីការពីការប្រើប្រាស់ម៉ូដែល e-Water Source នាថ្ងៃទី២០-២៣ ខែកក្កដា ឆ្នាំ ២០១៥ សណ្ឋាគារភ្នំប្រុស ទីក្រុកំពង់ចាម*

- បានរៀបចំសិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពីជំនាញសរសេរ លិខិតឆ្លើយឆ្លង របាយការណ៍ និងកំណត់ហេតុអង្គប្រជុំ នាថ្ងៃទី១៨-២០ ខែសីហា ឆ្នាំ២០១៥ នៅសណ្ឋាគារសោម៉ាទេវី ទីក្រុងសៀមរាប ដោយមានសិក្ខាកាមចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធសរុបចំនួន ៣០នាក់។ សិក្ខាសាលាបានផ្ដល់ចំណេះដឹងបន្ថែមក្នុងការសរសេរ លិខិតឆ្លើយឆ្លង របាយការណ៍ និងកំណត់ហេតុប្រជុំ និងផ្ដល់ផងដែរសមត្ថភាពជំនាញរបៀបដឹកនាំអង្គប្រជុំ ធ្វើកំណត់ហេតុប្រជុំ និងរបាយការណ៍ជូនថ្នាក់ដឹកនាំអង្គភាព និងស្ថាប័ន។



*សិក្ខាសាលាស្ដីពីជំនាញសរសេរ លិខិត របាយការណ៍ និង កំណត់ហេតុអង្គប្រជុំ នាថ្ងៃទី១៨-២០ ខែសីហា ឆ្នាំ២០១៥ សណ្ឋាគារសោម៉ាទេវី ទីក្រុងសៀមរាប*

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពីវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ និងនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គនាថ្ងៃទី៥-៧ ខែតុលា ឆ្នាំ២០១៥ សណ្ឋាគារសោម៉ាទេវី ទីក្រុងសៀមរាប ដោយមានការសិក្ខាកាមចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធសរុបចំនួន២៧នាក់។ សិក្ខាសាលាបានផ្សព្វផ្សាយជូនពីវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ រួមទាំងការវិវត្តន៍នៃការអនុវត្តនីតិវិធីពាក់ព័ន្ធនានារបស់ MRC ក្នុងពេលកន្លងមកដើម្បីលើកកំពស់ការយល់ដឹងពីការអនុវត្តកិច្ចព្រមព្រៀងមេគង្គនិងនីតិវិធីទាំងប្រាំរួមមាន៖ ១.នីតិវិធីចែករំលែកទិន្នន័យនិងព័ត៌មាន ២. នីតិវិធីត្រួតពិនិត្យការប្រើប្រាស់ទឹក ៣. នីតិវិធីស្ដីពីការជូនដំណឹង ពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង ៤. នីតិវិធីរក្សាលំហូរទឹកតាមដងទន្លេមេ និង ៥. នីតិវិធីស្ដីពីគុណភាពទឹកនិងបានបង្ហាញជូនពីមេរៀនបទពិសោធន៍ក្នុងដំណើរការអនុវត្តកិច្ចព្រមព្រៀងនិងនីតិវិធីខាងលើរួមទាំងការលំបាកនិងភាពងាយស្រួលក្នុងក្របខ័ណ្ឌជាតិ និងតំបន់។



*សិក្ខាសាលាផ្សព្វផ្សាយស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍កិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ និងបណ្តានីតិវិធីទាំង ៥ របស់គណៈកម្មការទន្លេមេគង្គ នាថ្ងៃទី១៨-២០ ខែសីហា ឆ្នាំ២០១៥សណ្ឋាគារសោម៉ាទេវី ទីក្រុងសៀមរាប*

- បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់សំណុំឧបករណ៍យេនឌ័រថ្មីរបស់គណៈកម្មការទន្លេមេគង្គ នាថ្ងៃទី៣-៥ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅសណ្ឋាគារសោមាទេវីអង្គ ខេត្តសៀមរាប។ សិក្ខាកាម អញ្ជើញចូលរួមជាមន្ត្រីទទួលបន្ទុកការងារយេនឌ័រមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានចំនួន៣៥រូប។ សិក្ខាសាលានេះបានផ្សព្វផ្សាយណែនាំពីគោលគំនិត និងវិធីសាស្ត្រប្រើប្រាស់សំណុំឧបករណ៍យេនឌ័រថ្មីរបស់គណៈកម្មការទន្លេមេគង្គដល់មន្ត្រីទទួលបន្ទុកការងារយេនឌ័រនៅក្រសួង ស្ថាប័នពាក់ព័ន្ធ។




*សិក្ខាសាលាផ្សព្វផ្សាយស្តីពីការប្រើប្រាស់សំណុំឧបករណ៍យេនឌ័រថ្មីរបស់គណៈកម្មការទន្លេមេគង្គ នាថ្ងៃទី៣-៥ ខែវិច្ឆិកា ឆ្នាំ២០១៥ សណ្ឋាគារសោម៉ាទេវី ទីក្រុងសៀមរាប*

- បានទៅចូលរួមក្នុងវេទិកាទឹកពិភពលោកលើកទី៧ នាថ្ងៃទី១២-១៧ ខែមេសា ឆ្នាំ២០១៥ នៅទីក្រុងដាហ្គូ សាធារណៈរដ្ឋកូរ៉េ។ សមាសភាពប្រតិភូរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងក្រសួងធនធានទឹកនិងឧតុនិយម ដែលចូលរួមវេទិកានេះ រួមមាន៖ ឯ.ឧ តែ ណាវុធ អគ្គលេខាធិការ គជទមក លោក ម៉ៅ ហាក់ អគ្គនាយករងកិច្ចការបច្ចេកទេសនៃក្រសួង ធទឧ លោក យិន សាវុធ ប្រធាននាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ នៃធទឧ លោក ហ៊ីង ស៊ុនថាន ប្រធាននាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក នៃធទឧ លោក ហាក់ សុជាតិ មន្ត្រីសម្របសម្រួលកម្មវិធី FMMP លោក សុខ ខុម មន្ត្រីសម្របសម្រួលកម្មវិធីជលផល និងលោក អ៊ូ សុជាណា មន្ត្រីសម្របសម្រួលកម្មវិធី ICBP ។




*គណៈប្រតិភូកម្ពុជា ចូលរួមវេទិកាទឹកពិភពលោកលើកទី៧ នៅទីក្រុងដាហ្គូ សាធារណៈរដ្ឋកូរ៉េ*
*នាថ្ងៃទី១២-១៧ ខែមេសា ឆ្នាំ២០១៥*

- បានសម្របសម្រួលបញ្ជូនមន្ត្រី០១ រូប គឺលោក ឈុន តារា មកពីក្រសួងបរិស្ថានទៅចូលរួមគម្រោងកម្មសិក្សាមន្ត្រីវ័យក្មេងរបស់គណៈកម្មការទន្លេមេគង្គជំនាន់ទី១១ចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៥ រហូតដល់ពីថ្ងៃទី30 ខែវិច្ឆិកា ឆ្នាំ២០១៥ លើជំនាញបណ្តុះបណ្តាលផ្នែកការគ្រប់គ្រងគ្រោះរាំងស្ងួត។

ឯកសារសំខាន់ៗ ដែលសម្របសម្រួលរៀបចំផលិតឡើងដោយកម្មវិធី ICBP៖

1- កម្មវិធីអនុវត្តការងារ ICBP ឆ្នាំ2014-2015
2- គោលការណ៍ណែនាំសម្រាប់ការកសាងសមត្ថភាព ឆ្នាំ2015
3- សៀវភៅអនុវត្ត MRC យេនឌ័រ ជាភាសាខ្មែរនិងអង់គ្លេសភាគទី 1,2,3
4- គោលការណ៍ណែនាំសម្រាប់បញ្ជូនមន្ត្រីទៅបំរើការនៅលេខាធិការដ្ឋាន MRC ឆ្នាំ 2015
5- គោលការណ៍ណែនាំសម្រាប់ការផ្ទេរជំនាញនិងចំណេះដឹង ឆ្នាំ2015 (ពង្រាង)
6- ក្របខ័ណ្ឌពង្រឹងសមត្ថភាព 2015 (ពង្រាង)
7- ក្របខ័ណ្ឌត្រួតពិនិត្យនិងវាយតម្លៃ (ឆ្នាំ2014-2015)

**បញ្ហាប្រឈម**

- នៅមានការខ្វះខាតសំភារៈប្រើប្រាស់មួយចំនួនដូចជាៈ ម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនព្រីន ស្គេន និង ម៉ាស៊ីនថតចម្លង
- នៅមានការខ្វះខាតបុគ្គលិកនៅថ្នាក់ការិយាល័យសម្រាប់សម្របសម្រួលជួយការងាររដ្ឋបាល និងជំនាញផ្សេងៗ។
- ភាពមិនប្រាកដប្រជារបស់ផ្នែកកសាងសម្ថភាពនៅក្នុរចនាសម្ព័ន្ធថ្មីរបស់លេខាធិការរដ្ឋាន MRC និងកង្វះខាតថវិកាសម្រាប់ការអនុវត្តន៍សម្មភាពការងារទាក់ទងនឹងការបណ្តុះបណ្តាល និងពង្រឹងសម្ថភាព

**ទិសដៅអនុវត្តក្នុងឆ្នាំ២០១៦**

- រៀបចំឯកសារបច្ចុប្បន្នភាពកាំប្យៀវត្ស, គ្រឿងឥស្សរិយយសរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ គណៈកម្មាធិការជាតិទន្លេមេគង្គម្ពុជាសម្រាប់ឆ្នាំ២០១៦
- រៀបចំឯកសារក្របខ័ណ្ឌមន្ត្រីរាជការ, មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតនៃគណៈកម្មាធិការ ជាតិទន្លេមេគង្គកម្ពុជាសម្រាប់ឆ្នាំ២០១៦ និងផែនការឆ្នាំ២០១៧ ដើម្បីដាក់ជូនថ្នាក់ដឹកនាំ ពិនិត្យ និងសម្រេច
- រៀបចំផែនការបណ្តុះបណ្តាលធនធានមន្ត្រីរាជការ និងបុគ្គលិករបស់គណៈកម្មាធិការជាតិទន្លេ មេគង្គកម្ពុជា សម្រាប់ឆ្នាំ២០១៦ ដល់២០២០។
- រួមជាមួយលេខាធិការរដ្ឋាន MRC បង្កើតឡើងនូវព័ត៌មាននិងទិន្នន័យគោល (Baseline Data/Information) សម្រាប់ប្រើប្រាស់ក្នុងការវាយតម្លៃការបណ្តុះបណ្តាល និងពង្រឹងសម្ថភាព របស់ប្រទេសជាសមាជិកនាពេលអនាគត។
- ផ្តោតការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពទាក់ទងនឹង៖ ជំនាញដឹកនាំនិងគ្រប់គ្រង ជំនាញចរចារនិងគ្រប់គ្រងជម្លោះ ការអនុវត្តន៍កិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥និងបណ្តានីតិវិធី ទាំង៥។

## ៤.២.៣ នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ

នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ មានកម្មវិធីធំៗចំនួន០២ ស្ថិតក្នុងក្របខ័ណ្ឌគណៈ កម្មការទន្លេមេគង្គ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ផ្សេងៗទៀតដែលស្ថិតនៅក្រោមការ ទទួលខុសត្រូវរបស់នាយកដ្ឋាននេះ រួមមាន៖

១. កម្មវិធីផែនការអភិវឌ្ឍន៍អាងទន្លេ

២. កម្មវិធីគ្រប់គ្រងធនធានទឹកចម្រុះមេគង្គ

## ១ កម្មវិធីផែនការអភិវឌ្ឍន៍អាងទន្លេ

### សមិទ្ធផលសំខាន់ៗដែលសម្រេចបាន ៖

- **ការរៀបចំផែនការ**

***ការអនុវត្តផែនការសកម្មភាពអាង* (Basin Action Plan)**

- ការរអនុវត្តផែនការសកម្មភាពអាងបានបញ្ចប់ និងបានសម្រេចលទ្ធផលតាមផែនការ។
- ដំណើរការជឿនលឿនគឺ ៩០% នៃការងារត្រូវបានអនុវត្ត។
- ការអនុវត្តផែនការចង្កុលថ្នាក់ជាតិ២០១១-២០១៥ ក៏ត្រូវបានបញ្ចប់ដែរ។ គម្រោង២៩ ដែលបានលើកឡើង មានតែគម្រោងមួយទេដែលទទួលបានថវិកាអនុវត្ត។
- ភាពប្រឈមទូទៅ ជាពិសេសចំពោះកម្ពុជា គឺកង្វះថវិការសម្រាប់អនុវត្តគម្រោងដែលបានស្នើឡើង។ ក្រុមការងារនឹងខិតខំរៀបចំគម្រោងឲ្យបានល្អជាងមុន។

***ការវាយតម្លៃសេណារីយ៉ូ* (Scenario Assessment)**

- ការងារត្រូវបានបញ្ចប់ និងសម្រេចបានលទ្ធផលដោយមានការផ្លាស់ប្តូរតិចតួច។
- របាយការណ៍វាយតម្លៃសេណាណារីយ៉ូ ត្រូវបានរៀបចំ ធ្វើការពិនិត្យឡើងវិញ និងបានបញ្ចប់ដែលនឹងត្រូវចែកចាយទៅតាមក្រសួងស្ថាប័ន។
- បានរៀបចំរបាយការណ៍ស្តីពីវិធីសាស្រ្តសម្រាប់ការសិក្សារបស់ក្រុមប្រឹក្សា លើការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ (Council Study)។
- ភាពប្រឈមទូទៅ គឺប្រសិទ្ធិភាពនៃម៉ូឌែល និងវិធីសាស្រ្តវាយតម្លៃ ព្រមទាំងគុណភាព និងភាពជឿជាក់នៃលទ្ធផលសម្រេច។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ ក្នុងពេលអនាគតយើងមានតម្រូវការពង្រឹងសមត្ថភាពបច្ចេកទេសក្នុងការប្រើប្រាស់ម៉ូឌែល ក៏ដូចជាក្នុងការត្រួតពិនិត្យប្រសិទ្ធិភាពនៃលទ្ធផល។

***ជម្រើសនៃវិធីចែករំលែកផលប្រយោជន៍ថ្នាក់តំបន់* (Regional Benefit Sharing Options)**

- ការងារត្រូវបានបញ្ចប់និងសម្រេចបានលទ្ធផលមួយកម្រិត។
- របាយការណ៍បញ្ចប់និងកូនសៀវភៅសង្ខេបត្រូវបានរៀបចំហើយ។
- ភាពប្រឈមនៃការងារនេះគឺយើងគ្រាន់តែបានទទួលគំនិត ប៉ុន្តែមិនដឹងថាអនុវត្តជាក់ស្តែងយ៉ាងណានោះទេ។ ដើម្បីដោះស្រាយបញ្ហានេះយើងត្រូវការអនុវត្តជាកស្តែងដើម្បីរៀនសូត្របទពិសោធន៍។

***បច្ចុប្បន្នកម្មនៃយុទ្ធសាស្រ្តអភិវឌ្ឍន៍អាង* (Basin Development Strategy Updated)**

- ការងារត្រូវបានបញ្ចប់ជាស្ថាពរ និងសម្រេចបានលទ្ធផលតាមផែនការ។

- បច្ចុប្បន្នកម្មនៃយុទ្ធសាស្រ្តអភិវឌ្ឍន៍អាងទន្លេបានបញ្ចប់ គណៈកម្មាធិការរួមបានឯកភាពលើឯកសារនេះ ហើយក្រុមប្រឹក្សាក៏បានអនុម័តដើម្បីយកទៅអនុវត្តផងដែរ ។
- ក្រុមការងារ BDP បានរួមចំណែកដល់ការរៀបចំផែនការយុទ្ធសាស្រ្តគណៈកម្មការទន្លេមេគង្គ ២០១៦-២០២០ ដែលបានបញ្ចប់ និងឯកភាពដោយគណៈកម្មាធិការរួ ហើយត្រូវបានអនុម័តដោយក្រុមប្រឹក្សា។
- ភាពប្រឈមនៃការងារនេះគឺកង្វះថវិការសម្រាប់អនុវត្តសកម្មភាពការងារ ដោយសារការធ្វើវិមជ្ឈការ។

***នីតិវិធីនៃការរក្សាលំហូរជារទឹកលើទន្លេមេ (PMFM)***

- ការងារត្រូវបានបញ្ចប់និងសម្រេចបានលទ្ធផលមួយចំនួន។
- របាយការណ៍អនុវត្ត PMFM 2011-2015 (របាយការណ៍បឋមបានរៀបចំរួច និងបានពិនិត្យឡើងវិញនៅថ្នាក់ជាតិ។ របាយការណ៍បញ្ចប់ត្រូវបានរៀបចំបន្ទាប់ពីបញ្ចប់កិច្ចពិភាក្សាថ្នាក់ជាតិទាំងអស់ដោយក្រុមការងារតំបន់
- គេហទំព័រ PMFM ត្រូវបានដំណើរការ
- គោលការណ៍ណែនាំបច្ចេកទេសត្រូវបានធ្វើបច្ចុប្បន្នកម្ម
- ប៉ុន្តែយើងមានភាពប្រឈមលើចំណុចមួយចំនួនដូចជា៖
    - ✓ ការអនុវត្តអោយបានត្រឹមត្រូវនៃនីតិវិធីប្រើប្រាស់និងគ្រប់គ្រងធនធានទឹក ក៏ដូចជាកង្វះទិន្នន័យនៃប្រតិបត្តិការទំនប់វារីអគ្គិសនី នៅកន្លែងទឹកធ្លាក់នៃទន្លេឡានសាងប្រទេសចិន។
    - ✓ យើងមិនទាន់អាចអនុវត្តជាក់ស្តែងនូវវិធានរក្សា real time flows បាននៅពេលដែលកម្រិតលំហូរ threshold ទាបជាងកម្រិត PMFM។
    - ✓ កង្វះអ្នកបច្ចេកទេសឆ្នើមដើម្បីបន្តដំណើរកា ការងារ PMFM នៅ MRCS និងនៅថ្នាក់ជាតិ បានរារាំងដល់ការបញ្ចប់ និងការអនុម័តគោលការណ៍ណែនាំបច្ចេកទេសនៃនីតិវិធីនេះ។
- យើងនៅមានបញ្ហាដែលមិនទាន់ដាច់ស្រេចដូចជា៖
    - ✓ ការឯកភាពគ្នារវាងប្រទេសទាំងបួនលើលំហូរអប្បបរមាសម្រាប់មាត្រាទី៦A ដើម្បីរៀបចំផែនការ។
    - ✓ បញ្ហាសេសសល់ផ្សេងទៀតមាន៖ និយមន័យ (Working Definition) នៃរដូវវស្សា និងរដូវប្រាំង។ សម្រាប់គោលបំណង PMFM: រដូវវស្សាចាប់ផ្តើមពីខែមិថុនាដល់ខែវិច្ឆិកា ឯរដូវប្រាំងពីខែធ្នូដល់ខែឧសភា ក៏ដូចជាការបង្ហាញឲ្យច្បាស់លាស់អំពីទិន្នន័យនៃលំហូរសម្រាប់ស្ថានីយ៍ដែលរងឥទ្ធិពលដោយទឹកជោរនាចដូចជាស្ថានីយតាន់ចូវ។

- ការគាំទ្រដល់ Council Study និងនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA)
- ការងារនិងលទ្ធផលបានសម្រេចមួយចំនួន និងមានការងារមួយចំនួនទៀតកំពុងនឹងត្រូវអនុវត្តបញ្ចប់។
- ក្រុមការងារតំបន់បានរៀបចំរបាយការណ៍ដូចខាងក្រោមសម្រាប់ការសិក្សារបស់ក្រុមប្រឹក្សាដែលកំពុងរៀបចំពិនិត្យ ដោយថ្នាក់ជាតិ និងពិគ្រោះយោបល់ថ្នាក់តំបន់ (ថ្ងៃទី១៥-១៩កុម្ភៈ ២០១៦)៖
  - ✓ របាយការណ៍ស្តីពីការបង្កើត និងការវាយតំលៃសេណារីយ៉ូសម្រាប់ការសិក្សារបស់ក្រុមប្រឹក្សា
  - ✓ កំណត់ត្រាបឋមស្តីពីរបបជលសាស្ត្រនិងការអភិវឌ្ឍសម្រាប់ការសិក្សារបស់ក្រុមប្រឹក្សា
  - ✓ របាយការណ៍ពីវិធីសាស្ត្រសម្រាប់វាយតម្លៃសង្គម
  - ✓ របាយការណ៍ពីវិធីសាស្ត្រសម្រាប់វាយតម្លៃសេដ្ឋកិច្ច
  - ✓ របាយការណ៍ពីវិធីសាស្ត្រសម្រាប់វាយតម្លៃផលប៉ះពាល់រួមនៃសេណារីយ៉ូ ដែលរួមបញ្ចូលទាំងសង្គមសេដ្ឋកិច្ចនិងបរិស្ថាន

- **ចំណេះដឹង (Knowledge)**

***ព័ន្ធទិន្នន័យសេដ្ឋកិច្ចសង្គម (Socio-economic database)***

- ការងាររៀបចំប្រព័ន្ធទិន្នន័យសេដ្ឋកិច្ចសង្គមបានបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០១៥។
- របាយការណ៍ប្រព័ន្ធទិន្នន័យសេដ្ឋកិច្ចសង្គមសម្រាប់ BDP របស់គណៈកម្មការទន្លេមេគង្គបានបញ្ចប់និងផ្សព្វផ្សាយ។
- ភាពប្រឈមនៅក្នុងការងារនេះគឺកង្វះទិន្នន័យសេដ្ឋកិច្ចសង្គមមួយចំនួនដែលទាក់ទងនឹងវិស័យនានា។

***សូចនាករ សេដ្ឋកិច្ច សង្គម និងបរិស្ថាន (Economic, social and environmental indicators)***

- ការងាររៀបចំសូចនាករសេដ្ឋកិច្ចសង្គមបានបញ្ចប់។
- សេចក្តីព្រាងឯកសារក្របខ័ណ្ឌសូចនាកររបស់គណៈកម្មការទន្លេមេគង្គត្រូវបានបញ្ចប់ និងបានចែកចាយនៅក្នុងខែធ្នូ ២០១៥/ មករា២០១៦។
- ភាពប្រឈមដែលបានជួបប្រទះគឺពេលអនុវត្តជាក់ស្តែងអាចមានការលំបាកក្នុងការរកទិន្នន័យសម្រាប់សូចនាករមួយចំនួន។

***ប្រព័ន្ធទិន្ន័យគម្រោង (Project Master Database)***

- លទ្ធផលនៃការងាររៀបចំប្រព័ន្ធទិន្ន័យគម្រោងមិនបានបញ្ចប់ឡើយ។

- របាយការណ៍អំពីលទ្ធភាពបង្កើតប្រព័ន្ធទិន្នន័យត្រូវបានរៀបចំរួចរាល់។
- មានឯកសារយោងមួយដែលអាចប្រើក្នុងពេលរៀបចំផែនការយុទ្ធសាស្ត្របន្ទាប់ សម្រាប់បង្កើត និងថែរក្សាប្រព័ន្ធទិន្នន័យ។

***ការគាំទ្រដល់ការរៀបចំរបាយការណ៍ស្ថានភាពអាង (Support to State of the Basin Report)***

- ការងារបានមកដល់ទីបញ្ចប់ជាមួយនឹងលទ្ធផល៖
  - ✓ ផែនទីអាងត្រូវបានបោះពុម្ពរួច និងផ្សព្វផ្សាយ។
  - ✓ របាយការណ៍ស្តីពីនិន្នាការអភិវឌ្ឍន៍ ទស្សនវិស័យ ( ទំហំ 300 ទំព័រ ត្រូវបានបញ្ចប់ និងចែកចាយ )។
  - ✓ គំនិត និងមាតិកាសម្រាប់ SOB ឆ្នាំ២០១៨ បានរៀបចំរួចរាល់។
  - ✓ ក្រុមការងារក៏បានរួមចំណែកដល់ការត្រៀមរៀបចំរបាយការណ៍ SOB ឆ្នាំ ២០១៥។

- **ការចូលរួម (Participation)**

***យន្តការស្ថាប័នក្នុងការគាំទ្រការរៀបចំផែនការអាងទន្លេ***

- ការងារដើម្បីសម្រេចលទ្ធផលនេះត្រូវបានបញ្ចប់។
- របាយការណ៍ស្តីពីក្រុមការងារត្រូវបានរៀបចំ និងបានពិនិត្យនៅដើមឆ្នាំ២០១៥។
- ភាពប្រឈមរបស់យើងគឺយន្តការជាតិដើម្បីសម្របសម្រួលនឹងវិមជ្ឈការ ថវិកា និងកំណែទម្រង់ MRC ទៅអនាគត។

***ដំណើរការពិភាក្សាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដើម្បីរៀបចំផែនការអាង***

- ការងារនេះបានចប់សព្វគ្រប់។
- របាយការណ៍ BDP Forum បានបញ្ចប់និងចែកជូនប្រទេសនៅដើមឆ្នាំ២០១៥នេះ។

***ជួយគាំទ្រដល់ដំណើរការវិមជ្ឈការ (Support to decentralization process)***

- បានបញ្ចប់ការងារ និងលទ្ធផលត្រូវបានសម្រេចតាមផែនការ
- គោលការណ៍ណែនាំសម្រាប់រៀបចំ NIP បានរៀបចំរួចរាល់
- ភាពប្រឈមរបស់យើងគឺកង្វះថវិកាសម្រាប់អនុវត្ត NIP

- **ការអភិវឌ្ឍន៍សមត្ថភាព និងសមត្ថភាពដើម្បីអនុវត្ត NIP**

***កម្មវិធីបណ្តុះបណ្តាល (Training Modules )***

- ការងារបានបញ្ចប់ លទ្ធផលសម្រេចបានមួយកម្រិតតែមានការផ្លាស់ប្តូរ

- ○ ម៉ូឌុលមេរៀនស្តីពី IWRM បានរៀបចំរួចរាល់សម្រាប់ការបណ្តុះបណ្តាល
- ○ ពង្រាងម៉ូឌុលមេរៀនស្តីពីការចរចារ បានរៀបចំរួចរាល់សម្រាប់ការបណ្តុះបណ្តាល
- ○ ការអភិវឌ្ឍសមត្ថភាព/ការបណ្តុះបណ្តាលក៏ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ស្តីពី ៖
  - ✓ ការចែករំលែកផលប្រយោជន៍ក្នុងតំបន់
  - ✓ ក្របខ័ណ្ឌសូចនាកររបស់គណៈកម្មការទន្លេមេគង្គ
  - ✓ របាយការណ៍ស្ថានភាពអាងទន្លេ
  - ✓ ប្រព័ន្ធទិន្នន័យសេដ្ឋកិច្ច-សង្គម
  - ✓ វិធីសាស្ត្រសំរាប់វាយតម្លៃសេណារីយ៉ូអភិវឌ្ឍន៍
  - ✓ PMFM
  - ✓ ការរៀបចំផែនការយុទ្ធសាស្ត្រអាងទន្លេ និង ផែនការយុទ្ធសាស្ត្រ របស់គណៈកម្មការទន្លេមេគង្គ គោលការណ៍ណែនាំរៀបចំ NIP

***ការជួយគាំទ្រដល់ការអនុវត្តន៍ NIP នៅថ្នាក់ជាតិ***

- ○ ការងារអនុវត្តន៍គម្រោងគំរូជិតដល់ទីបញ្ចប់។ សកម្មភាពចុងក្រោយគឺ ការស្តារប្រឡាយជំហានទី១កំពុងបន្ត ហើយនឹងបញ្ចប់ក្នុងពេលឆាប់ខាងមុខ។
- ○ ភាពប្រឈមជាពិសេសចំពោះកម្ពុជា គឺខុសពីប្រទេស៣ទៀត យើងបានរើសយកគម្រោងហេដ្ឋារចនាសម្ព័ន្ធដើម្បីអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានទឹក ក្រុមការងារតំបន់មានបទពិសោធន៍តិចតួចក្នុងការវាយតម្លៃសំណើរគម្រោងប្រភេទនេះ រួមផ្សំនឹងតម្រូវការពេលវេលាដោះស្រាយបញ្ហាត្រួតស៊ីគ្នានៃដីស្រែ និងដីខ្នងប្រឡាយ ដែលនាំឲ្យស៊ីពេលយូរ រួចយើងជួបប្រទះនឹងកង្វះថវិការសម្រាប់អនុវត្តគម្រោង។
- ○ ទោះយ៉ាងណាយើងទទួលបានបទពិសោធន៍ក្នុងការអនុវត្តគម្រោងបែបនេះជាមួយសហគមន៍ និង MRC។

## ២ កម្មវិធីគ្រប់គ្រងធនធានទឹកចម្រុះមេគង្គ

### សមិទ្ធផលខាន់ៗដែលសម្រេចបាន ៖

ផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងគ្រប់គ្រងទឹកឆ្លងដែននៅក្នុងអនុអាងនៃទន្លេសេសាននិងស្រែពក និងនៅក្នុងតំបន់ដីសណ្តនៃទន្លេមេគង្គនាក្នុងឆ្នាំ២០១៥ ត្រូវបានធ្វើការរៀបចំធ្វើឡើងដោយមានការឯកភាពគ្នារវាងប្រទេសកម្ពុជានិងវៀតណាមក្រោមការជួយផ្តល់យោបល់របស់ទីប្រឹក្សាបច្ចេកទេសផ្នែកការងារគ្រប់គ្រងធនធានទឹករបស់ធនាគាពិភពលោក។ សមក្មភាពដែលបានព្រមព្រាងគ្នានោះមានរៀបរាប់ដូចខាងក្រោម:

- រៀបចំសេចក្តីព្រាង របាយការណ៍នៃបញ្ហាថ្នាក់ជាតិ សម្រាប់លទ្ធផលសម្រេចទី១នៃផែនការអនុវត្ត សកម្មភាពគម្រោង ដែលជារបាយការណ៍រួមគ្នាលើការកំណត់អត្តសញ្ញាណនៃបញ្ហាប្រឈម និង តំរូវការនៃការចែករំលែក ព័ត៌មាននិងទិន្នន័យ និងការសម្របសម្រួល។ សេចក្តីព្រាងរបាយការណ៍ រួមបញ្ចូលនូវបញ្ហាជាតិនិងបញ្ហាឆ្លងដែនដោយឈរលើទស្សនៈជាតិ និងរៀបរាប់ពីបញ្ហានៃការងារ គ្រប់គ្រងទឹកនៅក្នុងអនុអាងនៃទន្លេសេសាន និងស្រែពក និងនៅក្នុងតំបន់ដីសណ្តមេគង្គ ។ សេចក្តីព្រាងរបាយការណ៍ទាំងពីរត្រូវបានលើកយកមកពិភាក្សានៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ និងបានបញ្ជូនទៅ MRCS ដើម្បីធ្វើការកែសម្រួល និងទទួលបាននូវការផ្តល់ជាអនុសាសន៍ដើម្បី បន្តការកែលំអឯកសារ។
- ការកំណត់អត្តសញ្ញាណ និងឯកភាពគ្នាទៅលើបញ្ហានៃការងារគ្រប់គ្រងទឹកឆ្លងដែនរួមគ្នាដែល បញ្ហានេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍រួមគ្នានៃបញ្ហាគ្រប់គ្រងទឹកឆ្លងដែន (Joint Issues Papers)។ ជំនាញការបច្ចេកទេសធនធានទឹករបស់ធនាគាពិភពលោកបានផ្តល់នូវគំរូសម្រាប់សរ សេររបាយការណ៍រួមគ្នានេះនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៥។
- រៀបចំធ្វើទស្សនកិច្ចសិក្សានិងកិច្ចប្រជុំរួមគ្នាសម្រាប់រយពេល៥ថ្ងៃទៅពិនិត្យមើលនៅអនុអាងនៃ ទន្លេសេសាន និងស្រែពក និងបន្ទាប់មករៀបចំធ្វើសិក្ខាសាលារួមគ្នា។ កិច្ចការនេះនឹងអនុវត្តធ្វើ នៅក្នុងរវាងពាក់កណ្តាល ខែមករា ឬនៅក្នុងអាទិត្យទី៣ ខែកុម្ភៈ ឆ្នាំ២០១៦។
- បន្ទាប់ពីបានបញ្ចប់សេចក្តីព្រាងរបាយការណ៍នៃបញ្ហាថ្នាក់ជាតិរួមគ្នារវាងប្រទេសទាំងពីរ ប្រទេស នីមួយនឹងរៀបចំកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិជាមួយនឹងអ្នកដែលពាក់ព័ន្ធ ដើម្បីពិភាក្សាលើសេច ក្តីព្រាងនៃរបាយការណ៍បញ្ហាថ្នាក់ជាតិរួមគ្នានេះ។ កិច្ចពិគ្រោះយោបល់នេះនឹងអនុវត្តនៅក្នុងអំឡុង ខែមីនាឆ្នាំ ២០១៦។ លទ្ធផលដែលទទួលបានមកពីកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិនិងរបាយ ការណ៍នៃបញ្ហាថ្នាក់ជាតិរួមគ្នានេះនឹងត្រូវដាក់រួមបញ្ចូលទៅក្នុងការកែតម្រូវចុងក្រោយនៃរបាយ ការណ៍បញ្ហាឆ្លងដែនរួមគ្នាដែលត្រូវអនុវត្តឲ្យបានរួចរាល់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២១៦។

## *សេចក្តីសន្និដ្ឋាន*

ផ្អែកលើរបាយការណ៍លំអិតតាមសមិទ្ធផលនិមួយៗ ជាទូទៅសកម្មភាព៥ឆ្នាំ របស់កម្មវិធី BDP មាន ភាពលោភលន់បន្តិច ហើយនៅឆ្នាំ២០១៥ បានប្រឈមនឹងបញ្ហាថវិកា។ ទោះយ៉ាងណាក្រុមការងារជាតិ សហការណ៍ជាមួយតំបន់បានសម្រេចលទ្ធផលស្ទើរតែពេញលេញទោះបីការងាររៀបចំផែនការដោយមាន ការចូលរួមពីភាគីពាក់ព័ន្ធតែងតែសាំញ៉ាំនិងទាមទារពេលវេលាច្រើនដើម្បីប្រមូលបាននូវមតិយោបល់និង ការឯកភាពគ្នា។

គម្រោងគ្រប់គ្រងធនធានទឹកចម្រុះនៅតំបន់ដីសណ្តមេគង្គនិងនៅអនុអាងនៃទន្លេសេសាននិងស្រែពក បានប្រព្រឹត្តទៅដោយមានការចូលរួមផ្តល់ជាមតិយោបល់ពីអត្ថដែលពាក់ព័ន្ធមកពីតាមក្រសួងនិងស្ថាប័ណ្ណរដ្ឋាភិបាលនិងពីសំណាក់អង្គការក្រៅរដ្ឋាភិបាលតាមរយៈសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនិងការចុះប្រមូលទិន្នន័យនៅតាមថ្នាក់ក្រោមជាតិ ពីមន្ទីរ អង្គការក្រៅរដ្ឋាភិបាលនានា និងពីសហគមន៍ដែលរស់នៅក្នុងតំបន់ដែលមានការពាក់ព័ន្ធទៅនឹងគម្រោង។ ផលសម្រេចដែលទទួលបានពីការអនុវត្តគម្រោងនៅក្នុងឆ្នាំ២០១៥ នេះគឺបានធ្វើបញ្ចប់របាយការណ៍នៃបញ្ហាការងារគ្រប់គ្រងទឹកឆ្លងដែនថ្នាក់ជាតិដែលមានការឯកភាពគ្នារវាងប្រទេសកម្ពុជានិងវៀតណាម។

### *ផែនការការងារសម្រាប់ឆ្នាំ២០១៦*

រហូតដល់ ខែមិថុនា ឆ្នាំ២០១៦ ផែនការសកម្មភាពទាក់ទងផែនការអភិវឌ្ឍន៍អាងទន្លេមានដូចខាងក្រោម៖

- រៀបចំ PINs សម្រាប់សកម្មភាពជាតិ និងគម្រោងផែនការចង្អុលថ្នាក់ជាតិ ២០១៦-២០២០ និងឯកសារផែនការចង្អុលថ្នាក់ជាតិ ២០១៦-២០២០ ដើម្បីលើកកំពស់ការអនុវត្តន៍យុទ្ធសាស្រ្តអភិវឌ្ឍន៍អាងទន្លេមេគង្គនៅកម្ពុជាឲ្យមានប្រសិទ្ធិភាព ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។
- រៀបចំគម្រោងរួម ជាមួយប្រទេសឡាវ ប្រទេសថៃ និងប្រទេសវៀតណាម។
- ចូលរួមប្រជុំតំបន់ស្តីពីការរៀបចំគម្រោងរួម ជាមួយប្រទេសឡាវ ប្រទេសថៃ និងវៀតណាម។
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិបញ្ចប់លើឯកសារផែនការចង្អុលថ្នាក់ជាតិ ឆ្នាំ២០១៦-២០២០ រួមជាមួយនឹងការត្រួតពិនិត្យតាមដាន និងវាយតម្លៃ។
- បញ្ចប់ឯកសារផែនការចង្អុលថ្នាក់ជាតិឆ្នាំ២០១៦-២០២០។

ផែនការសកម្មភាពបន្តបន្ទាប់ពីលទ្ធផលសម្រេចទី១ (Outcome 1) នៃផែនការសកម្មភាពគម្រោងគ្រប់គ្រងធនធានទឹកចម្រុះមេគង្គបានរៀបចំរួចរាល់ដើម្បីអនុវត្តលទ្ធផលសម្រេចទី២ ដែលរៀបរាប់ពីការឯកភាពគ្នាលើយន្តការនៃការសម្របសម្រួលដើម្បីដោះស្រាយលើតម្រូវការនៃការងារគ្រប់គ្រង និងកិច្ចការសម្របសម្រួលឆ្លងដែន (Outcome 2: An agreed upon coordination mechanism to address transboundary management and coordination needs) និងលទ្ធផលសម្រេចទី៣ផែនការសកម្មភាពរួមគ្នាដើម្បីអនុវត្តទៅលើការសម្របសម្រួលដែលជាអាទិភាព និងសកម្មភាពគ្រប់គ្រងនានា (Outcome 3: Joint action plan to implement priority coordination and management activities)។

# កម្រងរូបភាពព្រឹត្តិការណ៍របស់នាយកដ្ឋានផែនការនិងសហប្រតិបត្តិការអន្តរជាតិ



*កិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់តំបន់ស្តីពីឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ ២០១៦-២០២០*



*កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពីការរៀបចំឯកសារផែនការយុទ្ធសាស្ត្រ MRC ២០១៦-២០២០*



*សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការរៀបចំប្រព័ន្ធទិន្នន័យសេដ្ឋកិច្ចសង្គមរបស់គណៈកម្មការទន្លេមេគង្គ*



កិច្ចប្រជុំលើកទី១២របស់ក្រុមការងារត្រួតពិនិត្យបច្ចេកទេសសម្រាប់អនុវត្តនីតិវិធីស្តីពីការថែរក្សា
លំហូរទឹកលើទន្លេមេរបស់គណៈកម្មការទន្លេមេគង្គ



ជំនួបប្រជុំជាមួយក្រុមជំនាញការតំណាងប្រទេសផ្តល់ជំនួយដើម្បីវាយតម្លៃលើផែនការយុទ្ធសាស្រ្ត
២០១៦-២០២០ របស់គណៈកម្មការទន្លេមេគង្គ



សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីផែនការយុទ្ធសាស្រ្ត៥ឆ្នាំ (២០១៦-២០២០)
របស់គណៈកម្មការទន្លេមេគង្គ



សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពីផែនការយុទ្ធសាស្ត្រ៥ឆ្នាំ (២០១៦-២០២០)
របស់គណៈកម្មការទន្លេមេគង្គ



កិច្ចប្រជុំសម្របសម្រួល BDP ថ្នាក់តំបន់លើកទី២២ នៃកម្មវិធីកសាងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ



កិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីការគ្រប់គ្រងធនធានទឹកនៅទំនាបលិចទឹកជ្រៃលាស់ ឃុំជ្រៃលាស់
និងការរៀបចំសិក្សានិងធ្វើគម្រោងប្លង់ស្តារប្រឡាយកងទ័ព ស្រុកពញាឮ ខេត្តកណ្តាល



កិច្ចប្រជុំក្រុមការងារបច្ចេកទេសពិសេសលើកទី២ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ
MRC ២០១៦-២០២០ នាថ្ងៃទី ២៣-២៤ ខែកក្កដា ឆ្នាំ ២០១៥



កិច្ចប្រជុំការងារបច្ចេកទេសថ្នាក់តំបន់ស្តីពីការធ្វើបច្ចុប្បន្នភាពផែនការចង្អុលថ្នាក់ជាតិ
សម្រាប់អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គ ២០១៦-២០២០



សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការរៀបចំផែនការចង្អុលថ្នាក់ជាតិឆ្នាំ២០១៦-២០២០
ដើម្បីអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គឆ្នាំ២០១៦-២០២០ របស់ MRC



កិច្ចប្រជុំថ្នាក់តំបន់ស្តីពីផែនការសកម្មភាពប្រចាំឆ្នាំ២០១៦ របស់គណៈកម្មការទន្លេមេគង្គ



សិក្ខាសាលាពិគ្រោះយោបល់ស្តីពីសេចក្តីព្រាងបឋមនៃផែនការចង្អុលថ្នាក់ជាតិសម្រាប់អនុវត្ត
យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គឆ្នាំ ២០១៦-២០២០ របស់គណៈកម្មការទន្លេមេគង្គ



កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីសេចក្តីព្រាងឯកសារផែនការសកម្មភាពប្រចាំឆ្នាំ២០១៦
របស់គណៈកម្មការទន្លេមេគង្គ



*សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីរបាយការណ៍នៃការអនុវត្តនីតិវិធីសម្រាប់រក្សាលំហូរទឹកនៅតាមទន្លេមេ ២០១១-២០១៥ និងការបណ្តុះបណ្តាលបច្ចេកទេសស្តីពីការប្រមូលទិន្នន័យសេដ្ឋកិច្ចសង្គមសម្រាប់ BDP*



*កិច្ចប្រជុំថ្នាក់តំបន់លើកទី២ស្តីផែនការការចង្អុលបង្ហាញរបស់ជាតិ ២០១៦-២០២០*

## ៤.២.៤ នាយកដ្ឋានគ្រប់គ្រងព័ត៌មាន និងចំណេះដឹង

នាយកដ្ឋានគ្រប់គ្រងព័ត៌មាន និងចំណេះដឹង មានកម្មវិធី ចំនួន០៣ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់នាយកដ្ឋាននេះ រួមមាន៖ ។

១. កម្មវិធីគ្រប់គ្រងព័ត៌មាន និងចំណេះដឹង
២. កម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់
៣. កម្មវិធីគ្រប់គ្រងគ្រោះរាំងស្ងួត

**ក. សមិទ្ធផលខាន់ៗដែលសម្រេចបានក្នុងឆ្នាំ២០១៥**

## គ.១ កម្មវិធីគ្រប់គ្រងព័ត៌មាន និងចំណេះដឹង

- *ការគ្រប់គ្រងនិងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលដោយមានការគាំទ្រផ្នែកបច្ចេកទេស*
  - បានចាត់មន្ត្រីតំណាងចូលរួមជាប្រចាំក្នុងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំកម្មវិធីគណៈកម្មាធិការសម្របសម្រួលកម្មវិធី និងក្រុមសម្របសម្រួលនិងជំនួយបច្ចេកទេស។
  - សម្របសម្រួលដំណើរទស្សនកិច្ចរបស់អនុរដ្ឋមន្ត្រីប្រទេសបារាំងចុះពិនិត្យស្ថានីយMekong HYCOS នៅចតុមុខ នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ រាជធានីភ្នំពេញ។
  - រៀបចំចុះអនុស្សារណៈយោគយល់រវាងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជានិងក្រុមហ៊ុន VSTECH ដើម្បីរៀបចំប្រព័ន្ធព័ត៌មានជាតិរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។
  - កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពីការអនុវត្តនីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹក និងដំណើរការអនុវត្តផែនការវិមជ្ឈការជំហានទី២ នៃគម្រោងពិនិត្យតាមដានធារទឹក និងកំរិតកករ។
  - បានបញ្ចប់គោលការណ៍ណែនាំរបស់គណៈកម្មការទន្លេមេគង្គស្តីពីការប្រើប្រាស់ទិន្នន័យ ព័ត៌មាន និងចំណេះដឹង ដែលបានកែសម្រួលកាលពីខែឧសភា ឆ្នាំ២០១៥ ហើយគ្រោងនឹងធ្វើការបោះពុម្ពផ្សព្វផ្សាយឆាប់ៗនេះ។

- *បណ្តាញពិនិត្យតាមដានទន្លេ និងការភ្ជាប់ជាមួយបណ្តាញប្រព័ន្ធពិនិត្យតាមដានដទៃទៀតរបស់គណៈកម្មការទន្លេមេគង្គត្រូវបានដាក់ឲ្យដំណើរការដើម្បីផ្តល់ទិន្នន័យជលសាស្ត្រ-ឧតុនិយមដែលមានគុណភាពនិងបានទាន់ពេលវេលានិងមានការពង្រឹងសមត្ថភាពដល់អ្នកពាក់ព័ន្ធថ្នាក់ជាតិ*
  - មន្ត្រីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធបានចូលរួមនិងយល់ដឹងអំពីវិធីសាស្រ្តក្នុងការវាស់កំរិតកករ និងទិន្នន័យកំរិតកករ តាមរយៈសិក្ខាសាលាថ្នាក់តំបន់។
  - មន្ត្រីនិងបុគ្គលិកជំនាញពីនាយកដ្ឋានជលសាស្រ្ត និងការងារទន្លេ តំណាងមន្ទីរធនធានទឹក និងឧតុនិយមខេត្ត និងអ្នកសង្កេតការណ៍ខេត្ត/ក្រុង បានយល់ដឹងអំពីការប្រើប្រាស់ឧបករណ៍ នីតិវិធីប្រតិបត្តិការគំរូស្តង់ដារប្រតិបត្តិការ និងការថែទាំឧបករណ៍ជលសាស្រ្ត Mekong Hycos តាមរយៈវគ្គបណ្តុះបណ្តាលថ្នាក់ជាតិ។
  - អ្នកជំនាញពីនាយកដ្ឋានជំនាញ មន្ត្រីសម្របសម្រួលកម្មវិធី និងអ្នកជំនាញពីថ្នាក់តំបន់បានចុះពិនិត្យ និងជួសជុលស្ថានីយ៍ Mekong HYCos នៅតាមបណ្តាខេត្តមួយចំនួន។
  - បានបោះពុម្ពនូវរបាយការណ៍ចុងក្រោយ នៅខែមេសា ឆ្នាំ២០១៥ ស្តីពីគម្រោងពិនិត្យតាមដានកំរិតកករ និងធារទឹករបស់គណៈកម្មការទន្លេមេគង្គ។



*សិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិស្តីពីលទ្ធផលបញ្ចប់គម្រោងធ្វើបច្ចុប្បន្នភាពគម្របដី*
*នៅក្នុងអាងទន្លេមេគង្គភាគខាងក្រោម នាថ្ងៃទី១៤-១៥ ខែធ្នូ ឆ្នាំ២០១៥ ទីក្រុងសៀមរាប*

- ***ប្រព័ន្ធព័ត៌មាន គ.ជ.ទ.ម.ក ដែលផ្ទុកទិន្នន័យនិងព័ត៌មានពីគណៈកម្មការទន្លេមេគង្គនិងស្ថាប័នពាក់ព័ន្ធត្រូវបានបង្កើតនិងធ្វើបច្ចុប្បន្នភាពជាប្រចាំសំរាប់ជាប្រយោជន៍ដល់អ្នកពាក់ព័ន្ធមេគង្គបានប្រើប្រាស់***
  - មន្ត្រីជំនាញចំនួន ០៤រូប បានចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់តំបន់ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធព័ត៌មានរបស់គណៈកម្មការទន្លេមេគង្គ (MRC-IS) នាថ្ងៃទី០៧-០៨ ខែមេសា ឆ្នាំ២០១៥ នៅខេត្តសៀមរាប។
  - សម្របសម្រួលជាមួយក្រុមហ៊ុនវីអេសស៊ីថេក ក្នុងការរៀបចំគេហទំព័រសម្រាប់តម្លើងកុំព្យូទ័រមេគជទមក។
  - ទិន្នន័យព័ត៌មាន និងឯកសារពាក់ព័ន្ធបន្ថែមមួយចំនួន ត្រូវបានបញ្ចូលជាបណ្តើរៗ ដើម្បីត្រៀមដាក់ឲ្យប្រើប្រាស់ ប្រព័ន្ធព័ត៌មានគជទមក។

- ***សេវាកម្មនៃឧបករណ៍បច្ចេកទេសនិងម៉ូដែលរបស់គណៈកម្មការទន្លេមេគង្គសំរាប់ការធ្វើផែនការការព្យាករណ៍ និងការវាយតម្លៃផលប៉ះពាល់ត្រូវបានប្រើប្រាស់ដោយស្ថាប័នពាក់ព័ន្ធកម្ពុជា***

មន្ត្រីក្រសួង-ស្ថាប័នពាក់ព័ន្ធបានទទួលការចូលរួមវគ្គបណ្តុះបណ្តាលអនុវត្តគម្រោងសិក្សាសាកល្បងនិងបានយល់ដឹងអំពីការប្រើប្រាស់ឧបករណ៍បច្ចេកទេសតាមរយៈសកម្មភាពដូចខាងក្រោម៖

- ជំនាញការម៉ូដែលថ្នាក់ជាតិបានទៅចូលរួមពិនិត្យទិន្នន័យម៉ូដែលបច្ចុប្បន្នភាពដែលរៀបចំដោយកម្មវិធីគ្រប់គ្រងព័ត៌មាន និងចំណេះដឹង។
- វគ្គបណ្តុះបណ្តាលលើការប្រើប្រាស់ឧបករណ៍បច្ចេកទេស ម៉ូដែល និងបញ្ចូលទិន្នន័យដើម្បី គាំទ្រដំណើរការករណីសិក្សាម៉ូដែល ២០១៤។

- ○ កិច្ចប្រជុំថ្នាក់ជាតិស្តីពីការអនុវត្តនីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹកនិងការបញ្ចប់ការសិក្សាសាកល្បងផ្នែកម៉ូដែលនៅព្រែកទាំងបួន (ព្រែកព្រិច ព្រែកក្រៀង ព្រែកកាំពី ព្រែកទេ)
- ○ ចុះប្រមូលទិន្នន័យដើម្បីធ្វើបច្ចុប្បន្នភាពផែនទីគម្របដីនៅអាងទន្លេមេគង្គភាគខាងក្រោមចំនួន ០២ លើក។
- ○ មន្ត្រីចំនួន ០៧រូប បានចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់តំបន់ ស្តីពីការប្រើប្រាស់ម៉ូដែល ISIS ។
- ○ មន្ត្រីចំនួន ០៦រូប បានចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់តំបន់សម្រាប់គ្រូបង្គោលផ្នែកប្រើប្រាស់ម៉ូដែល IQQM ។
- ○ សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិ ស្តីពីការប្រើប្រាស់ម៉ូដែល eWater source។
- ○ សិក្ខាសាលាបណ្តុះបណ្តាលបច្ចេកទេសថ្នាក់ជាតិស្តីពីការប្រើប្រាស់បច្ចេកវិទ្យាអង្កេតរូបភាពពីលំហរសម្រាប់ការសិក្សានៅស្ទឹងពោធិ៍សាត់ក្នុងការអនុវត្តនីតិវិធីតាមដានការប្រើប្រាស់ទឹក។
- ○ លទ្ធផលបញ្ចប់នៃគម្រោងធ្វើបច្ចុប្បន្នភាពគម្របដីនៅក្នុងអាងទន្លេមេគង្គភាគខាងក្រោម។



*សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិស្តីពីការប្រើប្រាស់ម៉ូដែល eWater source*
*នាថ្ងៃទី២០-២៤ ខែកក្កដា ឆ្នាំ២០១៥ ទីក្រុងកំពង់ចាម*

## ក.២ កម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់

- *មន្ត្រីកម្ពុជាចំនួន០៤រូបបានចូលរួមកិច្ចប្រជុំលើកទី២៦នៃគណៈសម្របសម្រួលកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់។*

- *ការព្យាករណ៍ទឹកជំនន់ ការវាយតម្លៃផលប៉ះពាល់ ការធ្វើម៉ូដែល ការពិនិត្យតាមដាន និងការគ្រប់គ្រងចំណេះដឹង។*

- ○ សមាជិកក្រុមការងារ ជំនាញការជាតិ និងមន្ត្រីតំណាងពាក់ព័ន្ធ សរុប១៤ រូប បានចូលរួមកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិស្តីពីរបាយការណ៍ដំបូងសម្រាប់គម្រោងបន្សាំសាកល្បងនៅកម្ពុជា។
- ○ មន្ត្រីតំណាងចំនួន០២រូបបានចូលរួមកិច្ចប្រជុំថ្នាក់តំបន់ស្តីពីការចាប់ផ្តើមអនុវត្តការងារទី៣ក្នុងការសិក្សាដំបូងអំពីស្ថានភាពនៃការអភិវឌ្ឍន៍ដែលអាចកើតមានក្នុងតំបន់ទំនាបលិចទឹកនៅខេត្តសៀមរាប ដើម្បីបង្ហាញនិងពិភាក្សាលើព័ត៌មាន និងរបាយការណ៍សម្រាប់រៀបចំសេណារីយ៉ូនៃនិន្នាការអភិវឌ្ឍន៍។
- ○ មន្ត្រីជំនាញចំនួន ១២រូប ពីនាយកដ្ឋានជំនាញ និងមន្ទីរធនធានទឹក និងឧតុនិយមខេត្ត/ក្រុង បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធព្យាករណ៍ទឹកជំនន់ទន្លេមេគង្គ និងប្រព័ន្ធព្យាករណ៍ទឹកជំនន់ទឹកភ្លៀង ដើម្បីស្វែងយល់អំពីបច្ចុប្បន្នភាព និងប្រសិទ្ធភាពប្រព័ន្ធព្យាករណ៍ទឹកជំនន់ទន្លេមេគង្គ និងជំនន់ទឹកភ្លៀងរបស់គណៈកម្មការទន្លេមេគង្គ។

- ▪ ***កិច្ចសន្ទនា និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពក្នុងចំណោមប្រទេសជាសមាជិក និងដៃគូសន្ទនាក្នុងការដោះស្រាយបញ្ហាទឹកជំនន់ឆ្លងដែន***
  - ○ បញ្ហាទឹកជំនន់ឆ្លងដែនត្រូវបានពិភាក្សា និងដោះស្រាយ ក្នុងចំណោមប្រទេសជាសមាជិកមេគង្គ និងដៃគូសន្ទនា តាមរយៈកិច្ចប្រជុំគណៈកម្មាធិការដឹកនាំកម្មវិធី។
  - ○ សម្របសម្រួលកម្មវិធី ដោយផ្អែកលើនីតិវិធី និងគោលការណ៍ណែនាំមួយចំនួនដែលបានបង្កើតឡើង ដើម្បីជួយសម្រួលដល់ការកាត់បន្ថយនិងដោះស្រាយផលប៉ះពាល់និងជម្លោះ។



*កិច្ចប្រជុំលើកទី២៦នៃគណៈសម្របសម្រួលកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ នៅទីក្រុងហាណូយ*



*វគ្គបណ្តុះបណ្តាលស្តីពី ប្រព័ន្ធព្យាករណ៍ទឹកជំនន់ទន្លេមេគង្គ និងប្រព័ន្ធព្យាករណ៍ទឹកជំនន់ទឹកភ្លៀង នាថ្ងៃទី ១១-១២ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅទីរួមខេត្តពោធិសាត់*

## គ.៣ កម្មវិធីគ្រប់គ្រងគ្រោះរាំងស្ងួត

- ▪ ***យុទ្ធសាស្ត្រនៃការកាត់បន្ថយ និងគ្រប់គ្រងគ្រោះរាំងស្ងួតថ្នាក់តំបន់***

- តំណាងក្រសួងស្ថាប័នពាក់ព័ន្ធចំនួន២៥រូបបានចូលរួមរៀបចំផែនការការងារសម្រាប់ឆ្នាំ ២០១៥ របស់កម្មវិធីគ្រប់គ្រងគ្រោះរាំងស្ងួត។
- មន្ត្រីតំណាងចំនួន ០២រូប បានទៅចូលរួមកិច្ចប្រជុំកិច្ចប្រជុំស្តីពីការចាប់ផ្តើមផែនការសកម្មភាពការងារសម្រាប់ឆ្នាំ២០១៥។

▪ ***ការវាយតម្លៃហានិភ័យ/ភាពងាយរងគ្រោះពីភាពរាំងស្ងួត និងការវិភាគអំពីសេដ្ឋកិច្ចសង្គម និងភាពសមស្របនៃដី***

- សមាជិកក្រុមការងារ ចំនួន១១រូប បានចុះពិនិត្យ និងជ្រើសរើសទីតាំងសម្រាប់បំពាក់ឧបករណ៍ស្ថានីយ៍ជលសាស្ត្រ-ឧតុនិយមស្វ័យប្រវត្តិ នៅក្នុងខេត្ត ចំនួន ០៧។ ជាលទ្ធផល ក្រុមការងារបានឯកភាពគ្នាជ្រើសរើសយកទីតាំងចំនួន០៥កន្លែងសម្រាប់បំពាក់ឧបករណ៍ស្ថានីយ៍ជលសាស្ត្រ និងឧតុនិយមស្វ័យប្រវត្តិ ដែលជាទីតាំងស្ថានីយ៍កត់ត្រាចាស់(Menu Stations)។
- មន្ត្រីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិរហូតដល់ថ្នាក់ខេត្ត និងស្រុក សរុបចំនួន ៣៦ នាក់ បានចូលរួមវាយតម្លៃភាពងាយរងគ្រោះនិងផលប៉ះពាល់ពីគ្រោះរាំងស្ងួត នៅក្នុងខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ចាម។
- មន្ត្រីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ ចំនួន៣៥រូប បានចូលរួមវាយតម្លៃភាពងាយរងគ្រោះ និងផលប៉ះពាល់នៃគ្រោះរាំងស្ងួត សម្រាប់ខេត្តព្រៃវែង និងខេត្តស្វាយរៀង។
- 

*ក្រុមការងារចុះពិនិត្យជ្រើសរើសទីតាំងបំពាក់ឧបករណ៍ស្ថានីយ៍ជលសាស្ត្រ-ឧតុនិយមស្វ័យវត្តិ នាថ្ងៃទី២៦-២៩ ខែសីហា និងថ្ងៃទី០១-០៣ ខែកញ្ញា ឆ្នា២០១៥*




កិច្ចប្រជុំពិគ្រោះយោល់ស្តីពីការវាយតម្លៃភាពងាយរងគ្រោះ និងផលប៉ះពាល់នៃគ្រោះរាំងស្ងួត សម្រាប់ខេត្តព្រៃវែង និង ខេត្តស្វាយរៀង នាថ្ងៃទី១៦-១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ខេត្តព្រះសីហនុ




កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការវាយតម្លៃភាពងាយរងគ្រោះនិងផលប៉ះពាល់នៃគ្រោះរាំងស្ងួតនៅក្នុងខេត្ត កំពង់ឆ្នាំង និង ខេត្តកំពង់ចាម នាថ្ងៃទី២៨ និង២៩ ខែកញ្ញា ឆ្នាំ ២០១៥ ខេត្តសីហនុ

- ***ការកសាងសមត្ថភាពសំរាប់ការត្រៀមគ្រោះរាំងស្ងួត ការរៀបចំផែនការ និងការគ្រប់គ្រង***

សមិទ្ធផលសំខាន់ៗដែលកម្មវិធីទទួលបានក្នុងឆ្នាំ២០១៥ រួមមានៈ

- ***ការវាយតម្លៃភាពងាយរងគ្រោះនិងផលប៉ះពាល់នៃគ្រោះរាំងស្ងួត***
  - រាយការណ៍និងពិភាក្សាលើលទ្ធផលនៃការវាយតម្លៃភាពងាយរងគ្រោះនិងផលប៉ះពាល់ពីគ្រោះរាំងស្ងួតជាមួយក្រសួង-ស្ថាប័ននិងអ្នកពាក់ព័ន្ធថ្នាក់ជាតិតាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ
  - បញ្ចប់របាយការណ៍ចំណាត់ថ្នាក់ផលប៉ះពាល់ ភាពងាយរងគ្រោះ និងហានិភ័យនៃគ្រោះរាំងស្ងួត លើតំបន់ផ្សេងៗគ្នានៅក្នុងអាងទន្លេមេគង្គក្រោម

- ***វាយតម្លៃតម្រូវការសមត្ថភាព និងអភិវឌ្ឍន៍សមត្ថភាព***
  - ចាប់ផ្តើមសកម្មភាពបណ្តុះបណ្តាលថ្នាក់ជាតិ និងតំបន់

- ***ការវិភាគធនធានទឹក និងការប្រើប្រាស់ដី***
  - បង្កើត និងធ្វើឲ្យប្រសើរឡើងនូវស្ថានីយ៍ជលសាស្ត្រ និងឧតុនិយមនៅក្នុងតំបន់មានហានិភ័យគ្រោះរាំងស្ងួតនៃអាងទន្លេមេគង្គក្រោម សម្រាប់ទំនាក់ទំនងនិងតាមដានត្រួតពិនិត្យភាពងាយរងគ្រោះ និងហានិភ័យនាពេលអនាគត
  - ដំណើការវិភាគលើតុល្យភាពទឹក និងភាពសមស្របនៃដំណាំ ទៅនឹងគ្រោះរាំងស្ងួត
  - បង្ហាញពីលទ្ធផល និងប្រមូលមតិយោបល់ ពីស្ថាប័នពាក់ព័ន្ធ និងប្រទេសជាសមាជិក
  - បញ្ចប់របាយការណ៍ ស្តីពីការវិភាគធនធានទឹក និងដី នៅក្នុងអាងទន្លេមេគង្គក្រោម

- ***យុទ្ធសាស្ត្រថ្នាក់តំបន់ សម្រាប់ការគ្រប់គ្រង និងកាត់បន្ថយគ្រោះរាំងស្ងួតត្រូវបានបង្កើតឡើង***

- ○ ពិភាក្សាជាមួយអ្នកពាក់ព័ន្ធថ្នាក់ជាតិ ស្ដីពីអាទិភាពនៃតម្រូវការរបស់ជាតិលើយុទ្ធសាស្ត្រនៃការកាត់បន្ថយ និងការគ្រប់គ្រងគ្រោះរាំងស្ងួត
- ○ បង្កើតនូវប្រព័ន្ធតាមដានត្រួតពិនិត្យ និងព្យាករណ៍គ្រោះរាំងស្ងួត នៅថ្នាក់ជាតិ និងថ្នាក់តំបន់។



*សិក្ខាសាលានេះស្ដីពីការគ្រប់គ្រងគ្រោះមហន្តរាយនៅឥណ្ឌូនេស៊ី នាថ្ងៃទី១២-១៣ ខែសីហា ឆ្នាំ២០១៥ នៅមជ្ឈមណ្ឌលសម្របសម្រួលអាស៊ានសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយប្រទេសឥណ្ឌូនេស៊ី*

## *បញ្ហាប្រឈម*

ថវិកាមួយចំនួនធំត្រូវបានកាត់បន្ថយលើសកម្មភាពមួយចំនួននៅថ្នាក់ជាតិបើធៀបទៅនឹង ឆ្នាំ២០១៤។ ដោយថវិកាមានកំណត់ជាហេតុនាំអោយអនុវត្តតែលើគម្រោងមួយចំនួនប៉ុណ្ណោះជាពិសេសគម្រោងសិក្សាបឋមដើម្បីបង្ហាញអំពីការបង្កើតទិសដៅជាយុទ្ធសាស្ត្រ ដើម្បីគ្រប់គ្រងហានិភ័យកើតពីទឹកជំនន់ដែលធ្លាប់មានសម្រាប់អនាគត។

ចំពោះកម្មវិធីគ្រប់គ្រងព័តមាននិងចំណេះដឹងមានការខ្វះខាតថវិកាសម្រាប់ការអនុវត្តន៍សកម្មភាពរបស់ខ្លួនក្នុងឆ្នាំ២០១៥កន្លងមក ដោយសារដៃគូអភិវឌ្ឍន៍ពុំបានផ្ដល់ថវិកាទាន់ពេលវេលា និងគ្រប់គ្រាន់។ ម៉្យាងទៀត ប្រទេសជាសមាជិកពុំទាន់មានការឯកភាពក្នុងការអនុវត្តសកម្មភាពរបស់កម្មវិធីនេះចាប់តាំងពីឆ្នាំ២០១៤ រហូតដល់ ឆ្នាំ២០១៥។

## *ផែនការការងារសម្រាប់ឆ្នាំ២០១៦*

ក្នុងចំណោមកម្មវិធីដែលស្ថិតក្រោមនាយកដ្ឋានគ្រប់គ្រងព័ត៌មាននិងចំណេះដឹងឃើញថាកម្មវិធីគ្រប់គ្រងព័ត៌មាននិងចំណេះដឹង បានអនុវត្តលើសកម្មភាពជាច្រើនដោយសារមានថវិកាច្រើនជាងកម្មវិធី ដទៃទៀត។ ទោះយ៉ាងណា កម្មវិធីនេះនៅតែមានកង្វះខាតក្នុងការសម្រេចបានតាមផែនការ និងលទ្ធផលសម្រេចរបស់កម្មវិធីដោយសារនៅផ្នែកខ្លះរបស់លទ្ធផលសម្រេចមួយចំនួន ជាពិសេសទាក់ទងនឹងសកម្មភាពការងារអាទិភាព ស្ដីពីប្រព័ន្ធព័ត៌មាន ក្នុងលទ្ធផលសម្រេចទី២ និងការងារក្នុងលទ្ធផលសម្រេចទី៥ ដោយសារកង្វះថវិកា និងធនធានមនុស្សនៅថ្នាក់តំបន់ ដែលនៅបន្សល់ទុកឲ្យការងារនេះពុំទាន់បានបញ្ចប់នៅឡើយ ហើយមន្ត្រីពីថ្នាក់ជាតិនៅពុំអាចមានសមត្ថភាពគ្រប់គ្រាន់នៅ

ឡើយសម្រាប់ត្រៀមសហការសិក្សាជាមួយក្រុមការងារថ្នាក់តំបន់ដូចជា គម្រោងសិក្សារបស់ក្រុមប្រឹក្សា និងការវាយតម្លៃផលប៉ះពាល់នានានៃគម្រោងអភិវឌ្ឍន៍លើដងទន្លេមេគង្គកន្លងមក។ ចំពោះកម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ជាកម្មវិធីស្នូលក្នុងការព្យាករណ៍ទឹកជំនន់ហាក់ពុំសូវមានសកម្មភាពដែលគួរឲ្យចាប់អារម្មណ៍នៅថ្នាក់ជាតិ និងមានការរឹតត្បិតលើការចូលរួមរបស់តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ និងតួនាទីចាត់ចែងរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។ ចំណែកកម្មវិធីគ្រប់គ្រងគ្រោះរាំងស្ងួត ទើបតែមានថវិកា ហើយជាថវិកាបន្តិចបន្តួចដែលពិបាកក្នុងការសម្រេចបានការងារសំខាន់ៗតាមការរំពឹងទុក និងពុំមានសកម្មភាពណាបំរើឲ្យការកសាងសមត្ថភាពសមត្ថភាពនៅឡើយ។

កម្មវិធីទាំងនោះ នៅតែត្រូវការថវិកាក្នុងឆ្នាំ២០១៦ ដើម្បីពង្រឹងតួនាទីរបស់ខ្លួនដែលធ្លាប់មានពីមុនមកក្នុងនោះមានការងារចុះប្រមូលទិន្នន័យ និងព័ត៌មាន ដើម្បីធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មាន។ ដោយសារការគាំទ្រថវិកាពីគណៈកម្មការទន្លេមេគង្គកាន់តែថយចុះជាលំដាប់នាយកដ្ឋានគួរមានតួនាទីស្នូលក្នុងការលើកជាសំណើគម្រោងដើម្បីសុំថវិកាពីប្រភពដទៃ និងមានលទ្ធភាពលើកសំណើថវិការដ្ឋសម្រាប់ឆ្នាំខាងមុខ។ ជាងនេះ គ.ជ.ទ.មក និងនាយកដ្ឋានគួរប្រកាន់ខ្ជាប់នូវជំហរបច្ចេកទេសជាក់ស្តែងលើផលប៉ះពាល់ ទាំងវិជ្ជមាននិងអវិជ្ជមាន ដែលបណ្តាលមកពីគម្រោងអភិវឌ្ឍន៍តាមដងទន្លេមេគង្គចាប់ផ្តើមចំណាយទុនលើគម្រោងសិក្សាលើផលប៉ះពាល់សម្រាប់រកវិធានការដោះស្រាយផលប៉ះពាល់ឆ្លងដែននិងកាត់បន្ថយផលប៉ះពាល់ស្របទៅតាមបទដ្ឋានគតិយុត្តិជាតិ និងអន្តរជាតិ ដោយរួមទាំងនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គផងដែរ។

- បន្តរៀបចំប្រព័ន្ធព័ត៌មានរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាជាមួយក្រុមហ៊ុនVSCTECH តាមផែនការដែលបានគ្រោងទុក (តាមផែនការដើមគ្រោងនឹងបញ្ចប់នាដំណាច់ឆ្នាំ២០១៥)។
- រៀបចំបោះពុម្ពផែនទីគម្របដីនៅក្នុងអាងទន្លេមេគង្គភាគខាងក្រោមដើម្បីចែកជូនដល់ក្រសួងស្ថាប័នពាក់ព័ន្ធតាមសំណូមពររបស់សិក្ខាសាលា។
- ត្រៀមចុះអនុស្សារណៈយោគយល់គ្នារវាងលេខាធិការដ្ឋាសនគណៈកម្មការទន្លេមេគង្គ និងនាយកដ្ឋានជលសាស្ត្រនិងការងារទន្លេ និងនាយកដ្ឋានឧតុនិយម ដែលគ្រោងធ្វើនៅដើមឆ្នាំ២០១៦ សម្រាប់ការប្រមូលទិន្នន័យចាប់ពីឆ្នាំ២០១៦ដល់ពាក់កណ្តាលឆ្នាំ២០១៧ដើម្បីប្រើប្រាស់ក្នុងការព្យាករណ៍ទឹកជំនន់ និងពិនិត្យតាមដានស្ថានភាពទឹកទន្លេមេគង្គ។

## ៤.២.៥ នាយកដ្ឋានបណ្តាគម្រោង និងកម្មវិធី

នាយកដ្ឋានបណ្តាគម្រោងនិងកម្មវិធីមានកម្មវិធី ចំនួន០៦ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់នាយកដ្ឋាននេះ រួមមាន ៖

១. កម្មវិធីជលផល
២. កម្មវិធីកសិកម្មនិងធារាសាស្ត្រ
៣. កម្មវិធីនិរន្តរភាពវារីអគ្គិសនី
៤. កម្មវិធីបរិស្ថាន
៥. កម្មវិធីបម្រែបម្រួលអាកាសធាតុនិងការបន្សាំ
៦. កម្មវិធីនាវាចរ

## ១. កម្មវិធីជលផល

### *សមិទ្ធផលការងារសម្រេចបាន*

- បានបញ្ចប់ការរៀបចំអត្ថបទសិក្សាស្រាវជ្រាវសម្រាប់ការបោះពុម្ពទស្សនាវដ្ដីផលចាប់ និងការចិញ្ចឹមត្រី Vol.២១.៣ ស្ដីពីផលិតកម្ម និងតំលៃនៅទីផ្សារបស់ប្រភេទត្រីលម្អ នៅក្នុងបណ្ដាប្រទេសអាស៊ាន និងបង្គាទឹកសាប។
- បានបញ្ចប់ការធ្វើបច្ចុប្បន្នភាពសៀវភៅរូបភាពសម្រាប់កំណត់អត្តសញ្ញាណត្រីទឹកសាប។
- បានផ្ដល់យោបល់ និងអនុម័តលើរបាយការណ៍ថ្នាក់ជាតិស្ដីពីការពិនិត្យមើលឡើងវិញលើការសិក្សា និងជំរឿនថ្នាក់ជាតិដែលពាក់ព័ន្ធទៅនឹងវិស័យជលផលក្នុងប្រទេសឡាវ កម្ពុជា និងវៀតណាម។
- បានបោះពុម្ព និងចែកចាយឯកសារបច្ចេកទេសចំនួន៣ ស្ដីពីជម្រកត្រី និងទិន្នផលត្រីនៅក្នុងអាងទន្លេមេគង្គភាគខាងក្រោម ការត្រួតពិនិត្យឡើងវិញលើឯកសារស្រាវជ្រាវផ្លូវត្រី ដែលមានស្រាប់ និងការលូតលាស់នៃកូនត្រីម្សៅ និងកូនត្រីជទង់នៅក្នុងអាងទន្លេមេគង្គក្រោម។
- បានចែកចាយ និងផ្សព្វផ្សាយនូវអត្ថបទបោះពុម្ពផ្សាយស្ដីពីផលចាប់ និងការចិញ្ចឹមត្រី និងស្ដីពីការបន្សាំជលផលទៅនឹងការប្រែប្រួលអាកាសធាតុ។
- បានបញ្ចប់ការបកប្រែ និងបោះពុម្ពទស្សនាវដ្ដីផលចាប់ និងការចិញ្ចឹមត្រីជាភាសា ឡាវ កម្ពុជា ថៃ និងវៀតណាម Vol. ១៦, ១៧, ១៨, ១៩, ២០ និង២១ ។
- បានចងក្រងសៀវភៅស្ថិតិជលផល ដែលទិន្នន័យបានមកពីប្រទេសជាសមាជិកទាំងបួន សម្រាប់ការរៀបចំឯកសារស្ដីពីស្ថានភាពអាងទន្លេ និងរបាយការណ៍ស្ដីពីវិស័យជលផល ក្នុងអាងទន្លេមេគង្គភាគខាងក្រោម ។
- បានបញ្ចប់សេចក្ដីព្រាងផែនការធ្វើវិមជ្ឈការនៃការផ្ទេរសកម្មភាពត្រួតពិនិត្យ និងការតាមដានផលចាប់ ២០១៦-២០២០ សម្រាប់ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គបន្តអនុវត្ត។

- បានចូលរួមសរសេររបាយការណ៍ស្ថានភាពអាងទន្លេមរបស់គណៈកម្មការទន្លេមេគង្គ និងការនេសាទប្រចាំថ្ងៃរបស់អ្នកនេសាទនៅក្នុងអាងទន្លេមេគង្គភាគខាងក្រោម ដោយធ្វើការវិភាគអំពីនិន្នាការផលចាប់ ដោយប្រើប្រាស់ទិន្នន័យផលចាប់ ដោយដាយត្រី និងឧបការណ៍ Lee ។
- បានផ្តល់យោបល់ និងអនុម័តលើរបាយការណ៍បញ្ចប់ស្តីពីការពិនិត្យមើលឡើងវិញនូវគោលនយោបាយ និងបទដ្ឋានច្បាប់សម្រាប់ការបង្កើនផលស្តុកត្រី ក្នុងបណ្តាប្រទេសសមាជិក នៃអាងទន្លេមេគង្គភាគខាងក្រោម។ ផ្អែកលើរបាយការណ៍ថ្នាក់ជាតិ កម្មវិធីជលផល បានបង្កើតក្រុមប្រតិបត្តិសម្រាប់បង្កើនផលស្តុក នៅក្នុងអាងទន្លេមេគង្គភាគខាងក្រោម និងបានអនុម័តនៅក្នុងកិច្ចប្រជុំថ្នាក់តំបន់។
- បានបញ្ចប់របាយការណ៍វាយតម្លៃផលប៉ះពាល់នៃប្រតិបត្តិការទ្វារទឹក (Weir) លើភាពសម្បូរបែបនៃប្រភេទត្រីក្នុងទន្លេ និងដៃទន្លេ។
- បានបញ្ចប់ការចុះប្រមូលទិន្នន័យស្តីពីការសិក្សា និងអង្កេតលើស្ថានភាពនិងនិន្នាការវារីវប្បកម្មនៅក្នុងប្រទេសទាំងបួនដែលជាសមាជិក។
- បានផ្តល់យោបល់ និងអនុម័តលើរបាយការណ៍ប្រចាំឆ្នាំស្តីពីការត្រួតពិនិត្យ និងតាមដានភាពសម្បូរបែបនៃប្រភេទត្រីក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាមសម្រាប់ឆ្នាំ ២០១៣-២០១៤។
- បានផ្តល់យោបល់ និងអនុម័តលើរបាយការណ៍ស្តីពីការសិក្សាសាកល្បង និងការវាយតម្លៃសិប្បីជាតិ( Mollucs) នៅក្នុងខេត្តកំពង់ឆ្នាំងប្រទេសកម្ពុជា។
- បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលបច្ចេកទេសថ្នាក់តំបន់ស្តីពីការប្រើប្រាស់មូលដ្ឋានទិន្នន័យ និងការបញ្ចូលទិន្នន័យអំពីទិន្នផលត្រីក្នុងទីកន្លែងនេសាទត្រី។
- បានផ្តល់យោបល់ និងអនុម័តលើរបាយការណ៍ស្រាវជ្រាវបច្ចេកទេសស្តីពីការរីកលូតលាស់នៃប្រភេទពូជត្រីក្នុងស្រុក Hoven’s Carp, O.exodon, *B. gonionotus Hemibagrus Wyckioides* និង *Pangasius larnaudii* ក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។
- បានផ្តល់យោបល់ និងអនុម័តរបាយការណ៍ស្តីពីការសិក្សាស្រាវជ្រាវលើភាពលូតលាស់របស់ត្រីប្រលូង (Hoven Carp) ក្នុងស្រះវារីវប្បកម្មរបស់ប្រទេសកម្ពុជា។
- បានផ្តល់យោបល់ និងអនុម័តរបាយការណ៍បញ្ចប់ស្តីពីការពិនិត្យមើលឡើងវិញលើការបង្កើនផលស្តុកត្រីពេលបច្ចុប្បន្ន នៅក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម និងបានចងក្រងជាក្រុមប្រតិបត្តិតំបន់ និងអនុម័តពីប្រទេសជាសមាជិក នៅក្នុងកិច្ចប្រជុំថ្នាក់តំបន់។
- បានបញ្ចប់ការផ្តល់យោបល់ និងអនុម័តលើគោលការណ៍ណែនាំសម្រាប់ការធ្វើឲ្យប្រសើរឡើងនូវការចលនារបស់ត្រីតាមប្រព័ន្ធធារាសាស្រ្ត និងការធ្វើផែនការសម្រាប់ការអនុវត្តសាកល្បងគោលការណ៍ណែនាំនេះ។

- បានរៀបចំសំណើគម្រោងសម្រាប់ការសិក្សាថ្នាក់តំបន់មួយដែលទាក់ទងទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យជលផល និងវារីវប្បកម្មក្នុងអាងទន្លេមេគង្គភាគខាងក្រោម។ ការសិក្សា នឹងសហការយ៉ាងជិតស្និទ្ធជាមួយកម្មវិធីផ្តួចផ្តើមការបន្សាំការប្រែប្រួលអាកាសធាតុ (CCAI)។ លទ្ធផលនៃការសិក្សា នឹងប្រើប្រាស់ជាធាតុចូលមួយសម្រាប់រៀបចំ MASAP
- បានបញ្ចប់ពង្រាងម៉ូដែលជលផល-ជលសាស្រ្ត។ លទ្ធផលនៃការធ្វើម៉ូដែល នឹងគាំទ្រដល់ការវាយតម្លៃសេដ្ឋកិច្ចសង្គម របស់កម្មវិធីផ្តួចផ្តើមបន្សាំការប្រែប្រួលអាកាសធាតុ(**CCAI**)។
- បានលើកគម្រោងសំណើថវិកា និងពិភាក្សាជាមួយកម្មវិធីផ្តួចផ្តើមបន្សាំការប្រែប្រួលអាកាសធាតុ (CCAI) សម្រាប់គាំទ្រដល់សិក្ខាសាលាបណ្តុះបណ្តាលស្តីពីជលផល-ជលសាស្រ្តម៉ូដែល។ ជាលទ្ធផល CCAI បានឯកភាព និងអនុម័តផ្តល់ថវិកាសម្រាប់ការបណ្តុះបណ្តាល។
- បានផ្តល់យោបល់ និងអនុម័តលើរបាយការណ៍ថ្នាក់ជាតិរបស់ប្រទេសជាសមាជិកទាំងបួនស្តីពីការសិក្សាបញ្ហាយេនឌ័រនៅក្នុងវិស័យជលផល និងវារីវប្បកម្មនៅក្នុងអាងទន្លេមេគង្គ ភាគខាងក្រោម។
- បានផ្តល់យោបល់ និងអនុម័តលើការសិក្សាស្តីពីការស្ទង់មតិលើផលប៉ះពាល់សេដ្ឋកិច្ចសង្គមដោយសារការថយចុះធនធានជលផលក្នុងអាងទន្លេមគង្គភាគខាងក្រោមរបស់ប្រទេសជាសមាជិកទាំងបួន។ របាយការណ៍សម្រាប់ថ្នាក់តំបន់ កំពុងត្រូវបានរៀបចំ នឹងត្រូវបញ្ចប់នៅដើមឆ្នាំ២០១៦។
- បានធ្វើកិច្ចសហការជាមួយបណ្តាញវារីវប្បកម្មអាស៊ាន (NACA) ដើម្បីបញ្ចប់របាយការណ៍ និងក្រមប្រតិបត្តិ(Codes of Practice ) កំរិតតំបន់សម្រាប់អនុវត្តលើការធ្វើចលនានៃពពួក សរីរាង្គរស់នៅក្នុងទឹកឆ្លងដែននៅក្នុងអាងទន្លេមេគង្គភាគខាងក្រោម។
- បានផ្តល់យោបល់ និងអនុម័តរបាយការណ៍សកម្មភាពថ្នាក់ជាតិស្តីពីការគ្រប់គ្រងជលផលឆ្លងដែនរវាងខេត្តបកែវប្រទេសឡាវនិងខេត្តឈៀងម៉ៃប្រទេសថៃ និងរវាងខេត្តព្រៃវែងប្រទេសកម្ពុជានិងខេត្តដុងថាប់ប្រទេសវៀតណាម។
- បានបញ្ចប់ធ្វើការពិគ្រោះយោបល់ថ្នាក់ជាតិលើសេចក្តីព្រាងឯកសារយុទ្ធសាស្រ្តគ្រប់គ្រងជលផលក្នុងអាងទន្លេ (BFMS)។ អនុសាសន៍នៅក្នុងកិច្ចប្រជុំថ្នាក់ជាតិ នឹងត្រូវប្រើសម្រាប់កែសម្រួលឯកសារយុទ្ធសាស្រ្តក្នុងកំរិតតំបន់ នឹងដាក់ឆ្លងយោបល់ពីប្រទេសជាសមាជិកនៅក្នុងកិច្ចប្រជុំថ្នាក់តំបន់។
- បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលបច្ចេកទេសលើការគ្រប់គ្រង និងមូលដ្ឋានទិន្នន័យស្តីពីការសិក្សាទិន្នផលត្រីនៅតាមទីកន្លែងនេសាទ។
- បានផ្តល់យោបល់ និងអនុម័តរបាយការណ៍ថ្នាក់ជាតិស្តីពីបទពិសោធន៍ និងមេរៀននៃការអនុវត្តន៍ផែនការគ្រប់គ្រងតំបន់សហគមន៍នេសាទក្នុង ឃុំពត់ស ស្រុកបាទី ខេត្តតាកែវ ប្រទេសកម្ពុជា។

- បានផ្លាស់ប្តូរបទពិសោធន៍ និងធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលាបណ្តុះបណ្តាដែលបានរៀបចំដោយអាជ្ញាធរទន្លេសាប ស្តីពីវិធីសាស្រ្តនៃការវាយតម្លៃផលចាប់ដោយដាយត្រីនៅក្នុងប្រទេសកម្ពុជា។

*បញ្ហាប្រឈម*

ការអនុវត្តសកម្មភាពក្នុងឆ្នាំ២០១៥ បានពន្យាពេលដោយសារការមិនមានការឯកភាពនិងអនុម័តលើផែនការប្រចាំឆ្នាំ២០១៥ ប៉ុន្តែមានភាពរលូនបន្ទាប់ផែនការប្រចាំឆ្នាំបានឯកភាព។ ទោះបីយ៉ាងក៏ដោយមានសកម្មភាពមួយចំនួនមិនត្រូវបានបញ្ចប់តាមផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៥ទេ ដោយសារកង្វះថវិកាមកពីការខាតបង់អត្រាផ្តូរប្រាក់របស់ប្រទេសដៃគូអភិវឌ្ឍន៍ និងការមិនផ្តល់ថវិកាដែលឯកភាព និងយល់ព្រមលើគម្រោងសំណើពីកម្មវិធី CCAI ហើយសកម្មភាពទាំងនោះរួមមានៈ

- ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ដើម្បីពិភាក្សានិងអនុម័តលើយុទ្ធសាស្រ្តការគ្រប់គ្រង និងការអភិវឌ្ឍន៍ជលផលក្នុងអាងទន្លេមេគង្គ (BFMS)។
- ការបញ្ចប់សកម្មភាពនិងរបាយការថ្នាក់តំបន់នៃការអនុវត្តគម្រោងគ្រប់គ្រងជលផលឆ្លងដែនរវាងខេត្តបកែវប្រទេសឡាវ និងខេត្តឈៀងម៉ៃប្រទេសថៃ និងរវាងខេត្តព្រៃវែងប្រទេសកម្ពុជា និងខេត្តដុងថាប់ប្រទេសវៀតណាម។
- ការបញ្ចប់សកម្មភាព និងរបាយការណ៍ថ្នាក់តំបន់នៃការសិក្សា និងអង្កេតលើស្ថានភាព និងនិន្នាការវារីវប្បកម្មក្នុងអាងទន្លេមេគង្គភាគខាងក្រោម។ សកម្មភាពនេះបានបញ្ចប់ត្រឹមតែការចុះប្រមូលទិន្នន័យនៅតាមទីកន្លែងដែលបានកំណត់ប៉ុណ្ណោះ។
- ការពិគ្រោះយោបលនិងអនុម័តលើសេចក្តីព្រាងផែនការធ្វើវិមជ្ឈការនៃសកម្មភាពការត្រួតពិនិត្យ និងតាមដានផលចាប់នៅក្នុងអាងទន្លេមេគង្គភាគខាងក្រោម ឆ្នាំ២០១៦-២០២០។
- ការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលបច្ចេកទេសដើម្បីពិនិត្យបញ្ចប់ព្រាងម៉ូដែលជលផល-ជលសាស្រ្តនិងរបៀបប្រើប្រាស់ម៉ូដែល។

*ផែនការការងារសម្រាប់ឆ្នាំ២០១៦*

- នឹងធ្វើការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលបច្ចេកទេសថ្នាក់តំបន់ស្តីពីការពិនិត្យការបញ្ចូលទិន្នន័យ ការវិភាគទិន្នន័យ និងការសរសេរបាយការណ៍នៃការសិក្សាស្រាវជ្រាវទិន្នផលត្រីនៅតាមទីកន្លែងនេសាទ។
- នឹងធ្វើការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ ដើម្បីពិភាក្សា និងអនុម័តលើយុទ្ធសាស្រ្តគ្រប់គ្រងជលផលក្នុងអាងទន្លេមេគង្គភាគខាងក្រោម(BFMS)។
- នឹងអនុវត្តផែនការធ្វើវិមជ្ឈការនៃការផ្ទេរសកម្មភាពត្រួតពិនិត្យ និងតាមដានផលចាប់ក្នុងអាងទន្លេមេកគង្គភាគខាងក្រោម ឆ្នាំ២០១៦-២០២០។

## ២. កម្មវិធីកសិកម្មនិងធារាសាស្ត្រ

*សមិទ្ធផលការងារសម្រេចបាន*

- បានបញ្ចប់របាយការណ៍ស្រាវជ្រាវ ស្តីពីគោលការណ៍ណែនាំ សម្រាប់សំណង់ប្រព័ន្ធធារាសាស្ត្រ ដែលមិនមានឧបសគ្គដល់ការចរាចរណ៍របស់ត្រី។ គោលបំណងនៃការសិក្សានេះ គឺដើម្បីស្វែងយល់អំពីផលប៉ះពាល់ នៃសំណង់ប្រព័ន្ធធារាសាស្ត្រ ដែលពុំមានជណ្តើរ ឬ ផ្លូវត្រីឆ្លងកាត់ពីផ្នែកខ្សែទឹកខាងក្រោម ទៅកាន់ខ្សែទឹកខាងលើ និងបានកំណត់ពីរបៀបធ្វើឱ្យប្រសើរឡើងផ្លូវត្រីឆ្លងកាត់ ដោយពុំមានឧបសគ្គ ដែលអាចបង្កើនតម្លៃនៃធនធានជលផលទាំងនោះ។
- បានបញ្ចប់របាយការណ៍ស្រាវជ្រាវ នៃការប្រមូលទិន្នន័យ សម្រាប់ការវាយតម្លៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ទៅលើសន្តិសុខស្បៀងក្នុងអាងទន្លេមេគង្គក្រោម។ គោលបំណងនៃការសិក្សាពីការវាយតម្លៃផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុលើសន្តិសុខស្បៀងនេះ គឺដើម្បីកំណត់តំបន់ដែលងាយរងគ្រោះ និងវាយតម្លៃភាពងាយរងគ្រោះ បង្កើនសមត្ថភាពការយល់ដឹងដល់បណ្តាប្រទេសជាសមាជិក ដើម្បីបន្សាំទៅនឹងផលប៉ះពាល់ នៃបម្រែបម្រួលអាកាសធាតុទៅលើសមាសភាគសំខាន់ៗ នៃសន្តិសុខស្បៀង។
- បានបញ្ចប់របាយការណ៍ស្រាវជ្រាវ នៃការសិក្សា ការប្រើប្រាស់ទឹកក្រោមដីសម្រាប់កសិកម្មក្នុងប្រទេសកម្ពុជា។ ការសិក្សានេះមានការជីកអណ្តូងធ្វើតេស្ត សម្រាប់ប្រើប្រាស់ និងស្រោចស្រពនៅក្នុងខេត្តតាកែវ ដើម្បីរកព្រំដែននៃលំហូរទាំងខាងក្នុង និងខាងក្រៅ ជាពិសេសកំរិតនៃកំពស់ទឹក។ ទន្ទឹមនឹងនេះក៏មានការធ្វើតេស្តគុណភាពទឹកក្រោមដីផងដែរដោយប្រើប៉ារ៉ាម៉ែត្រមួយចំនួន។ គោលបំណងនៃការសិក្សានេះគឺដើម្បីអភិវឌ្ឍ និងផលិតផែនទីសុវត្ថិភាពទឹកក្រោមដី និងវាយតម្លៃពីនិរន្តរភាពទឹកក្រោមដីនាពេលបច្ចុប្បន្ន និងអនាគត។
- បានបញ្ចប់របាយការណ៍ស្រាវជ្រាវ ស្តីពីផលប៉ះពាល់នៃការធ្វើអាជីវកម្មរ៉ែ ទៅលើការប្រើប្រាស់ដីកសិកម្មសម្រាប់ការសិក្សារបស់ក្រុមប្រឹក្សា (MRC-Council Study)។ គោលបំណងនៃការសិក្សានេះ គឺដើម្បីសិក្សារកឲ្យឃើញនូវផលប៉ះពាល់ពីការជីករ៉ែគ្រប់ប្រភេទនៅលើដី និងការហូរច្រោះ ដែលធ្វើឲ្យប៉ះពាល់ដល់ការប្រើប្រាស់ដីកសិកម្ម។
- បានបញ្ចប់របាយការណ៍ស្រាវជ្រាវស្តីពីបម្រែបម្រួលនៃការប្រើប្រាស់ដីកសិកម្មក្នុងប្រទេសកម្ពុជា សម្រាប់ការសិក្សារបស់ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ (MRC-Council Study) ។ គោលបំណងនៃការសិក្សានេះគឺដើម្បីស្រាវជ្រាវរកនូវទំហំ ការប្រែប្រួលនៃការដាំដុះសម្រាប់ដីកសិកម្ម កំណត់នូវទិសដៅ និងផែនការអភិវឌ្ឍន៍ប្រកបដោយភាពជឿជាក់។

២០១៦ (ខែកុម្ភៈ ឬមីនា)។ មានបញ្ហាប្រឈមខ្លះៗពាក់ព័ន្ធការអនុវត្តន៍សកម្មភាពរបស់ជំនាញការថ្នាក់ជាតិដោយរយៈពេលនៃការអនុវត្តសកម្មភាពខ្លី ហើយទំហំការងារច្រើន ដូច្នេះមានការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍បញ្ចប់របស់ពួកគេ។

*ផែនការការងារសម្រាប់ឆ្នាំ២០១៦*

ក្នុងឆ្នាំ២០១៦នេះ កម្មវិធី AIP បានបន្តសកម្មភាពមួយចំនួនពីឆ្នាំ២០១៥ និងមានសកម្មភាពថ្មីមួយចំនួនទៀតដែលត្រូវអនុវត្ត។

## ៣. កម្មវិធីនិរន្តរភាពវារីអគ្គិសនី

**សមិទ្ធផលការងារសម្រេចបាន ៖**

- បានជ្រើសរើសទីប្រឹក្សាជាតិផ្នែកវារីអគ្គិសនីសម្រាប់ជួយគាំទ្របច្ចេកទេសអនុវត្តកម្មវិធី Council Study
- បានជ្រើសរើសទីប្រឹក្សាជាតិសម្រាប់គម្រោង RSAT និង ISH0306 សម្រាប់ឆ្នាំ២០១៥
- បានបង្កើតឧបករណ៍សម្រាប់ការកសាងផែនការ និងការគ្រប់គ្រង ដើម្បីជួយកំណត់នូវផលប៉ះពាល់ពីវារីអគ្គិសនីក្នុងការការពារតំបន់ប្រព័ន្ធអេកូឡូស៊ីដែលងាយរងគ្រោះ ការធ្វើឱ្យមាននិរន្តរភាពវារីអគ្គិសនី និងការកំណត់ព្រំដែនផលប៉ះពាល់លើបរិស្ថាន និងសេដ្ឋកិច្ច សង្គម នៅពេលដែលវារីអគ្គិសនីត្រូវបានអភិវឌ្ឍ
- លទ្ធផលនៃករណីសិក្សានៅទន្លេស្រែពក និងការកែសម្រួលនូវឧបករណ៍ Hydropower Planning Support Tool (HPST) ដែលឧបករណ៍នេះប្រើប្រាស់សម្រាប់ការវាយតម្លៃទៅលើសេដ្ឋកិច្ច សង្គម និងបរិស្ថាន
- គោលការណ៍ណែនាំ និងវិធានការអនុវត្តន៍ដ៏ប្រសើរនៃការបន្ធូរបន្ថយផលប៉ះពាល់សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពនៃទំនប់វារីអគ្គិសនីក្នុងអាងទន្លេមេគង្គក្រោម និង ដៃទន្លេទៅលើរបាយការណ៍ដំបូងនៃនិរន្តភាពវារីអគ្គីសនីគម្រោង ISH0306
- ឧបករណ៍វាយតម្លៃដោយរហ័សនៃនិរន្តរភាពវារីអគ្គីសនីរបស់គណៈកម្មការទន្លេមេគង្គ RSAT ត្រូវបានអនុវត្តក្នុងអាងស្ទឹងពោធិ៍សាត់
- គោលការណ៍ណែនាំ សម្រាប់កាត់បន្ថយផលប៉ះពាល់ និងការគ្រប់គ្រងហានិភ័យនៃទំនប់វារីអគ្គិសនីនៅលើទន្លេមេ និងដៃទន្លេមេគង្គក្រោម ទៅលើរបាយការណ៍ដំបូងនៃជម្រើសក្នុងការកាត់បន្ថយផលប៉ះពាល់ ដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍វារីអគ្គិសនីនៅទន្លេមេគង្គ។

## ៤. កម្មវិធីបរិស្ថាន

### សមិទ្ធផលការងារសម្រេចបាន ៖

- សៀវភៅណែនាំសម្រាប់ពិសោធន៍គុណភាពទឹក (Manual for Water Quality Laboratory) ត្រូវបានរៀបរៀងដោយ លោកស្រី ញឹម សុភា អ្នកជំនាញការថ្នាក់ជាតិ ដែលមានជាភាសាខ្មែរ និងអង់គ្លេស ត្រូវបានបញ្ចប់ក្នុង ខែវិច្ឆិកា ឆ្នាំ២០១៥។ ក្នុងគោលបំណង ដើម្បីពិពណ៌នាអំពីប្រព័ន្ធនៃការធានាគុណភាព (Quality Assurance) និងប្រព័ន្ធត្រួតពិនិត្យគុណភាព (Quality Control)
- និយាមនីតិវិធីប្រតិបត្តិស្តីពីនីតិវិធីគុណភាពទឹក (Standard Operation Procedures for Water Quality) ត្រូវបានរៀបរៀងដោយ លោកស្រី ញឹម សុភា អ្នកជំនាញការថ្នាក់ជាតិ ដែលមានជាភាសាខ្មែរ និងអង់គ្លេស ត្រូវបានបញ្ចប់ក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ ដោយបានរៀបរៀងរួមមានរចនាសម្ព័ន្ធ និងនីតិវិធីក្នុងការអនុវត្តន៍ការគ្រប់គ្រងនៃមន្ទីរពិសោធន៍ និងដើម្បីផ្តល់អោយក្រសួងធនធានទឹកនិងឧតុនិយម (MOWRAM) សម្រេចបាននូវបេសកកម្មរបស់គណៈកម្មការទន្លេមេគង្គ (MRC) ។ គោលការណ៍ប្រតិបត្តិការងារគឺប្រកបដោយវិជ្ជាជីវៈ និងសមស្របតាមបទដ្ឋានអន្តរជាតិ (ISO17025) ក្នុងគោលបំណងផ្តល់នូវសេវាកម្មប្រកបដោយគុណភាពខ្ពស់
- របាយការណ៍បណ្តាញត្រួតពិនិត្យគុណភាពទឹក (Water Quality Monitoring Network) ដែលមានចំនួនសរុប១៩ស្ថានីយ៍ ដែលស្ថិតនៅតាមដងទន្លេមេគង្គ ដោយក្នុងនោះ (៦ស្ថានីយ៍តាមទន្លេមេគង្គ) (៣ស្ថានីយ៍តាមទន្លេបាសាក់) (២ស្ថានីយ៍ក្នុងបឹងទន្លេសាប) (៣ស្ថានីយ៍ ទន្លេសាប) និង (3S ៥ស្ថានីយ៍)
- របាយការណ៍ស្តីពីការត្រួតពិនិត្យសុខភាពប្រព័ន្ធអេកូឡូស៊ីឆ្នាំ២០១៥(Report on Ecological Health Monitoring in Cambodia 2015)។ គោលបំណងរួមនៃរបាយការណ៍គឺដើម្បីតាមដានអំពីសុខភាពប្រព័ន្ធអេកូឡូស៊ីរបស់ប្រព័ន្ធទន្លេមេគង្គ



*សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់តំបន់ស្តីពី*



*ទស្សនៈកិច្ចថ្នាក់តំបន់ក្នុងការផ្លាស់ប្តូរបច្ចេកទេស*

- របាយការណ៍ស្តីពីការត្រួតពិនិត្យផលប៉ះពាល់សង្គមនិងការវាយតម្លៃភាពងាយរងគ្រោះ (Report on Social Impact Monitoring and Vulnerabilty Assessment (SIMVA) Survey 2014 on Shocks and Trends, and Case Study in the Lower Mekong Basin Corridor in Cambodia)



*សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិដើម្បីបង្កើនការយល់ដឹងរបស់មន្ត្រីមន្ទីរពិសោធន៍ស្តីពី ISO/IEC17025 និងតម្រូវការរបស់ ISO/IEC17025*



*សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិស្តីពីការធានាគុណភាពលើការយកសំណាកទឹកនិងការថែរក្សាសំណាកនៅបឹងទន្លេសាប ខេត្តសៀមរាប*

## បញ្ហាប្រឈម

កម្មវិធីបរិស្ថាន ក្នុងឆ្នាំ២០១៥ មានសកម្មភាពមួយចំនួនដែលត្រូវអនុវត្តហើយមានសកម្មភាពខ្លះក៏បានចប់ចុងឆ្នាំ២០១៥។ មានបញ្ហាប្រឈមខ្លះៗពាក់ព័ន្ធការអនុវត្តគម្រោង Biodiversity Indicator Monitoring (BIM) ត្រូវបានផ្អាក់តំបន់ធ្វើការពន្យារពេលសម្រាប់ការអនុវត្តគម្រោងរហូតដល់មានថវិកា។

## ផែនការការងារសម្រាប់ឆ្នាំ២០១៦

ក្នុងឆ្នាំ២០១៦នេះ កម្មវិធីបរិស្ថាន កំពុងតែបន្តការងាររបស់ខ្លួនពីឆ្នាំ២០១៥ ដោយពុំមានសកម្មភាពថ្មីសម្រាប់អនុវត្តទេ។

# ៥. កម្មវិធីប្រែប្រួលអាកាសធាតុនិងការបន្សាំ

## សមិទ្ធផលការងារសម្រេចបាន

- ចងក្រងនិងសង្ខេបនូវ៖
  - ផែនការយុទ្ធសាស្រ្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា (២០១៤-២០២៣)
  - ផែនការយុទ្ធសាស្រ្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យសំខាន់ៗចំនួន ០៨នៅកម្ពុជា រួមមាន៖ ទី១-គ្រប់គ្រងគ្រោះមហន្តរាយ ទី២-អប់រំ ទី៣-ថាមពលនិង

ឧស្សាហកម្ម ទី៤-សុខាភិបាល ទី៥-អភិវឌ្ឍជនបទ ទី៦-គមនាគមន៍ ទី៧-ធនធានទឹក និងទី៨-កសិកម្ម កសិ-ឧស្សាហកម្ម ផលិតកម្មសត្វពាហនៈ ជលផល និងព្រៃឈើ
  - សកម្មភាពគម្រោងសំខាន់ៗពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។
- បានទទួលទិន្នន័យពពួកសត្វស្លាប និងពពួកថលជលិក (ពពួកសត្វដែលរស់ក្នុងទឹកក៏បានលើគោកក៏បាន) ដែលមានលើពិភពលោកពី MRC
- គម្រោងបង្ហាញសាកល្បងលើកទី២ស្តីពី "*ការកសាងសមត្ថភាពសហគមន៍រស់នៅក្នុងតំបន់រងគ្រោះដោយទឹកជំនន់ និងភាពរាំងស្ងួត ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ*" ខេត្តព្រៃវែង
- របាយការណ៍បញ្ចប់គម្រោងជំហានទី១ ចំនួន៤ របស់បណ្តាប្រទេសជាសមាជិក
- ក្បួន និងឧបករណ៍សម្រាប់ការរៀបចំផែនការបន្សាំរបស់ CCAI
- ឯកសារមេរៀននៃសកម្មភាពកសាងសមត្ថភាពទាំងអស់
- របាយការណ៍ចំនួន៤ ស្តីពីការសិក្សា ពិនិត្យឡើងវិញ ឯកសារពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងការបន្សាំក្នុងបរិស្ថានទឹក របស់ប្រទេសជាសមាជិកនីមួយៗ។
- ឯកសារទស្សនៈទានស្តីពីការបង្កើតមូលដ្ឋានទិន្នន័យ និងប្រព័ន្ធត្រួតពិនិត្យ និងរាយការណ៍ពីការប្រែប្រួលអាកាសធាតុ និងការបន្សាំក្នុងអាងទន្លេមេគង្គក្រោម




***កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់លើកទី២ស្តីពីការបង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាពបន្សាំមេគង្គ***



***កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់លើកទី២ស្តីពីការវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើប្រព័ន្ធអេកូឡូស៊ីក្នុងអាងទន្លេមេគង្គ***

- ឯកសារការងារស្តីពីការសិក្សាពិនិត្យឡើងវិញប្រព័ន្ធត្រួតពិនិត្យការប្រែប្រួលអាកាសធាតុ និងសូចនាករការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់ និងការបន្សាំ
- ឯកសារការងារស្តីពីសូចនាករសម្រាប់ប្រព័ន្ធត្រួតពិនិត្យនិងរាយការណ៍ពីការប្រែប្រួលអាកាសធាតុក្នុងអាងទន្លេមេគង្គក្រោម

- ឯកសារទស្សនៈទាននៃរបាយការណ៍ដំបូងស្តីពីស្ថានភាពការប្រែប្រួលអាកាសធាតុ និងការបន្សាំក្នុងអាងទន្លេមេគង្គក្រោម
- ផែនទីចង្អុលផ្លូវសម្រាប់កសាងយុទ្ធសាស្ត្របន្សាំ និងផែនការសកម្មភាពមេគង្គ (MASAP)



*កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការកំណត់និងការវិភាគសេណារីយ៉ូការប្រែប្រួលអាកាសធាតុដើម្បីវាយតម្លៃផលប៉ះពាល់នៅក្នុងអាងទន្លេមេគង្គក្រោម*



*កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីគោល-យោបាយការប្រែប្រួលអាកាសធាតុនិងការបន្សាំក្នុងប្រទេសកម្ពុជា*

## បញ្ហាប្រឈម

ការគ្រប់គ្រង និងអនុវត្តន៍កម្មវិធីជាទូទៅគឺអាចធ្វើបានល្អ ប៉ុន្តែដោយមានបញ្ហាប្រឈមមួយចំនួនបានធ្វើឲ្យកិច្ចការនេះមានការរអាក់រអួលដោយអន្លើ មានជាអាទិ៍៖ កម្មវិធីត្រូវបានរៀបចំផែនការដើម្បីអនុវត្តន៍ទៅតាមការរំពឹងទុកក៏ ប៉ុន្តែដោយប្រឈមនឹងការកែទម្រង់ការគ្រប់គ្រងនិងរចនាសម្ព័ន្ធរបស់គណៈកម្មការទន្លេមេគង្គបានធ្វើឲ្យកិច្ចការមួយចំនួនធំត្រូវតែធ្វើការបញ្ចប់ដោយបង្ខំ ដែលជាហេតុធ្វើឲ្យសមិទ្ធិផលទទួលបានអាចនឹងមិនមានគុណភាពល្អដូចការគ្រោងទុកកិច្ចការមួយចំនួន គឺជាកិច្ចការដែលត្រូវអនុវត្តរួមគ្នាជាមួយនឹងបណ្តាកម្មវិធីពាក់ព័ន្ធដូចនេះគឺត្រូវរង់ចាំធាតុចូលពី បណ្តាកម្មវិធីពាក់ព័ន្ធទាំងនោះដែលជាហេតុធ្វើឲ្យមានការយឺតយ៉ាវកិច្ចការមួយចំនួនគឺត្រូវបានចាត់ជាការទទួលខុសត្រូវរបស់អ្នកជំនាញការជាតិ ហើយដោយហេតុកិច្ចសន្យារបស់ជំនាញការជាតិនេះត្រូវបានបញ្ចប់ត្រឹមដំណាច់ឆ្នាំ២០១៥ហើយគាត់មិនទាន់បញ្ចប់កិច្ចការដែលគាត់ទទួលខុសត្រូវបានទាំងស្រុងគឺធ្វើឲ្យកិច្ចការរបស់កម្មវិធីដែលមានការពាក់ព័ន្ធយឺតយ៉ាវ។

### ផែនការការងារសម្រាប់ឆ្នាំ២០១៦

ដោយមូលហេតុថាមិនទាន់ដឹងច្បាស់ឬពុំអាចវាយតម្លៃជាមុនបានអំពីលទ្ធផលនៃការកែទម្រង់ការគ្រប់គ្រងនិងរចនាសម្ព័ន្ធរបស់គណៈកម្មការទន្លេមេគង្គហេតុនេះគឺមានការលំបាកក្នុងការកំណត់ទិសដៅឬផែនការការងារនៅជំហានបន្ទាប់របស់កម្មវិធី។ ជារួមសម្រាប់ទិសដៅបន្តនៃកិច្ចការប្រែប្រួលអាកាសធាតុនិងការបន្សាំគឺត្រូវមានភាពទន់ភ្លន់ទៅតាមលទ្ធផលនៃការកែទម្រង់ការគ្រប់គ្រងនិងរចនាសម្ព័ន្ធរបស់

## ៦. កម្មវិធីនាវាចរ

### សមិទ្ធផលការងារសម្រេចបាន ៖

- បានបោះពុម្ព និងចែកចាយឯកសារគម្រោងគ្រប់គ្រងទំនិញគ្រោះថ្នាក់តាមដងទន្លេមេគង្គ ទៅគ្រប់ក្រសួងស្ថាប័ន និងអ្នកពាក់ព័ន្ធសំខាន់ៗ។ ឯកសារទាំងនោះ រួមមាន៖
  - ផែនការសកម្មភាពដឹកជញ្ជូនប្រកបដោយនិរន្តរភាពនៃបណ្តាទំនិញដែលប្រកបដោយគ្រោះថ្នាក់នៅតាមដងទន្លេមេគង្គ
  - គោលការណ៍ណែនាំសម្រាប់ការទុកដាក់ និងការផ្ទេរទំនិញដែលប្រកបដោយគ្រោះថ្នាក់ សម្រាប់បណ្តាកំពង់ផែនៅប្រទេសកម្ពុជា និងប្រទេសវៀតណាម
  - គោលការណ៍ណែនាំគ្រប់គ្រងកាកសំណល់សម្រាប់បណ្តាកំពង់ផែនៅប្រទេសកម្ពុជា និងប្រទេសវៀតណាម
  - ភាគទី១៖ បញ្ជីអធិការកិច្ចបណ្តានាវាសម្រាប់បណ្តាកំពង់ផែនៅប្រទេសកម្ពុជា និងប្រទេសវៀតណាម
  - ភាគទី២៖ បញ្ជីអធិការកិច្ចបណ្តានាវាសម្រាប់បណ្តាកំពង់ផែនៅប្រទេសកម្ពុជា និងប្រទេសវៀតណាម

- បានបញ្ចប់សេចក្តីព្រាងរបាយការណ៍គម្រោងផែនការមេដឹកជញ្ជូនផ្លូវទឹកតាមដងទន្លេមេគង្គ និងបានត្រៀមបញ្ជូនទៅក្រសួងជំនាញ ដើម្បីពិនិត្យ និងផ្តល់យោបល់បន្ថែម។ ឯកសារទាំងនោះ រួមមាន៖
  - ភាគទី១៖ ស្ថានភាពគោល ការព្យាករណ៍ សេណារីយ៉ូអភិវឌ្ឍន៍ និងផែនការសកម្មភាព
  - ភាគទី២៖ Volume II: បញ្ជីសកម្មភាពគម្រោងវិនិយោគ



*សិក្ខាសាលាថ្នាក់តំបន់លើកដំបូង ស្តីពីគម្រោងផែនការសម្រាប់ការដឹកជញ្ជូនតាមផ្លូវទឹកក្នុងអាងទន្លេមេគង្គភាគខាងក្រោម*



*សិក្ខាសាលាថ្នាក់តំបន់លើកចុងក្រោយ ស្តីពីគម្រោងផែនការមេដឹកជញ្ជូនផ្លូវទឹក*



*សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីពិនិត្យលើសេចក្តីព្រាងឯកសារគម្រោងផែនការមេដឹកជញ្ជូនផ្លូវទឹកក្នុងអាងទន្លេមេគង្គភាគខាងក្រោម*

## បញ្ហាប្រឈម

កង្វះថវិកាសម្រាប់ដំណើរការកម្មវិធីដែលជាហេតុនាំអោយពុំមានផែនការសកម្មភាព និងផែនការថវិកាសម្រាប់អនុវត្តសកម្មភាពនៅថ្នាក់ជាតិ។ ដៃគូអភិវឌ្ឍន៍ពុំសូវមានចំណាប់អារម្មណ៍លើការងាររបស់វិធីនេះដូចកម្មវិធីដទៃទៀត ហើយការងារនេះក៏ពុំមែនជាវិស័យអាទិភាពក្នុងការងាររបស់រដ្ឋាភិបាលកម្ពុជា។ ជារួមកម្មវិធីនាវាចរណ៍នៅថ្នាក់ជាតិពុំសូវមានសកម្មភាពច្រើនដូចកម្មវិធីដទៃនោះទេ ដោយសារពុំមានផែនការសកម្មភាពប្រចាំឆ្នាំហើយសកម្មភាពទាំងនោះត្រូវបាននាំមុខដោយក្រុមការងារកម្មវិធីនាវាចរណ៍នៅថ្នាក់តំបន់។ ការកសាងសមត្ថភាពគឺមានតិចតួចបំផុត មិនឆ្លើយតបនឹងតម្រូវការជាក់ស្តែងនៅថ្នាក់ជាតិ។

គណៈកម្មការទន្លេមេគង្គ។ អ្វីដែលជាកត្តាសំខាន់គឺចាំបាច់ត្រូវបន្តកិច្ចការកសាងសមត្ថភាពនិងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុ នៅថ្នាក់ក្រោមជាតិដែលបាននិងកំពុងដំណើរការ ហើយប្រសិនបើអាចគឺបន្តកិច្ចការនៃគម្រោងអនុវត្តន៍បង្ហាញនៅមូលដ្ឋានស្តីពីការប្រែប្រួលអាកាសធាតុ និងការបន្សាំ ដើម្បីទទួលបានបន្ថែមទៀតនូវ មេរៀនបទពិសោធន៍ ចំណុចខ្លាំង ចំណុច

ខ្សោយ ការអនុវត្តល្អៗនិងពង្រឹងពង្រីកការយល់ដឹងនិងសមត្ថភាពបន្សាំរបស់ប្រជាសហគមន៍មូលដ្ឋានតាមស្មារតីនៃវេទិកាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

**ផែនការការងារសម្រាប់ឆ្នាំ២០១៦**

- ផ្ទេរអូប័រនិងចំណេតផែទៅក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីប្រើប្រាស់ក្នុងការងារសុវត្ថិភាពនាវាចរណ៍តាមដងទន្លេមេគង្គ។
- ចែកចាយឯកសារគម្រោងផែនការមេដឹកជញ្ជូនផ្លូវទឹកតាមដងទន្លេមេគង្គ ដែលគ្រោងនឹងបោះពុម្ពទៅក្រសួងជំនាញ និងអ្នកពាក់ព័ន្ធសម្របសម្រួលក្នុងគម្រោងផែនការមេដឹកជញ្ជូនផ្លូវទឹកដែលអនុវត្តដោយស្ថាប័នជំនាញ។
- សម្របសម្រួលលើការងារជម្រុញការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនផ្លូវទឹកដែលអនុវត្តដោយគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គក្នុងក្របខណ្ឌគណៈកម្មការទន្លេមេគង្គ
- បន្តសហការ និងចូលរួមក្នុងការពិនិត្យ និងផ្តល់យោបល់លើផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍តាមដងទន្លេមេគង្គ។

# ៥. ទិសដៅការងារសម្រាប់ឆ្នាំ២០១៦

សម្រាប់ឆ្នាំ២០១៦នេះ បណ្តានាយកដ្ឋានចំណុះអោយអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក នឹង អនុវត្តផែនការការងាររបស់ខ្លួន ដោយផ្អែកលើផែនការសកម្មភាពការងារប្រចាំឆ្នាំ២០១៦របស់គណៈកម្មការទន្លេមេគង្គ។ ផែនការសកម្មភាពការងារ ដែលត្រូវអនុវត្តសម្រាប់ឆ្នាំ២០១៦ ជាសង្ខេបរួមមាន៖

**លទ្ធផលទី១៖ បង្កើនប្រសិទ្ធភាពនៃការអនុវត្តន៍ផែនការជាតិ គម្រោង និងការប្រើប្រាស់ធនធានដោយផ្អែកលើទស្សនៈអាងទន្លេទាំងមូល**

<u>ផលសម្រេចទី១</u> ៖ *ការយល់ដឹងរួមគ្នា ក៏ដូចជាការយកទៅអនុវត្តនូវចំណេះដឹងជាមូលដ្ឋានជាក់ស្តែងនឹងមានការកើនឡើង ក្នុងចំណោមអ្នករៀបចំគោលនយោបាយ និងអ្នកធ្វើផែនការគម្រោង។*

ដើម្បីទទួលបាន <u>ផលសម្រេចទី១</u> នេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា នឹងសហការជាមួយលេខាធិការដ្ឋាន MRC ដើម្បីអនុវត្ត និងបញ្ចប់នូវការងារមួយចំនួនដូចខាងក្រោម:

- ការសិក្សាទាក់ទាងនឹងដំណាំ ដែលសមស្របទៅនឹងតំបន់រាំងស្ងួត (និងជំនន់) និងការប្រើប្រាស់ទឹកក្រោមដី។
- ការវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើ វិស័យ និងប្រធានបទសំខាន់ៗ មួយចំនួន។

- ការវាយតម្លៃសម្រាប់ការសិក្សារបស់ក្រុមប្រឹក្សា (ការផ្លាស់ប្តូរផ្នែកជលសាស្ត្រ ជីវៈធនធាន សង្គម សេដ្ឋកិច្ច និងផលប៉ះពាល់រួម) សម្រាប់ការអភិវឌ្ឍន៍ធនធានទឹក នាអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល (ធារាសាស្ត្រ កសិកម្មនិងការប្រើប្រាស់ដី វារីអគ្គិសនី ការផ្គត់ផ្គង់ទឹកសម្រាប់ការប្រើប្រាស់និងឧស្សាហកម្ម ការការពារទឹកជំនន់ និងនាវាចរ)។

<u>**ផលសម្រេចទី២**</u> ៖ *ការគ្រប់គ្រងបរិស្ថាន និងការការអភិវឌ្ឍធនធានទឹកប្រកបដោយនិរន្តរភាព ត្រូវបានអនុវត្តសមស្របដើម្បីជាប្រយោជន៍សម្រាប់អាងទាំងមូល ដោយបណ្តាស្ថាប័នថ្នាក់ជាតិទទួលបន្ទុកការងារផែនការ។*

ដើម្បីទទួលបាន <u>ផលសម្រេចទី២</u> នេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជានឹងសហការជាមួយលេខាធិការរដ្ឋាន MRC ដើម្បីអនុវត្ត និងបញ្ចប់នូវការងារមួយចំនួនដូចខាងក្រោមៈ

- ការអនុវត្តន៍យុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេ ២០១៦-២០២០

- ការអនុវត្តន៍ផែនការមេប្រចាំតំបន់ សម្រាប់ការដឹកជញ្ជូនផ្លូវទឹក

- ដោយប្រើប្រាស់ចំណេះដឹងបច្ចុប្បន្ននិងគោលការណ៍ណែនាំដែលមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេ ដើម្បីជម្រុញថែមទៀតលើការបែងចែកផលប្រយោជន៍និងការចំណាយកម្រិតថ្នាក់តំបន់ តាមរយៈគម្រោងរួមគ្នា និងគម្រោងជាតិដែលមានចរិកលក្ខណៈតំបន់។

- បញ្ចប់ការរៀបចំយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានជលផលសម្រាប់អាងទាំងមូល។ ជាពិសេសគឺការទទួលបានធាតុចូលចុងក្រោយនិងគំនិតយោបល់នានាពីគ្រប់បណ្តាអ្នកពាក់ព័ន្ធ។

- បញ្ចប់ការសិក្សាបឋម ស្តីពីហានិភ័យទឹកជំនន់ ដើម្បីជាជំនួយដល់ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងទឹកជំនន់ថ្នាក់តំបន់។

- ចាប់ផ្តើមរៀបចំយុទ្ធសាស្ត្រថ្នាក់តំបន់ សម្រាប់ការអភិវឌ្ឍវារីអគ្គិសនីប្រកបដោយនិរន្តរភាព

- ចាប់ផ្តើមរៀបចំយុទ្ធសាស្ត្រថ្នាក់តំបន់ សម្រាប់ការគ្រប់គ្រង និងការកាត់បន្ថគ្រោះរាំងស្ងួត នៅពេលការវាយតម្លៃត្រូវបានបញ្ចប់។

**<u>ផលសម្រេចទី៣</u>** ៖ *គោលការណ៍ណែនាំ សម្រាប់ការអភិវឌ្ឍន៍ និងការគ្រប់គ្រងទឹក និងគម្រោងនានាដែលពាក់ព័ន្ធនឹងធនធានទឹក នឹងត្រូវបែងចែកជូន និងយកទៅប្រើប្រាស់ដោយស្ថាប័នធ្វើផែនការ និងអនុវត្តផែនការ។*

- ប្រើប្រាស់លទ្ធផលដែលបានមកពីការរៀបចំគោលការណ៍ណែនាំសម្រាប់ការកាត់បន្ថយផលប៉ះពាល់បរិស្ថានដែលបណ្តាលមកពីការអភិវឌ្ឍន៍វារីអគ្គិសនី និងការគ្រប់គ្រងហានិភ័យ ដើម្បីធ្វើបច្ចុប្បន្នភាពលើ គោលការណ៍បឋមស្តីពីទំនប់វារីអគ្គិសនីលើទន្លេមេ ហើយបន្ទាប់មកនឹងយកទៅប្រើប្រាស់នាពេលអនាគតសម្រាប់ដំណើរការអនុវត្ត ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA)។

- ឧបករណ៍សម្រាប់ការវាយតម្លៃហ៍សលើនិរន្តរភាពវារីអគ្គិសនី នឹងយកទៅសាកល្បងនៅថ្នាក់ជាតិ និងកម្រិតឆ្លងដែន ដោយអាស្រ័យតាមសំណើរបស់ប្រទេសជាសមាជិក។ ឧបករណ៍នេះនឹងត្រូវបានកែសម្រួល ដោយអាស្រ័យលើការបញ្ចប់ការងារនិរន្តរភាពវារីអគ្គិសនី រួមមាន៖ សុវត្ថិភាពទំនប់ អនុតំបន់ដែលមានប្រព័ន្ធអេកូឡូស៊ីផុយស្រួយ ការបែងចែកប្រយោជន៍ពីថ្នាក់ជាតិទៅថ្នាក់តំបន់ ការវាយតម្លៃពហុបំណងរបស់គម្រោងវារីអគ្គិសនី និង ការកាត់បន្ថយផលប៉ះពាល់និងការគ្រប់គ្រងហានិភ័យ។

- បន្តការរៀបចំគោលការណ៍ណែនាំសម្រាប់ការវាយតម្លៃពីផលប៉ះពាល់បរិស្ថានឆ្លងដែន។

- បន្តការរៀបចំគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងផ្ទៃរងទឹកភ្លៀង (បង្កើនវិសាលភាពពីគម្រោងទៅការអនុវត្តក្នុងប្រទេសមួយ)។

- បន្តការរៀបចំគោលការណ៍ណែនាំសម្រាប់គម្រោងប្លង់ស្រោចស្រពដែលសមស្របជាមួយមច្ឆាជាតិ និងគម្រោងស្រោចស្រពដែលមានផលប៉ះពាល់ឆ្លងដែន។

- បន្តការរៀបចំគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងដីសើម។

## លទ្ធផលទី២ ៖ ការពង្រឹងសហប្រតិបត្តិការថ្នាក់តំបន់

**<u>ផលសម្រេចទី៤</u>** ៖ *បណ្តាប្រទេសជាសមាជិក នឹងអនុវត្តរាល់នីតិវិធីរបស់ MRC ប្រកបដោយប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ។*

ដើម្បីទទួលបាន <u>ផលសម្រេចទី៤</u> នេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជានឹងសហការជាមួយលេខាធិការដ្ឋាន MRC ដើម្បីអនុវត្តនូវការងារមួយចំនួនដូចខាងក្រោម៖

- អនុវត្តអោយបានពេញលេញនូវគោលការណ៍ណែនាំបច្ចេកទេសដែលបានឯកភាពនាពេលថ្មី ៗ នេះសម្រាប់នីតិវិធីគុណភាពទឹក។

- បញ្ចប់គោលការណ៍ណែនាំបច្ចេកទេស នៃនីតិវិធីស្តីពីការថែរក្សាជារទឹកលើទន្លេមេ ដែលត្រូវបានធ្វើបច្ចុប្បន្នភាពដោយផ្អែកលើការងាររយៈពេល០៥ឆ្នាំកន្លងមក ជាលក្ខណៈរៀនផងអនុវត្តផង។

- ពិនិត្យមើលនិងចងក្រង មេរៀនដែលបានរៀនសូត្រតាមរយៈការអនុវត្តន៍នីតិវិធីមួយចំនួនដូចជា៖ PNPCA, PDIES, និង PWUM ហើយលើកជាវិធានការណ៍កែសម្រួលដើម្បីអោយបណ្តានីតិវិធីទាំងនេះផ្សារភ្ជាប់យ៉ាងរឹងមាំជាមួយនឹងដំណើរការធ្វើផែនការអភិវឌ្ឍអាងទន្លេ។

- ចូលរួមអនុវត្តបណ្តានីតិវិធី តាមរយៈវេទិការួម (Joint Platform) និងក្រុមការងារបច្ចេកទេស (Technical Working Group) រួមទាំង ដំណើរការ PNPCA សម្រាប់គម្រោងវារីអគ្គិសនីមួយ

- ចូលរួមធ្វើបច្ចុប្បន្នភាព ផែនការអភិវឌ្ឍន៍សមត្ថភាពនិងសកម្មភាពដើម្បីត្រួសត្រាយផ្លូវសម្រាប់ការជម្រុញ នឹងការអភិវឌ្ឍន៍សមត្ថភាពក្នុងឆ្នាំ២០១៧ ដោយផ្អែកលើសេចក្តីត្រូវការជាក់ស្តែងរបស់ស្ថាប័នអនុវត្តការងារ។

**<u>ផលសម្រេចទី៥</u>** ៖ *ការសន្ទនា និងការសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព រវាងបណ្តាប្រទេសជាសមាជិក និងការចូលរួមប្រកបដោយយុទ្ធសាស្រ្តពីបណ្តាដៃគូថ្នាក់តំបន់ និងអ្នកជាប់ពាក់ព័ន្ធដទៃទៀត ក្នុងការគ្រប់គ្រងទឹកឆ្លងដែន*

- ជាដៃគូសហការ ការបែងចែកពត៌មាន និងការផ្លាស់ប្តូរបច្ចេកទេស ជាមួយប្រទេសចិន និងភូមា នឹងត្រូវបានកំណត់ជាអាទិភាព ពីព្រោះវាមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងអាងទាំងមូល។

- ក្របខ័ណ្ឌសហប្រតិបត្តិការថ្នាក់តំបន់ពីរដែលសំខាន់ដូចជា GMS និង ASEAN - ចូលរួមរៀបចំមេរៀនដែលបានរៀនសូត្រពីកិច្ចសហការក្នុងអតីតកាល ដោយធ្វើការវិភាគពីគោលបំណងរួម និងយន្តការសមស្របសម្រាប់កិច្ចសហប្រតិបត្តិការ។

- ចូលរួមរៀនចំ និងពិភាក្សាលើគំនិតគោលស្តីពីកាបង្កើត វេទិកាអ្នកពាក់ព័ន្ធថ្នាក់តំបន់នៅចុងឆ្នាំ២០១៦ ដោយមានយន្តការការងារច្បាស់លាស់ ដើម្បីអោយមានការចូលរួមពីបណ្តាក្រុមដែលមានការចាប់អារម្មណ៍ដូចជា វិស័យឯកជន ស្ថាប័នស្រាវជ្រាវបច្ចេកទេស ទាក់ទងការងារ MRC ក្នុងគោលបំណងជម្រុញការប្រើប្រាស់យុទ្ធសាស្រ្តនិងគោលការណ៍ណែនាំរបស់ MRC។

**លទ្ធផលទី៣ ៖ ការតាមដានត្រួតពិនិត្យ និងការទំនាក់ទំនងផ្តល់ព័ត៌មានប្រសើរជាងមុន ស្តីពីស្ថានភាពអាងទន្លេ**

**<u>ផលសម្រេចទី៦</u>** ៖ *ពង្រឹង ការតាមដានត្រួតពិនិត្យអាងទន្លេទាំងមូល ការព្យាករណ៍ ការវាយតម្លៃផលប៉ះពាល់ និងការចែកចាយលទ្ធផល ដើម្បីអោយប្រទេសជាសមាជិកអាចធ្វើសេចក្តីសម្រេចប្រសើរជាងមុន* ដើម្បីទទួលបាន <u>ផលសម្រេចទី៦</u> នេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជានឹងសហការជាមួយលេខាធិការដ្ឋាន MRC ដើម្បីអនុវត្តនូវការងារមួយចំនួនដូចខាងក្រោម:

- បន្តសហការជាមួយ MRCS ក្នុងការថែរក្សាប្រព័ន្ធត្រួតពិនិត្យ និងព្យាករណ៍ ឧបករណ៍ម៉ូដែល និងសមត្ថភាពប្រើប្រាស់។
  ការតាមដានត្រួតពិនិត្យអាងទន្លេរួមមាន៖ ឧតុ-ជលសាស្រ្ត គុណភាពទឹក កករ ជលផល ផលប៉ះពាល់សង្គមនិងភាពងាយរងគ្រោះ និងសុខភាពអេកូឡូសី។ ការព្យាករណ៍ទឹកជំនន់ថ្នាក់តំបន់ ទន្ទឹមគ្នានឹងការបង្កើតនិងដាក់អោយដំណើរការប្រព័ន្ធត្រួតពិនិត្យ និងព្យាករណ៍គ្រោះរាំងស្ងួតនៅឆ្នាំ២០១៦។
- បន្តសហការជាមួយ MRCS ក្នុងការថែរក្សា ក៏ដូចជាធ្វើបច្ចុប្បន្នភាពប្រព័ន្ធពត៌មាននិងទិន្នន័យថ្នាក់តំបន់ ដូចជា៖ ឧតុ-ជលសាស្រ្ត គុណភាពទឹក កករ ជលផល សេដ្ឋកិច្ចសង្គម វារីអគ្គិសនី ធារាសាស្រ្ត។ ការបញ្ចប់លើការរៀបចំរបាយការណ៍បឋមស្តីពីស្ថានភាពទន្លេ នៅដើមឆ្នាំ២០១៦។

លទ្ធផលទី៤ ៖ **អង្គការអាងទន្លេដែលមានទំហំតូចល្មម**

**<u>ផលសម្រេចទី៧</u>** ៖ *ដំណើរការអន្តរកាលរបស់ MRC/CNMC ឆ្ពោះទៅកាន់អង្គការអាងទន្លេមួយ ដែលមានប្រសិទ្ធភាពនិងប្រសិទ្ធផលដោយអនុលោមតាមផែនការវិធីស្តីពីវិមជ្ឈការ និងផែនការកំណែទម្រង់*

ដើម្បីទទួលបាន <u>ផលសម្រេចទី៧</u> នេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជានឹងសហការជាមួយលេខាធិការដ្ឋាន MRC ដើម្បីអនុវត្តនូវការងារមួយចំនួនដូចខាងក្រោម:

- សហការជាមួយ MRCS ក្នុងការរៀបចំនិងអនុវត្ត រចនាសម្ព័ន្ធថ្មីរបស់ MRCS ចាប់ពីខែកក្កដា ២០១៦ ក៏ដូចជាការជ្រើសរើសបុគ្គលិកថ្មី។
- សហការជាមួយ MRCS ក្នុងការបង្កើតនិងដាក់អោយដំណើការប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្មី ដើម្បីអោយស្របទៅនឹងគោលការណ៍កញ្ចប់ថវិការួម (Basket Funding)។

- ចូលរួមអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់តាមដានការអនុវត្តន៍ផែនកា យុទ្ធសាស្ត្រ និងផែនការចង្អុលបង្ហាញថ្នាក់ជាតិ។
- សហការជាមួយ MRCS ក្នុងការរៀបចំគំនិតគោលស្តីពីការបង្កើត និងដំណើរការក្រុមជំនាញការថ្នាក់តំបន់ (Regional Expert Group) នៅដំណាច់ឆ្នាំ២០១៦។

# ៦. ការវាយតម្លៃ និងសេចក្តីសន្និដ្ឋាន

បណ្តាសកម្មភាពការងារ និងសមិទ្ធផលសំខាន់ៗខាងលើ ដែលសម្រេចបានកន្លងមក គឺបានមកពីការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃពីសំណាក់ថ្នាក់ដឹកនាំរបស់រាជរដ្ឋាភិបាល និងការយកចិត្តទុកដាក់របស់មន្ត្រីរបស់ គ.ជ.ទ.ម.ក ដែលបានបំពេញភារកិច្ច និងកិច្ចសហការជាមួយបណ្តាប្រទេសជាសមាជិក **MRC** ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិយ៉ាងល្អប្រសើរ និងការអនុវត្តន៍កិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ដើម្បីសម្រេចបានផលប្រយោជន៍រួមក្នុងកិច្ចការពារ និងអភិវឌ្ឍន៍ធនធានប្រកបដោយនិរន្តរភាពក្នុងអាងទន្លេមេគង្គ។ បណ្តាសមិទ្ធផលដែលសម្រេចបាននេះបានបង្ហាញពីភាពជោគជ័យធំៗរបស់ គ.ជ.ទ.ម.ក ក្នុងការបំពេញភារកិច្ចសម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ និងនីតិវិធីទាំង៥ ព្រមទាំងបណ្តាកម្មវិធីរបស់ **MRC** ក្នុងការពង្រឹងកិច្ចសហការ និងការអភិវឌ្ឍរួមនៅក្នុងតំបន់ទន្លេមេគង្គ។ បណ្តាកម្មវិធី និងគម្រោងនានារបស់ **MRC** បានអនុវត្តដោយផ្តល់នូវផលប្រយោជន៍តាមវិស័យដែលជួយដល់ការធ្វើការសម្រេចចិត្តក្នុងប្រទេសនិមួយៗ និងក្នុងតំបន់ដើម្បីបន្តគាំទ្រដល់ការកែលម្អការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ។

នៅក្នុងឆ្នាំ២០១៥ យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ដើម្បីគាំទ្រ និងជម្រុញការរៀបចំ និងការអនុវត្តន៍ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ការការពារបរិស្ថាន និងការគ្រប់គ្រងអាងទន្លេមេគង្គប្រកបដោយនិរន្តរភាពនៅតាមបណ្តាប្រទេសជាសមាជិក។ ការពង្រឹងដំណើរការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព តាមរយៈយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ បានជួយដល់ការអនុវត្តន៍យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅឆ្ពោះទៅរកកិច្ចអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព និងជម្រុញសកម្មភាពអភិវឌ្ឍន៍នៅក្នុងតំបន់អោយកាន់តែមានថាមពល ក្នុងគោលបំណងអោយមានការរីកលូតលាស់និងការទទួលខុសត្រូវរួមគ្នាចំពោះសកម្មភាពអភិវឌ្ឍន៍អាងទន្លេមេគង្គទាំងមូល។

ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ នៅតាមប្រទេសជាសមាជិកត្រូវបានអនុវត្តតាមរយៈការអនុវត្តផែនការចង្អុលបង្ហាញរបស់ប្រទេសរៀងៗខ្លួន ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួង-ស្ថាប័នជាសមាជិក។ ចំពោះ គ.ជ.ទ.ម.ក បានដឹកនាំការសម្របសម្រួល រួមចំណែកឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គកម្ពុជា ដើម្បីរក្សាគុណភាពបរិស្ថាន ជម្រុញការរីកចម្រើនសេដ្ឋកិច្ច និងធានាសុវត្ថិភាពសង្គម។ ឆ្នាំ២០១៥ ជាឆ្នាំចុងក្រោយនៃការអនុវត្តន៍ផែនការ

អភិវឌ្ឍន៍យុទ្ធសាស្ត្រ ០៥ឆ្នាំ (២០១១-២០១៥) របស់ **MRC** ក៏ដូចជាសមាជិកដទៃទៀតកម្ពុជាបានបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការរួមចំណែកទទួលខុសត្រូវជាបណ្តើរៗ ក្នុងដំណើរឆ្ពោះទៅកាន់ឯករាជ្យភាពផ្នែកហិរញ្ញវត្ថុនៅឆ្នាំ ២០៣០ របស់ **MRC** តាមរយៈការអនុវត្តន៍ផែនទីបង្ហាញផ្លូវសម្រាប់ដំណើរការវិមជ្ឈការនៃមុខងារស្នូលគ្រប់គ្រងអាងទន្លេមេគង្គ ដែលប្រទេសជាសមាជិកទាំងអស់រួមជាមួយដៃគូអភិវឌ្ឍន៏បានឯកភាព ដូចដែលមានចែងក្នុងសេចក្តីប្រកាសរួមនៅក្នុងកិច្ចប្រជុំកំពូលរបស់ **MRC** លើកទី១នៅក្រុងហួហ៊ីន ប្រទេសថៃ នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ និងកិច្ចប្រជុំកំពូលលើកទី២ នៅក្រុងហូជីមិញ ប្រទេសវៀតណាម នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៤។

នៅក្នុងឆ្នាំ២០១៥ ទោះបីបានជួបនូវការលំបាកខ្លះៗ និងភាពប្រឈមមួយចំនួនដែលក្នុងនោះ គ.ជ.ទ.ម.ក បានប្រឹងប្រែងពង្រឹងសមត្ថភាពរបស់ខ្លួន ក៏ដូចជាទាញយកនូវបទពិសោធន៍ជាច្រើនដើម្បីរកដំណោះស្រាយជាយុទ្ធសាស្ត្រជាពិសេសលើកិច្ចការសំខាន់ៗមួយចំនួនដូចជា៖ បញ្ហាបម្រែបម្រួលអាកាសធាតុនិងការអភិវឌ្ឍវារីអគ្គិសនីតាមដងទន្លេមេគង្គ ដោយរក្សាបាននូវជំហរកិច្ចសហប្រតិបត្តិការបានល្អនៅក្នុងតំបន់ទាំងមូលក្នុងក្របខ័ណ្ឌ **MRC**។នៅក្នុងឆ្នាំ២០១៥ ទោះបីបានជួបនូវការលំបាកខ្លះៗ និងភាពប្រឈមមួយចំនួនដែលក្នុងនោះ គ.ជ.ទ.ម.ក បានប្រឹងប្រែងពង្រឹងសមត្ថភាពរបស់ខ្លួន ក៏ដូចជាទាញយកនូវបទពិសោធន៍ជាច្រើនដើម្បីរកដំណោះស្រាយជាយុទ្ធសាស្ត្រជាពិសេសលើកិច្ចការសំខាន់ៗមួយចំនួនដូចជា៖ បញ្ហាបម្រែបម្រួលអាកាសធាតុនិងការអភិវឌ្ឍវារីអគ្គិសនីតាមដងទន្លេមេគង្គ ដោយរក្សាបាននូវជំហរកិច្ចសហប្រតិបត្តិការបានល្អនៅក្នុងតំបន់ទាំងមូលក្នុងក្របខ័ណ្ឌ **MRC**។ ភាពប្រឈមសំខាន់មួយទៀតគឺកម្រិតយល់ដឹងអំពីទស្សនៈ និងការអនុវត្តន៍គោលការណ៍ **IWRM** នៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលទាមទារចាំបាច់អោយមានការយល់ដឹងទូលំទូលាយ ដើម្បីធានាបានការអភិវឌ្ឍន៏ប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គទាំងនៅកម្ពុជាក៏ដូចជាតំបន់។ កម្ពុជាមានច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកឆ្នាំ២០០៧ ដែលមានចែងក្នុងមាត្រា៤ អំពីការអនុវត្ត **IWRM** សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព។ ដូច្នេះការអនុវត្តច្បាប់តម្រូវឲ្យបង្កើនសមត្ថភាពមន្ត្រី និងជំនាញការជាតិក្នុងកិច្ចការនេះគឺមានសារៈសំខាន់ ដូចជាក្នុងផ្នែកអភិវឌ្ឍធនធានទឹកនិងធនធានពាក់ព័ន្ធ រួមមាន៖ ការអភិវឌ្ឍវារីអគ្គិសនី ផលិតកម្មកសិកម្ម ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ការពារបរិស្ថាន និងគុណភាពទឹក ដែលផ្អែកតាមគោលការណ៍ **IWRM**។

បណ្តាការងារផ្នែករដ្ឋបាល-ហិរញ្ញវត្ថុ បុគ្គលិក-បណ្តុះបណ្តាលអភិវឌ្ឍន៏ធនធានមនុស្ស ការងារកិច្ចសហប្រតិបត្តិការ និងការងារជំនាញបច្ចេកទេសរបស់នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានគ.ជ.ទ.ម.ក ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធជាសមាជិក និងលេខាធិការដ្ឋាន **MRC** បានដំណើការដូចប្រក្រតី ហើយដែលសម្រេចបានសមិទ្ធផលគួរអោយកត់សម្គាល់មួយចំនួន ដែលជាការឆ្លុះ

បញ្ចាំងនូវការខិតខំបំពេញការងារ និងសាមគ្គីភាពផ្ទៃក្នុងល្អរបស់មន្ត្រីរាជការ និងដោយមានកិច្ចសហការល្អ និងការចូលរួមពីគ្រប់ដៃគូពាក់ព័ន្ធ។

ទន្ទឹមនឹងសម្រេចបានសមិទ្ធផលនានាដូចបានបង្ហាញខាងលើ គ.ជ.ទ.ម.ក នៅក្នុងឆ្នាំ២០១៥ កន្លងទៅនេះក៏បានជួបប្រទះបញ្ហាលំបាក និងការប្រឈមមួយចំនួននៅក្នុងការបំពេញការងាររបស់ខ្លួន ហើយដែលត្រូវពុះពារបន្ថែមទៀត រួមមានៈ

សមត្ថភាព ចំណេះដឹង និងជំនាញព្រមទាំងកំរិតនៃការទទួលខុសត្រូវរបស់មន្ត្រីទទួលបន្ទុកគម្រោង/កម្មវិធីបំរើការនៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក នៅមានកម្រិតនៅឡើយក្នុងខណៈពេលដែលតម្រូវឲ្យមានការពង្រឹងប្រសិទ្ធការងារដើម្បីឈានឆ្ពោះទៅកាន់ស្វ័យភាព និងភាពជាម្ចាស់នៃការងារក្នុងក្របខណ្ឌ**MRC**នៅថ្នាក់ជាតិ។

ការឆ្លើយតបទៅនឹងសំណើរបស់ គ.ជ.ទ.ម.ក ពីក្រសួង-ស្ថាប័នជាសមាជិក និង សំណើពី **MRCS** ពេលខ្លះ មានការយឺតយ៉ាវ និងកៀកពេក ដែលធ្វើឲ្យ គ.ជ.ទ.ម.ក មិនអាចចាត់ចែងបន្តឲ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធិភាពខ្ពស់។

ការអនុវត្តគម្រោង និងកម្មវិធីខ្លះនៅថ្នាក់ជាតិ មានការយឺតយ៉ាវ ដោយសារមិនទាន់ត្រូវបានអនុម័តលើឯកសារគម្រោង និងកម្មវិធីក្នុងកម្រិតតំបន់ ព្រោះពិបាកក្នុងការកំណត់ពេលវេលាប្រជុំ។

ស្មារតីនៃកិច្ចសហប្រតិបត្តិមេគង្គពីប្រទេសជាសមាជិកទាំងបួនរបស់**MRC** នៅមានកម្រិតដោយសារបញ្ហាស្នូលសំខាន់ៗមួយចំនួនពុំទាន់ត្រូវបានដោះស្រាយដោយឈរលើស្មារតីយោគយល់គ្នាព្រោះថា ប្រទេសជាសមាជិកនីមួយៗតែងតម្កល់នូវផលប្រជាតិលើសផលប្រយោជន៍តំបន់។

ភាពមិនប្រាកដប្រជាដោយសារការយឺតយ៉ាវទៅលើការសម្រេចពីការកែទំរង់រចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន **MRC** ដែលនាំឲ្យជួបការលំបាកលើការសន្យាផ្តល់ជំនួយថវិកាពីដៃគូអភិវឌ្ឍន៏។

ក្នុងឆ្នាំ២០១៦ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា នឹងបន្តអនុវត្តការងាររបស់ខ្លួនដោយធ្វើការងារសម្របសម្រួល និងការងារសហប្រតិបត្តិការ អនុលោមទៅតាមផែនការការងារប្រចាំឆ្នាំ២០១៦ របស់**MRC** ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍០៥ឆ្នាំ របស់ គ.ជ.ទ.ម.ក (២០១៦-២០២០) និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ ០៥ឆ្នាំថ្មី របស់ **MRC** (២០១៦-២០២០) ដោយធ្វើការបន្សាំទៅនឹងរចនាសម្ព័ន្ធថ្មីរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ **MRC** ក្នុងការអនុវត្តន៏មុខងារស្នូលគ្រប់គ្រងអាងទន្លេ ជំនួសអោយការអនុវត្តន៏កម្មវិធី និងគម្រោងដែលធ្លាប់បានអនុវត្តកន្លងមក។ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា នឹងប្រើប្រាស់នូវមេរៀន ក៏ដូចជាបទពិសោធន៍ដែលទទួលបានកន្លងមក ដើម្បីដោះស្រាយជាមួយភាពប្រឈមនានា ដែលអាចកើតមាននៅឆ្នាំ២០១៦។

ដើម្បីអោយការអនុវត្តន៍ផែនការការងារប្រចាំឆ្នាំ២០១៦សម្រេចបានជោគជ័យកត្តាសំខាន់ៗមួយចំនួនដែលជាកំលាំងចលករួមជាមួយការដឹកនាំដ៏ត្រឹមត្រូវនិងឈ្លាសវៃពីសំណាក់ថ្នាក់ដឹកនាំ គ.ជ.ទ.ម.ក ដែលគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាត្រូវការចាំបាច់មានដូចជា៖

- បន្តការចូលរួមយ៉ាងសកម្ម និងគាំទ្រពេញលេញរបស់ក្រសួង-ស្ថាប័នជាសមាជិក
- បង្កើនការខិតខំរបស់មន្ត្រី និងបុគ្គលិក គ.ជ.ទ.ម.ក ប្រកបដោយស្មារតីទទួលខុសត្រូវ
- ពង្រឹងកិច្ចសហការល្អរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានគ.ជ.ទ.ម.ក និងលេខាធិការដ្ឋាន MRC
- មានកិច្ចសហការនិងការគាំទ្រផ្នែកហិរញ្ញវត្ថុពីបណ្តាប្រទេសផ្តល់ជំនួយលើមុខងារស្នូលនិងផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៦
- មន្ត្រីក្រសួង-ស្ថាប័នជំនាញបន្តការចូលរួមយ៉ាងសកម្មលើការងារបច្ចេកទេសដើម្បីអនុវត្តការងារអោយមានប្រសិទ្ធភាពរួមទាំងការគាំទ្រលើកទឹកចិត្តរបស់ថ្នាក់ដឹកនាំ
- MRC បន្តការគាំទ្រថវិកានិងបច្ចេកទេសដើម្បីអនុវត្តសកម្មភាពជាតិនៅថ្នាក់ជាតិ។

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានការរំពឹងទុក និងភាពជឿជាក់យ៉ាងរឹងមាំនៅក្នុងកិច្ចខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួនដោយសង្ឃឹមថានឹងមានកិច្ចសហការល្អនិងជិតស្និទ្ធពីគ្រប់ភាគីពាក់ព័ន្ធដើម្បីនាំមកនូវសមិទ្ធផលថ្មីៗបន្ថែមទៀតដែលជាការលើកកម្ពស់កិត្យានុភាពប្រទេសកម្ពុជានៅក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គនិងរួមចំណែកក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការ អនុវត្តន៍កិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គទាំងមូល៕

# ឧបសម្ព័ន្ធ

## តារាងព្រឹត្តិការណ៍ និងសកម្មភាពការងារប្រចាំឆ្នាំ២០១៥ របស់ គ.ជ.ឧ.ម.ក

# ឧបសម្ព័ន្ធ

## តារាងព្រឹត្តិការណ៍ និងសកម្មភាពការងាររបស់ គ.ជ.ទ.ម.ក

| ល.រ | កាលបរិច្ឆេទ | អធិប្បាយព្រឹត្តិការណ៍ ឬ សកម្មភាព | ចំនួនអ្នកចូលរួម | ទីកន្លែង | អ្នករៀបចំ | ផ្សេងៗ |
|---|---|---|---|---|---|---|
| **ក. ផ្នែកអភិបាលកិច្ច** | | | | | | |
| ១ | ១៥-១៦ មករា ២០១៥ | ចូលរួមកិច្ចប្រជុំលើកទី21របស់ក្រុមប្រឹក្សា និងកិច្ចប្រជុំលើកទី19 ជាមួយដៃគូរអភិវឌ្ឍន៍។<br>• បានអនុម័តគម្រោងថវិកាចំណាយសម្រាប់ទ្រទ្រង់ដល់កិច្ចដំណើរការលេខាធិការដ្ឋាន MRC ប្រចាំឆ្នាំ 2015 ដែលមានចំនួន 4,039,862 ដុល្លា<br>• ក្រុមប្រឹក្សាក៏បានឯកភាពលើគោលការណ៍ជ្រើសរើសនាយកប្រតិបត្តិ MRCS បន្ទាប់ផងដែរដោយឲ្យមានការតែងតាំងពីប្រទេសជាសមាជិកតាមរយៈការប្តូរវេន<br>• ក្រុមប្រឹក្សាក៏បានសំដែងអំណរគុណដៃគូរអភិវឌ្ឍន៍ចំពោះការជួយឧបត្ថម្ភគាំទ្រ MRC។ ជាការឆ្លើយតបដៃគូរអភិវឌ្ឍន៍បានវាយតម្លៃអំពីការប្តេជ្ញាចិត្តរបស់ប្រទេសជាសមាជិកចំពោះកំណែទម្រង់ និងការបង្កើនប្រសិទ្ធភាពការងាររបស់ MRC | ៨២ រូប<br>គណៈប្រតិភូកម្ពុជាមានចំនួន 11រូប ដឹកនាំដោយ **ឯកឧត្តម លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាសមាជិកក្រុមប្រឹក្សាតំណាងកម្ពុជា | ទីក្រុងហាណូយ ប្រទេសវៀតណាម | គណៈកម្មការទន្លេមេគង្គ (MRC) | |
| ២ | ២៨ មករា ២០១៥ | ចូលរួមកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គស្តីពីគម្រោងសាងសង់ទំនប់វារីអគ្គិសនី **ដន សាហុង**។<br>• ជារួម មតិឆ្លើយតបលើគម្រោងទំនប់វារីអគ្គិសនី **ដន សាហុង** ដោយភាគី កម្ពុជា ថៃ និងវៀតណាម មានជំហរប្រហាក់ប្រហែលគ្នា ដោយបានស្នើសុំឲ្យមានការព | ៣០រូប<br>គណៈប្រតិភូ ៤ប្រទេស ជាសមាជិក និងមន្ត្រីលេខាធិការដ្ឋាន | លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ប្រចាំទីក្រុងវៀងច័ន្ទ | គណៈកម្មការទន្លេមេគង្គ (MRC) | |

| ល.រ | កាលបរិច្ឆេទ | អធិប្បាយព្រឹត្តិការណ៍ ឬ សកម្មភាព | ចំនួនអ្នកចូលរួម | ទីកន្លែង | អ្នករៀបចំ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | ន្យាពេល ដើម្បីបន្តការសិក្សា ប្រមូលទិន្នន័យ និងព័ត៌មាន ក៏ដូចជាការវាយតម្លៃបន្ថែមទៀត។ ស្របតាមនីតិវិធីនៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ1995 អង្គប្រជុំបានឯកភាពគ្នានឹងធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាដើម្បីជ្រាបនិងមានការណែនាំ និងរាយការណ៍បន្តជូនរដ្ឋាភិបាលនៃប្រទេសជាសមាជិករៀងៗខ្លួន។ | | | | |
| ៣ | ២៣-២៤ មិនា ២០១៥ | ចូលកិច្ចប្រជុំវិសាមញ្ញលើកទី២ របស់គណៈកម្មាធិការរួម។<br>• បានសម្រេចគាំទ្របេក្ខជនវៀតណាមអោយធ្វើជានាយកប្រតិបត្តទី1 ដោយឈរលើមូលដ្ឋានកិច្ចសហប្រតិបត្តិការមេគង្គ។ ចំពោះនាយកប្រតិបត្តិបន្ទាប់ ភាគីឡាវ និងកម្ពុជាបានស្នើឲ្យប្រើគោលការណ៍តាមលំដាប់តួអក្សរឡាតាំងពីទាបទៅខ្ពស់ | ៣០ រូប<br>គណៈប្រតិភូ ៤ប្រទេស ជាសមាជិក និងមន្ត្រីលេខាធិការដ្ឋាន | លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គប្រចាំទីក្រុងភ្នំពេញ | គណៈកម្មការទន្លេមេគង្គ (MRC) | |
| ៤ | ៥-៨ ឧសភា ២០១៥ | ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី៤១ និងកិច្ចប្រជុំលើកទី១៩ ជាមួយដៃគូសន្ទនា របស់គណៈកម្មាធិការរួម។<br>• បានបញ្ជាក់អះអាងជាឯកច្ឆ័ន្ទ អំពីវេនរបស់ប្រទេសជាសមាជិក ដែលត្រូវធ្វើជានាយកប្រតិបត្តិ (Chief Executive Officer) យកវេនតាមលំដាប់តួអក្សរ គឺ *ទី1 - វៀតណាម, ទី2 - កម្ពុជា, ទី3 - ឡាវ និង ទី4 - ថៃ*។ ដូច្នេះគោលការណ៍នេះបានត្រូវដោះស្រាយចប់សព្វគ្រប់មានន័យថា CEO វៀតណាមនឹងត្រូវធ្វើការចាត់តាំងឆាប់ៗនេះ ហើយនៅ3ឆ្នាំក្រោយ ប្រទេសកម្ពុជាត្រូវដល់វេន សម្រាប់ប៉ុស្តិ៍ CEO<br>• ឯកភាពលើចំណុចមួយចំនួនដែលនៅសេសសល់ស្តីពី | ៦៥ រូប<br>គណៈប្រតិភូ ៤ប្រទេស ជាសមាជិក និងមន្ត្រីលេខាធិការដ្ឋាន | ទីក្រុងសៀមរាប ប្រទេសកម្ពុជា | គណៈកម្មការទន្លេមេគង្គ (MRC) | |

| ល.រ | កាលបរិច្ឆេទ | អធិប្បាយព្រឹត្តិការណ៍ ឬ សកម្មភាព | ចំនួនអ្នកចូលរួម | ទីកន្លែង | អ្នករៀបចំ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | ការកែសម្រួល ***បទបញ្ជាផ្ទៃក្នុង*** របស់គណៈកម្មាធិការរួម និងក្រុមប្រឹក្សា ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត<br><br>• ឯកភាពលើរចនាសម្ពន្ធ័ថ្មីរបស់លេខាធិការដ្ឋាន MRC ដែលមានត្រឹមតែ 4អង្គភាព (4 Units) ដោយពុំចាំបាច់មានជាក្រុមប្រឹក្សាភិបាល (Advisory Board) | | | | |
| ៥ | ៩-១១ កញ្ញា ២០១៥ | ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី៤២ របស់គណៈកម្មាធិការរួម។<br>• ឯកភាពឲ្យមានរយៈពេលអន្តរកាលចំនួន 6ខែ មុននឹងឈានទៅអនុវត្តរចនាសម្ព័ន្ធថ្មីរបស់លេខាធិការដ្ឋាន MRC ដោយរក្សាទុកតែបុគ្គលិកសំខាន់ៗ ប្រមាណជា 100 នាក់<br>• ឯកភាពលើការបង្កើតកញ្ចប់ថវិការួម (MRC Basket Fund) ដែលត្រូវអនុវត្តចាប់ពី ដើមឆ្នាំ 2016<br>• កម្ពុជា ឡាវ និងវៀតណាម បានឯកភាពលើសំណើសុំប្រើប្រាស់រូបមន្តបង់វិភាគទានបច្ចុប្បន្ន សម្រាប់ឆ្នាំ2016<br>• ឯកភាព លើឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គ ឆ្នាំ2016-2020 (Basin Development Strategy) និង ផែនការយុទ្ធសាស្ត្រគណៈកម្មការទន្លេមេគង្គ ឆ្នាំ2016-2020 (MRC Strategic Plan) សម្រាប់ដាក់ជូនក្រុមប្រឹក្សាអនុម័ត | ៦៥ រូប<br>គណៈប្រតិភូ ៤ប្រទេស ជាសមាជិក និងមន្ត្រីលេខាធិការដ្ឋាន | ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ | គណៈកម្មការទន្លេមេគង្គ (MRC) | |
| ៦ | ៩-១០ មិថុនា ២០១៥ | ចូលរួមកិច្ចប្រជុំក្រុមការងារគណៈកម្មាធិការរួម លើកទី២៦ *កញ្ចប់ថវិការួម (MRC Basket Fund) និង លក្ខខ័ណ្ឌការងាររបស់* | ២៩ រូប<br>គណៈប្រតិភូ ៤ប្រទេស ជា | លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ប្រចាំ | គណៈកម្មការទន្លេមេគង្គ (MRC) | |

| ល.រ | កាលបរិច្ឆេទ | អធិប្បាយព្រឹត្តិការណ៍ ឬ សកម្មភាព | ចំនួនអ្នកចូលរួម | ទីកន្លែង | អ្នករៀបចំ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | *គណៈកម្មាធិការថវិកា (TOR of Budget Committee)* | សមាជិក និងមន្ត្រីលេខាធិការដ្ឋាន | ទីក្រុងវៀងច័ន្ទ | | |
| ៧ | ១៤ តុលា ២០១៥ | ចូលរួមកិច្ចប្រជុំក្រុមការងារគណៈកម្មាធិការរួម លើកទី២៧ *ការកែទំរង់រចនាសម្ព័ន្ធរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRCS Restructure)* | ២៥ រូប<br>គណៈប្រតិភូ ៤ប្រទេស ជាសមាជិក និងមន្ត្រីលេខាធិការដ្ឋាន | លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ប្រចាំទីក្រុងវៀងច័ន្ទ | គណៈកម្មការទន្លេមេគង្គ (MRC) | |
| ៨ | ៤ ធ្នូ ២០១៥ | ចូលរួមកិច្ចប្រជុំក្រុមការងារគណៈកម្មាធិការរួម លើកទី២៨<br>• *កម្រិតប្រាក់បៀវត្សរ៍ថ្មីរបស់មន្ត្រី MRCS ( New Salary Scale)*<br>• *ការធ្វើជាម្ចាស់ផ្ទះរបស់លេខាធិការដ្ឋាន MRC និង ការសិក្សាពីទីតាំងមួយ និងពីរ របស់លេខាធិការដ្ឋាន MRC* | ២៩ រូប<br>គណៈប្រតិភូ ៤ប្រទេស ជាសមាជិក និងមន្ត្រីលេខាធិការដ្ឋាន | លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គប្រចាំទីក្រុងភ្នំពេញ | គណៈកម្មការទន្លេមេគង្គ (MRC) | |
| **ខ. អគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក** | | | | | | |
| ៩ | ២៧-២៨ មេសា ២០១៥<br>២១-២២ កញ្ញា ២០១៥ | ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពីកិច្ចការទូតផ្នែកទឹក៖ ច្បាប់ទឹកអន្តរជាតិ និងកិច្ចសហប្រតិបត្តិការតំបន់។<br>• ការយល់ដឹងអំពីខ្លឹមសារនៃ UN Water Convention 1997, ការបំពេញបន្ថែមទៅលើកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការតំបន់មេគង្គ និងទន្លេអន្តរជាតិ និងដើម្បីត្រៀមខ្លួនចូលជាសមាជិក UNWC។ | ចូលរួមដោយអគ្គលេខាធិការ និង មន្ត្រីអគ្គលេខាធិការដ្ឋានមួយចំនួន | ទីក្រុងសៀមរាប និងទីក្រុងភ្នំពេញ | អង្គការ IUCN ក្រោមគម្រោង BRIDGE | |
| ១០ | ៥ កុម្ភះ ២០១៥<br>៩ កក្កដា ២០១៥ | កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះស្តីពីហេដ្ឋារចនាសម្ពន្ធ័ និងសមាហរណកម្មក្នុងតំបន់។<br>• គោលបំណងនៃកិច្ចប្រជុំរៀងរាល់៣ខែម្តងគឺ ដើម្បីរាយការណ៍ អំពីការគាំទ្ររបស់ម្ចាស់ជំនួយ លើគម្រោងដែលបានដាក់ស្នើសុំថវិការបស់ក្រសួងស្ថាប័នពាក់ព័ន្ធនៅ | ចូលរួមដោយអគ្គលេខាធិការ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ក្រសួងសាធារណការ និងដឹកជញ្ជូន | |

| ល.រ | កាលបរិច្ឆេទ | អធិប្បាយព្រឹត្តិការណ៍ ឬ សកម្មភាព | ចំនួនអ្នកចូលរួម | ទីកន្លែង | អ្នករៀបចំ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | ថ្នាក់ជាតិ, រាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តគម្រោង និងចំណុចប្រឈមមួយចំនួន និងមានវិធានការដោះស្រាយស្រប។ | | | | |
| ១១ | ១៧-១៩ តុលា ២០១៥ | ចូលរួមកិច្ចប្រជុំលើកទី១៤ នៃគណៈកម្មការចម្រុះ កម្ពុជា វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្រ្ត និងបច្ចេកវិជ្ជា។<br>• កិច្ចប្រជុំទ្វេភាគីថ្នាក់រដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរប្រចាំឆ្នាំដើម្បីពិនិត្យមើលវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យផ្អែកតាមកំណត់ហេតុ នៃកិច្ចប្រជុំ។ | ចូលរួមដោយអគ្គលេខាធិការ | ទីក្រុង ហូជីមិញ | ប្រទេសវៀតណាម | |
| ១២ | ២១-២៣ តុលា ២០១៥ | ចូលរួមវេទិកាមហាតំបន់មេគង្គស្តីពី ទឹក ស្បៀង និងថាមពល។<br>• ពិភាក្សា ផ្សព្វផ្សាយ លទ្ធផលសិក្សាស្រាវជ្រាវ និងបង្កើនកិច្ចសហការណ៍ ក្នុងតំបន់មេគង្គ លើវិស័យទឹក ស្បៀង និងថាមពល នៃបណ្តាប្រទេស នៅក្នុងតំបន់មេគង្គ ចូលរួមដោយអង្គការសង្គមស៊ីវិល ស្ថាប័នរដ្ឋ ស្ថាប័នសិក្សាស្រាវជ្រាវ នានា។ | ចូលរួមដោយអគ្គលេខាធិការ និង មន្ត្រីអគ្គលេខាធិការដ្ឋានមួយចំនួន | ទីក្រុងភ្នំពេញ | អង្គការ CGIAR និង MRC | |
| ១៣ | ២៦ តុលា ២០១៥ | ចូលរួមកិច្ចប្រជុំត្រៀមស្តីពីកិច្ចសហប្រតិបត្តិការ មេគង្គ-ឡានសាង។<br>• ពិភាក្សាអំពី Concept Note ស្តីពីការបង្កើតយន្តការមេគង្គ ឡានសាង ការលើកគម្រោងសហប្រតិបត្តិការ ជាមួយភាគីចិន ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេស មេគង្គ-ឡានសាង។ | ចូលរួមដោយអគ្គលេខាធិការ | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | |

| ល.រ | កាលបរិច្ឆេទ | អធិប្បាយព្រឹត្តិការណ៍ ឬ សកម្មភាព | ចំនួនអ្នកចូលរួម | ទីកន្លែង | អ្នករៀបចំ | ផ្សេងៗ |
| --- | --- | --- | --- | --- | --- | --- |
| ១៨ | ១៩-២០ តុលា ២០១៥ | សិក្ខាសាលាផ្សព្វផ្សាយស្តីពីការពង្រឹងនូវការយល់ដឹងនិងការចូលរួមកិច្ចសហប្រតិបត្តិការមេគង្គ។<br>• សិក្ខាសាលានេះបានជម្រាបជូនអំពីប្រវត្តិ CNMC និង MRC ទិសដៅរបស់ MRC សម្រាប់ពេលអនាគតតាមរយៈការបង្ហាញជូននូវឯកសារយុទ្ធសាស្រ្តអភិវឌ្ឍន៍អាង (Basin Development Strategy) ២០១៦-២០២០ ផែនការយុទ្ធសាស្រ្តរបស់ MRC ២០១៦-២០២០ ការកែទម្រង់រចនាសម្ព័ន្ធស្ថាប័ន MRC និងចែករំលែកការយល់ដឹងអំពីការលើកកំពស់យន្តការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការរវាងគណៈកម្មាធិការជាតិទន្លេមេគង្គជាជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងក្របខណ្ឌ MRC | ៣៥រូប មកពីមន្ទីរធនធានទឹកនិងឧតុនិយមនិងមន្ទីរផែនការពីខេត្ត-ក្រុងចំនួន១៨ជុំវិញបឹងទន្លេសាប និងតាមដងទន្លេមេគង្គ | នៅទីរួមខេត្តពោធិសាត់ | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | |
| ១៥ | ១៦-១៧ វិច្ឆិកា ២០១៥ | សិក្ខាសាលាផ្សព្វផ្សាយស្តីពីការពង្រឹងនូវការយល់ដឹងនិងការចូលរួមកិច្ចសហប្រតិបត្តិការមេគង្គ។<br>• បាន បង្ហាញជូនសិក្ខាកាមចូលរួមអំពីប្រវត្តិសង្ខេបនិងកិច្ចសហប្រតិបត្តិការរវាង MRC និង CNMC និងជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអំពីផលប្រយោជន៍រូបវន្ត និងមិនរូបវន្ត ផលប្រយោជន៍សេដ្ឋកិច្ច-ហិរញ្ញវត្ថុនិងផលប្រយោជន៍ពីសហប្រតិបត្តិការតំបន់ដែលកម្ពុជាទទួលបានពីកិច្ចសហប្រតិបត្តិការជាមួយ MRC។ បង្ហាញជូនពីសារៈសំខាន់នៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ និងនីតិវិធីទាំង៥ព្រមទាំងចំណុចខ្វះខាត និងការលំបាកមួយចំនួនក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះនិងជម្រាបជូនផង | ២៥រូប មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ | ទីក្រុងសៀមរាប | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | |

| ល.រ | កាលបរិច្ឆេទ | អធិប្បាយព្រឹត្តិការណ៍ ឬ សកម្មភាព | ចំនួនអ្នកចូលរួម | ទីកន្លែង | អ្នករៀបចំ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | ដែរអំពីកំណែទម្រង់រចនាសម្ព័ន្ធនិងហិរញ្ញវត្ថុរបស់ MRC។ | | | | |
| **គ. បណ្តានាយកដ្ឋានក្រោមអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក** | | | | | | |
| **គ១. នាយកដ្ឋាន រដ្ឋបាលនិងហិរញ្ញវត្ថុ** | | | | | | |
| ១៦ | ២ មិថុនា ២០១៥ | ចូលរួមកិច្ចប្រជុំសម្របសម្រួលថ្នាក់តំបន់ស្តីពីការងារវិមជ្ឈការមុខងារស្នូលក្នុងការគ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គ។<br>• ការពិភាក្សាអំពីបញ្ហាសម្របសម្រួលក្នុងគម្រោង<br>• ផែនការការងារនិងសកម្មភាពពីខែមិថុនាដល់ខែធ្នូ ឆ្នាំ ២០១៥ និង<br>• ធ្វើបច្ចុប្បន្នភាពអំពីការរីកចម្រើន បញ្ហាសេសសល់ និងបញ្ហាប្រឈមនៃសកម្មភាពក្នុងកញ្ចប់ទី១ និងបញ្ហាទាក់ទងនឹងសកម្មភាពដែលបានស្នើសុំសម្រាប់កញ្ចប់ទី២ | ០២រូបពី គ.ជ.ទ.ម.ក | ទីក្រុងហូជីមិញ ប្រទេសវៀតណាម | គណៈកម្មការទន្លេមេគង្គ (MRC) | |
| ១៧ | ៨ មិថុនា ២០១៥ | ចូលរួមកិច្ចប្រជុំថ្នាក់តំបន់ស្តីពីការងារវិមជ្ឈការមុខងារស្នូលក្នុងការគ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គ។<br>• វឌ្ឍនភាពដំណើរការវិមជ្ឈការនៃសកម្មភាពកញ្ចប់ទី១<br>• សំណើសកម្មភាពសម្រាប់ធ្វើវិមជ្ឈការកញ្ចប់សកម្មភាពទី២ក្នុងឆ្នាំ២០១៦-២០២០។ | ១០រូបពីគ.ជ.ទ.ម.ក | លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គប្រចាំក្រុងវៀងច័ន្ទ ប្រទេសឡាវ | គណៈកម្មការទន្លេមេគង្គ (MRC) | |
| ១៨ | ៧-៨ កក្កដា ២០១៥ | ចូលរួមកិច្ចប្រជុំថ្នាក់តំបន់ស្តីពីការងារវិមជ្ឈការមុខងារស្នូលក្នុងការគ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គ។<br>• កិច្ចប្រជុំនេះផ្តោតលើការពិភាក្សា ការពិនិត្យមើលឡើងវិញនូវសកម្មភាពនៃមុខងារស្នូលដែលនឹងត្រូវធ្វើមជ្ឈការ | ១០រូបពីគ.ជ.ទ.ម.ក | លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គប្រចាំទីក្រុងភ្នំពេញ | គណៈកម្មការទន្លេមេគង្គ (MRC) | |

| ល.រ | កាលបរិច្ឆេទ | អធិប្បាយព្រឹត្តិការណ៍ ឬ សកម្មភាព | ចំនួនអ្នកចូលរួម | ទីកន្លែង | អ្នករៀបចំ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | និងទិដ្ឋភាពបច្ចេកទេសនៃសកម្មភាពទាំងនេះ។ | | | | |
| ១៩ | ២ កុម្ភៈ ២០១៥ | រៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីរៀបចំកញ្ចប់សកម្មភាពវិមជ្ឈការទី២ក្នុងឆ្នាំ២០១៦-២០២០។<br>• បាននិត្យ និងពិភាក្សាឡើងវិញលើមុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គសម្រាប់រៀបចំកញ្ចប់សកម្មភាពវិមជ្ឈការទី២ក្នុងឆ្នាំ០១៦-២០២០។ | ៣៥រូប មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ | ទីក្រុងកំពង់ចាម | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | |
| ២០ | ១០ វិច្ឆិកា ២០១៥ | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិដើម្បីរៀបចំផែនការវិមជ្ឈការកញ្ចប់សកម្មភាពទី២សម្រាប់ឆ្នាំ២០១៦-២០២០។ | ២៧រូប មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ | ទីក្រុងព្រះសីហនុ | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | |
| **គ២. នាយកដ្ឋាន បុគ្គលិកនិងអភិវឌ្ឍធនធានមនុស្ស** | | | | | | |
| ២១ | ២៦ កុម្ភៈ ២០១៥ | ចូលរួមកិច្ចប្រជុំលើកទី១០ របស់គណៈកម្មាធិការដឹកនាំកម្មវិធីកសាងសមត្ថភាពចម្រុះ (ICBP) | ០៣រូប ពីកម្ពុជា | ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ | MRC-ICBP | |
| ២២ | ៦-៨ ធ្នូ ២០១៥ | ចូលរួមកិច្ចប្រជុំលើកទី១១ របស់គណៈកម្មាធិការដឹកនាំកម្មវិធីកសាងសមត្ថភាពចម្រុះ (ICBP) | ០៣រូប ពីកម្ពុជា | ក្រុងបាងកក ប្រទេសថៃ | MRC-ICBP | |
| ២៣ | ១២-១៧ មេសា ២០១៥ | ការចូលរួមរបស់គណៈប្រតិភូប្រទេសជាសមាជិក MRC ក្នុងវេទិកាទឹកពិភពលោកលើកទី៧ នៅទីក្រុងដាហ្គូ សាធារណៈរដ្ឋកូរ៉េ | គណៈប្រតិភូកម្ពុជា ០៧រូប | ទីក្រុងដាហ្គូ សាធារណៈរដ្ឋកូរ៉េ | | |
| ២៤ | ៦ មិនា ២០១៥ | រៀបចំសិក្ខាសាលាអបអរសាទរនិងចូលរួមសំដែងមតិចំពោះខួបអនុស្សាវរីយ៍លើកទី104 ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០១៥ | ២៨រូប | ទីក្រុងកំពង់ចាម | CNMC-ICBP | |

